ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-Aug-2012, 14:29
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១០៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ច័ន្ទ តារាស្មី

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ *(Mr. Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្ដម

លោក ម៉ៃខល កាណាវាស

*(Mr. Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក គឹម ម៉េងឃី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក អែម អឿន (TCCP-28) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក អែម អឿន ហៅ អៀប ឡុន** (TCCP-28)

សួរបន្តដោយលោក ហ្សាស្តេី ប៉ោ ផ្តើមពី៖ ............................................................. ទំព័រ ៣
សួរដោយលោក ម៉ែខល កាណាវាស ផ្តើមពី៖ ............................................................. ទំព័រ ៣២
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី៖ ............................................................. ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤០]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន ដែលនឹងតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្ដីទាំងបីក្រុម ដែលព្រឹកនេះនឹងបន្តការតាំងសំណួរដោយក្រុមមេធាវីការពារក្ដីលោក នួន ជា។

ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដើម្បីតាំង -- ឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ ទី១ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្ដីក្នុងសំណុំរឿង ០០២ទាំងអស់បានជ្រាបថា នៅក្នុងកិច្ចដំណើរការសវនាការក្នុងសប្ដាហ៍នេះ ដែលចាប់ផ្ដើមពីថ្ងៃនេះ គឺថ្ងៃអង្គារ ទី២៨ ខែសីហា ឆ្នាំ២០១២ នេះទៅ និងថ្ងៃបន្តបន្ទាប់ លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ មានធុរៈចាំបាច់ផ្ទាល់ខ្លួន គាត់មិនអាចចូលរួមក្នុងកិច្ចដំណើរការសវនាការបាន។ បន្ទាប់ពីយើងបានពិគ្រោះយោបល់ជាមួយនឹងបណ្ដាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ជាចៅក្រមបម្រុងអន្តរជាតិជំនួសកន្លែងចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដែលអវត្តមាន រហូតដល់ពេលណាដែលលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ការអនុវត្តនេះដោយផ្អែកតាមបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក។

[០៩:០៥:០៣]

ជាបន្តលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលទាំងឡាយ ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះមានវត្តមាន។ លើកលែងតែជន

ជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិ តាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញ១ថ្ងៃនៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ចំណែកឯសាក្សី ដែលត្រូវមកផ្ដល់សក្ខីកម្មបន្ទាប់ពីបញ្ចប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី គឹម វុន (ស៊ីក) គឺសាក្សីដែលមានរហស្សនាម TCW-480។ សាក្សីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយ នៅចំពោះមុខលោកតាដំបងដែក កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២នេះ។ សូមអរគុណលោកប្រធាន។

[០៩:០៦:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេល១ថ្ងៃនេះ។

លោកវេជ្ជបណ្ឌិត គឹម សមសាន្ត គ្រូពេទ្យទទួលពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំនៃ អ.វ.ត.ក បានពិនិត្យសុខភាពរបស់លោក អៀង សារី នៅព្រឹកនេះ បានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈហត់ខ្លាំងនៅពេលធ្វើចលនាបន្តិចបន្តួច និយាយវែងមិនបាន និយាយដាច់ៗ នៅពេលអង្គុយ ឬដើរ ជើងទាំងពីរហើមកាន់តែខ្លាំង និងឈឺចង្កេះពិបាកអង្គុយ។ និងបានផ្ដល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។

នៅពេលនេះ លោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ គាត់មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយ និង

ស្នារតីសមស្រប។ គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្ដីរបស់គាត់បានដែរ។

[០៩:០៧:៥៥]

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញ១ថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន។ បាទ សូមអញ្ជើញ!

**លោក ហ្សាស្ដេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ អរុណសួស្ដីលោក លោកស្រី។ ស្វាគមន៍លោកស្រីចៅក្រមហ្វេនស៍។

**សួរបន្តដោយលោក ហ្សាស្ដេ ប៉ៅ៖**

**ស៖** អរុណសួស្ដីលោក អែម អឿន។ ខ្ញុំនឹងបន្តត្រង់ចំណុចដែលខ្ញុំឈប់កាលពីម្សិលមិញ។ ខ្ញុំនឹងព្យាយាមនិយាយដោយយឺតៗ និងសួរសំណួរងាយៗ។ សំណួរទី១ របស់ខ្ញុំនោះ គឺពាក់ព័ន្ធទៅនឹងការប្រជុំនយោបាយនៅបុរីកីឡា។ តើលោកមានបានចូលរួមដែរឬទេ? តើការប្រជុំនយោបាយនៅបុរីកីឡានេះបានប្រជុំនៅក្នុងឆ្នាំណាដែរ ដែលលោកបានចូលរួមនោះ?

**លោក អែម អឿន៖**

**ឆ៖** ការប្រជុំនៅបុរីកីឡា មិនមានទេ ខ្ញុំមិនមានចូលរៀនសូត្រជាមួយ។ នៅពេលនៅវេលានោះ ខ្ញុំមិនបានចាំថ្ងៃទេ តែខ្ញុំចាំបានថានៅក្នុងខែ៧ ដើមខែ៧ បាទ។ សូមបន្តទៀតចុះ។

[០៩:១០:០០]

**ស៖** ខ្ញុំសូមបញ្ជាក់បំភ្លឺចម្លើយរបស់លោក ការបកប្រែនោះគឺបានបញ្ជាក់ថា លោកបានចូល

វគ្គរៀនសូត្រនយោបាយនៅបុរីកីឡា។ តើលោកមានបានឆ្លើយដូច្នេះដែរឬទេ?

[០៩:១០:៣៥]

**ឆ៖** ចូលរៀនសូត្រ ខ្ញុំពិតជាបានចូល។ បាទ សូមអស់ៗយោបល់។

**ស៖** លោកទើបតែឆ្លើយថា ការរៀនសូត្រនោះគឺក្នុងខែកក្កដា តើនៅក្នុងឆ្នាំណាដែរ នៅក្នុងខែកក្កដាហ្នឹង?

**ឆ៖** សូមបន្ថែម គឺនៅក្នុងឆ្នាំ -- ដើម ឬចុងឆ្នាំ -- អ៊ំ ដើមឆ្នាំ៧៧។ សូមអស់។

**ស៖** ខ្ញុំសូមបញ្ជាក់ពេលវេលាឲ្យបានត្រឹមត្រូវបន្តិច លោកមកភ្នំពេញនៅពេលណាដែរ មកធ្វើការនៅមន្ទីរពេទ្យនោះ?

**ឆ៖** ខ្ញុំមករៀននៅមន្ទីរពេទ្យរុស្ស៊ី គឺនៅក្នុង១ខែ៦ ឆ្នាំ៧៥។

**ស៖** តើលោកធ្វើការនៅមន្ទីរពេទ្យនោះរយៈពេលប៉ុន្មានដែរ នៅពេលដែលលោកចូលរួមវគ្គនយោបាយនៅបុរីកីឡានោះ?

**ឆ៖** សូមបញ្ជាក់បន្ថែម--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី -- សហមេធាវីជាតិ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:១២:៣៣]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំបានចាំថា នៅពេលដែលខ្ញុំសួរសំណួរទៅលោក អែម អឿន នៅសប្តាហ៍មុន ខ្ញុំបានសួរបញ្ជាក់អំពីពេលវេលានេះរួចហើយ ដោយប្រៀប -- ដោយនិយាយអំពីពេលដែលគាត់មកដល់ ពេលដែលគាត់រយៈពេលដែលគាត់ទៅ -- បន្ទាប់ពីពេលមកដល់ ហើយរហូតដល់ពេលដែលគាត់ទៅប្រជុំបុរីកីឡា រហូតទៅដល់ពេល -- រៀនសូត្រនៅបុរីកីឡារហូតដល់ពេលគាត់ត្រូវត្រឡប់ទៅតំបន់២០វិញ។ ដូច្នេះសំណួរទាំងអស់នេះ ត្រូវបានសួររួចហើយ ហើយក៏ត្រូវបានឆ្លើយរួចហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបនឹងសំណួរ! អង្គជំនុំជម្រះចាំបាច់ត្រូវស្តាប់ នូវចម្លើយតបរបស់ដើមបណ្តឹង

រដ្ឋប្បវេណីតបទៅនឹងសំណួរនេះ។ កាលវេលាពាក់ព័ន្ធ នៃបញ្ហាដែលកើតឡើងនៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងអង្គហេតុ ដែលដើមបណ្ដឹងរដ្ឋប្បវេណីនេះបានដឹងនិងបានចូលរួម គឺជាការចាំបាច់ ក្នុងការដេញដោលចំពោះសាក្សីនេះ ដើម្បីបញ្ជាក់ការពិត។

[០៩:១៣:៤២]

**លោក អែម អឿន៖**

**ឆ៖** ត្រង់ណោះលោកប្រធាន ខ្ញុំសូមជម្រាបរឿងពិត ខ្ញុំបាននិយាយដូចលោកមេធាវីគាត់បានមានប្រសាសន៍រួចហើយថា ពេលវេលានិងការចេញទៅវិញនោះគឺជាពេលកំណត់ បានចេញ បាននិយាយរួចហើយអស់ហើយ។ សូមអស់យោបល់។

**សួរដោយលោក ហ្វាស្ដើ ប៉ោ៖**

**ស៖** ខ្ញុំនឹងសួរសំណួរឡើងវិញ។ ដោយសារតែចម្លើយរបស់លោក មិនឆ្លើយច្បាស់។ តើក្រោយពេលលោកមកភ្នំពេញនោះ មកធ្វើការនៅមន្ទីរពេទ្យ -- ខ្ញុំរៀបសំណួរឡើងវិញ ដើម្បីឲ្យលោកងាយយល់ និងបង្កើតជាសំណួរងាយៗចំពោះលោក។ តើក្រោយពេលលោកមកដល់ទីក្រុងភ្នំពេញ រយៈពេលប៉ុន្មានដែរ? ក្រោយដែលលោកមកធ្វើការនៅពេទ្យរុស្ស៊ីនោះ រយៈពេលប៉ុន្មានដែរទើបគេរៀបចំវគ្គរៀនសូត្រនៅបុរីកីឡានោះ?

[០៩:១៥:០៣]

**ឆ៖** ត្រង់នេះសូមបំភ្លឺបន្ថែម បើខ្ញុំចាំមិនច្បាស់ទេក្រែងលោខ្ញុំនិយាយខុស សូមទោសទុកជាមុនថាប្រហែលជា១ខែ ឬ២ខែ និយាយឲ្យខ្លីគឺ២ខែ បានខ្ញុំចូលសិក្សាវគ្គនយោបាយ។ សូមអស់យោបល់។

**ស៖** ប្រហែលជាមានការបកមិនពេញលេញ -- បកប្រែមិនពេញលេញ។ លោកមកដល់ទីក្រុងភ្នំពេញនៅក្នុងខែមិថុនា ឆ្នាំ១៩៧៥។ នេះជាចម្លើយដែលលោកបានទើបតែឆ្លើយអម្បាញ់មិញ។ តើក្រោយខែមិថុនា ឆ្នាំ៧៥ នោះរយៈពេលប៉ុន្មានដែរ ទើបលោកបានទៅចូលរួមវគ្គរៀនសូត្រនយោបាយនៅបុរីកីឡានោះ? បី-បួនខែក្រោយខែមិថុនា ឆ្នាំ៧៥ ឬក៏មួយឆ្នាំ ពីរឆ្នាំក្រោយខែមិថុនា ឆ្នាំ១៩៧៥ ឬក៏បួន-ប្រាំឆ្នាំ ក្រោយខែមិថុនា ឆ្នាំ១៩៧៥?

[០៩:១៦:១០]

**ឆ៖** សូមបញ្ជាក់ ស្ដាប់អត់បានកន្លែងហ្នឹង អត់យល់សំណួរ។

**ស៖** តើលោកធ្វើការនៅមន្ទីរពេទ្យសូវៀតនោះរយៈពេលប៉ុន្មានដែរ មុនពេលដែលលោកទៅ

ចូលរួមរៀនវគ្គនយោបាយនៅបុរីកីឡានោះ?

**ឆ៖** ខ្ញុំបានបញ្ជាក់អំមិញថា រយៈពេល២ខែបានខ្ញុំចូលរៀននយោបាយ។ ការពិតទៅការចូលមកដល់ទីក្រុងភ្នំពេញ គឺខ្ញុំដឹងថាចូលនៅ៧ខែ -- នៅក្នុងចុងខែ៦ ហ្នឹងការចូលដល់ភ្នំពេញ តែក្រោយពេលចូលដល់ហើយ ខ្ញុំចូលសិក្សានៅពេលវេលា ក្រោយមក២ខែបានចូលរៀនបាទ។ អស់យោបល់។

**ស៖** ដូច្នេះ២ខែក្រោយពេលដែលលោកចូលទីក្រុងភ្នំពេញ គឺលោកចូលមកដល់ទីក្រុងភ្នំពេញខែមិថុនា ឆ្នាំ១៩៧៥ តើត្រឹមត្រូវដែរឬទេ ដែលខ្ញុំអាចនិយាយថា តាមការចងចាំរបស់លោកនោះ លោកបានចូលរួមរៀនវគ្គនយោបាយនោះគឺប្រហែលជានៅក្នុងខែសីហា ឬក៏ខែកញ្ញា ឆ្នាំ១៩៧៥ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ត្រង់នេះ ខ្ញុំទទួលស្គាល់ពាក្យ ព្រោះខ្ញុំបានដឹងថាអ៊ីចេះ សូមបញ្ជាក់ថាខ្ញុំ--

**លោក វាំងសង់ វ៉ាយដ៍ ដេស្បាងលេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត។

[០៩:១៨:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្បាងលេ៖**

សូមអរគុណលោកប្រធាន។ តាមពិត ខ្ញុំជំទាស់ទៅនឹងសំណួរចុងក្រោយនេះ ពីព្រោះថាពីមុនមកចម្លើយពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទចូលរួមនៅក្នុងកិច្ចប្រជុំនយោបាយនោះ គឺយើងដឹងទាំងអស់គ្នាហើយ គឺគាត់បញ្ជាក់ថា ប្រហែលជាខែកក្កដា ឬប្រហែលជាខែមិថុនា ឆ្នាំ៧៧។ ដូច្នេះ យើងត្រូវតែសួរគាត់ ថាតើមានភាពផ្ទុយគ្នាអត់រវាងកាលបរិច្ឆេទនេះ ហើយបើយើងសួរថាចាប់ពីខែ៦ ៧៥ ទៅនេះគឺវាមិនត្រឹមត្រូវទេ។ ដូច្នេះមានន័យថាយើងអត់យល់អំពីចម្លើយ ដែលគាត់បានផ្តល់ពីមុនៗមកនោះទេបើសួរបែបនេះនោះ។

**លោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំហាក់ដូចជា មិនយល់ការជំទាស់ពីខាងសហព្រះរាជអាជ្ញាសោះ។ មិនថាដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយត្រឹមត្រូវ ឬក៏ស្មោះត្រង់នៅក្នុងចម្លើយរបស់គាត់ និងចម្លើយដែលឆ្លើយជូនអង្គជំនុំជម្រះត្រឹមត្រូវ ឬក៏ការពិត ឬការមិនពិតនោះ យើងត្រូវតែបង្ហាញឲ្យបានត្រឹមត្រូវ។ បញ្ហានេះជាបញ្ហាសំខាន់ ដើម្បី

សួរបញ្ជាក់ថា តើគាត់ចងចាំការបរិច្ឆេទនោះត្រឹមត្រូវដែរឬទេ។ ហើយគាត់ចាំត្រឹមត្រូវទៅលើអ្វីដែលបានកើតឡើង និងអ្វីដែលគាត់ឆ្លើយនោះដែរឬទេ។

[០៩:១៩:៥១]

ពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះបានបង្ហាញថា វាមានការច្របូកច្របល់ទៅលើកាលបរិច្ឆេទសំខាន់ៗមួយចំនួន។ ខ្ញុំនឹងសួរបញ្ជាក់ទៅលើចំណុចនេះនាពេលក្រោយ។ ពាក់ព័ន្ធនឹងកាលបរិច្ឆេទអម្បាញ់មិញនេះ កាលពីព្រឹកមិញខ្ញុំឮកាលបរិច្ឆេទបីខុសគ្នា គឺឮខែកក្កដា ឆ្នាំ១៩៧៧ ដែលគាត់ថា គាត់ទៅចូលរួមវគ្គនយោបាយនៅបុរីកីឡា។ ដូច្នេះហើយនៅពេលនេះគឺខ្ញុំបែរជាឮថា គាត់បានទៅរៀនសូត្រវគ្គនយោបាយនោះពីរខែ ក្រោយពេលដែលគាត់មកដល់ទីក្រុងភ្នំពេញនៅខែមិថុនាឆ្នាំ១៩៧៥។ ដូច្នេះ ខ្ញុំគិតថា បញ្ហាទាំងអស់នេះត្រូវតែចុចសួរ និងបញ្ជាក់ឲ្យបានច្បាស់លាស់។ នេះជាគោលបំណងនៃការតាំងសំណួរ ដេញដោល។

លោកប្រធាន សុំការអនុញ្ញាតសួរបញ្ជាក់ទៅលើចំណុចនេះ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងមូលហេតុសំអាងហេតុនៃសេចក្ដីជំទាស់មិនត្រឹមត្រូវ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីការពារក្ដីសួរលម្អិតបញ្ជាក់ឲ្យកាន់តែច្បាស់លាស់អំពីកាលបរិច្ឆេទទាំងឡាយពាក់ព័ន្ធទៅនឹងវត្តមានរបស់សាក្សីនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងការចូលរួមក្នុងកិច្ចប្រជុំរៀនសូត្រនយោបាយនៅបុរីកីឡា។ សាក្សីត្រូវឆ្លើយតបឲ្យបានត្រឹមត្រូវ និងជាក់ច្បាស់ទៅនឹងសំណួរដែលសួរពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទនេះ។

[០៩:២១:៤៣]

**លោក អែម អឿន៖**

សូមជម្រាបលោកប្រធាន ចំណុចខ្ញុំសូមសម្គាល់យកបានថា តាមការគិតរបស់ខ្ញុំគឺ ច្បាស់លាស់នៅ ៧៦ ព្រោះខ្ញុំនិយាយពីម្សិលមិញ ខ្ញុំបានប្រើពាក្យមួយថា ប្រហែលជាចុងឆ្នាំ៧៦ ឬដើមឆ្នាំ៧៧ នោះគឺជាពាក្យពិតរបស់ខ្ញុំ តែត្រង់ការកំណត់លោកអ្នកកត់ត្រាទុកនោះ ខ្ញុំចង់ដឹងថា គាត់យកពេលណាទេ តែថ្ងៃនេះ ខ្ញុំសុំបញ្ជាក់រឿងពិតកុំឲ្យមានការសង្ស័យទៀត គឺខ្ញុំសូមយកនៅចុងខែ៦ ចុងឆ្នាំខែ៦ តែថាខែថាថ្ងៃណានោះ ខ្ញុំមិនប៉ានកំណត់ទេ ព្រោះយូរហើយពេក។ អ៊ីចឹងខ្ញុំសូមសម្គាល់យកខែ៦ គឺការងារដែលខ្ញុំចូលរៀនគឺពិត ខ្ញុំទទួលស្គាល់បាទ។ សូមអស់យោបល់។

**ប្រធានអង្គជំនុំ៖**

ខែ៦ ឬក៏ឆ្នាំ៧៦? ឲ្យច្បាស់លាស់ ព្រោះកាលណាមានថ្ងៃ បើមិនចាំថ្ងៃទេ ឲ្យកាលបរិច្ឆេទជាខែ និងឆ្នាំ ឲ្យច្បាស់លាស់។ ពីព្រោះយើងពិនិត្យបញ្ហានេះដែរ ឃើញថាមានបញ្ហាច្របូកច្របល់មិនច្បាស់លាស់នៅក្នុងការផ្តល់សក្ខីកម្មពាក់ព័ន្ធជាមួយនឹងកាលបរិច្ឆេទនេះ ហើយកាលបរិច្ឆេទនេះវាសំខាន់ពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវ ដែលលើកមកដេញដោល ពាក់ព័ន្ធជាមួយនឹងកិច្ចប្រជុំសិក្សារៀនសូត្រនយោបាយនៅបុរីកីឡា។ នេះអង្គហេតុចម្បងមានតែមួយហ្នឹងទេ។ សូមបញ្ជាក់ឡើងវិញ ខែ? ឆ្នាំ? ឲ្យច្បាស់ បើអ្នកប្រើខែបាន គឺកុំប្រើខែ៦ ខែមិថុនា ខែកក្កដា ខែសីហា នេះជាខែខ្មែរ។ ខែ៦ ខែ៧ ហ្នឹងមិនមែនខែខ្មែរទេ អក្សរខ្មែរហ្នឹងអក្សរ នៅក្នុងវចនានុក្រម ជួន ណាត ក្តីគឺមិនមានទេ។

[០៩:២៤:០២]

**លោក អែម អឿន៖**

អរគុណលោកប្រធាន។ ចំណុចថាខែ៦ ខែ៧ គឺជាការចងចាំរបស់ខ្ញុំ ប៉ុន្តែពាក្យថា សីហា ធ្នូអី អត់ស្គាល់ សុំទោសលោកប្រធាន។ ខ្ញុំអត់ស្គាល់ពាក្យថា ជាខែណាៗទេ ស្គាល់ខែ១ ខែ២ ខែ៣ រហូតដល់ ខែ១០ ស្គាល់។

**ប្រធានអង្គជំនុំ៖**

ឥឡូវតាមដំណើរហ្នឹងលោកទៅចុះ! ពីព្រោះលោកជាខ្មែរ លោកអត់ស្គាល់ អ៎! លោកអត់ចេះខែខ្មែរផង ប៉ុន្តែលោកបញ្ជាក់ឲ្យច្បាស់លាស់កាលបរិច្ឆេទហ្នឹង ខែណា? ឆ្នាំណា? នៅពេលដែលលោកនិយាយអំពីកាលបរិច្ឆេទ គឺនិយាយអំពី បើមិនចាំថ្ងៃទេ គឺខែ ខែណា? ឆ្នាំណា? ឧទាហរណ៍លោកចូលមករៀននៅ សាលាមន្ទីរពេទ្យសូវៀតនៅខែ៦ ឆ្នាំ១៩៧៥។ អ៊ីចឹងដល់ពេលលោកទៅរៀននៅសាលានយោបាយនៅ បុរីកីឡានៅក្នុងខែណា? ឆ្នាំណា? លោកចាកចេញ។ សំណួរនឹងអាចសួរបន្តបន្ទាប់ហើយពីកាលបរិច្ឆេទនេះ ព្រោះពិនិត្យឃើញថា មានភាពមិនប្រាកដប្រជានៅក្នុងការឆ្លើយពាក់ព័ន្ធនឹងកាលបរិច្ឆេទ។ សូមលោកឆ្លើយបញ្ជាក់ឲ្យច្បាស់លាស់ ចៀសវាងបញ្ហាហ្នឹងគឺនៅជញ្ជ្រំ នៅហ្នឹងអស់ពេលយ៉ាងយូរហើយណ៎ះ!

**លោក អែម អឿន៖**

អរគុណលោកប្រធាន។ អ៊ីចឹងខ្ញុំសូមសម្គាល់យកក្នុងតុលាការថា ខ្ញុំចូលសិក្សានយោបាយនៅក្នុងខែ៦ អ៎! នៅក្នុងឆ្នាំ៧៦ សូមទោស នឹកម្តងទៀតសិន។ នៅខែ៧ ឆ្នាំ៧៦ បាទ។ សូមអស់

យោបល់លោកប្រធាន។

**សួរដោយលោក ហ្សាស្តេ ប៉ោះ**

**ស៖** លោកសាក្សី ខ្ញុំយល់ថា វាពិបាកធ្វើឱ្យលោករំឭកឡើងវិញទៅលើកាលបរិច្ឆេទទាំងអស់នេះ។ ក៏ប៉ុន្តែចំណុចមួយ ដែលត្រូវឱ្យលោកបញ្ជាក់កាលបរិច្ឆេទឱ្យត្រឹមត្រូវនោះគឺមានដូចតទៅ។ លោកបានឆ្លើយថា លោកចូលរួមវគ្គរៀនសូត្រនយោបាយនៅបុរីកីឡា ប្រហែលជាពីរខែក្រោយពេលដែលលោកធ្វើការ -- ចាប់ផ្តើមធ្វើការនៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត តើលោកនៅចាំទេ ដែលថា លោកបានទៅរៀនវគ្គនយោបាយនោះនៅបុរីកីឡានោះ គឺពីរខែក្រោយពេលដែលលោកចាប់ផ្តើមធ្វើការនៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត។ តើលោកនៅតែរក្សាចម្លើយនេះដែរឬទេ?

[០៩:២៧:២៨]

**លោក អែម អឿន៖**

**ឆ៖** ខ្ញុំៗសូមរក្សាចម្លើយដែលខ្ញុំឆ្លើយហើយ។ សូមអស់។

**ស៖** វាពិបាកក្នុងការយល់ជាភាសាអង់គ្លេសនោះណាស់ តើលោកនៅតែរក្សាចម្លើយរបស់លោកដែរឬទេ ដែលថា លោកទៅរៀនវគ្គនយោបាយនៅបុរីកីឡានោះ គឺពីរខែក្រោយពេលដែលលោកចាប់ផ្តើមធ្វើការងារនៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត។ តើអ៊ីចឹងដែរឬទេ លោកនៅតែរក្សាចម្លើយនេះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកអ្នកដើមចោទ ថាខ្ញុំនៅតែទទួល ព្រោះខ្ញុំបានធ្វើអ៊ីចឹង គ្រាន់តែខ្ញុំខាងដើមកន្លងមកនោះ វាមិនបានចាំថ្ងៃខែ ព្រោះថាស្មានថាវាមិនដល់ -- វាមិនអាចជួបអ៊ីចឹង។ ម្ល៉ោះហើយការចងចាំអាចនឹងភ្លេចភ្លាំងលើកាលបរិច្ឆេទ ប្រហែលជាការខុសគ្នាដោយសារការភ្លេចភ្លាំង វាយូរអង្វែងពេក ប្រហែលជាភ្លេចខ្លះ សូមអធ្យាស្រ័យបាទ។ ប៉ុន្តែខ្ញុំសូមរក្សាទុកថា ប្រហែលជាពីរខែក្រោយពេលខ្ញុំចូលមករៀនៗពេទ្យ គឺពីរខែក្រោយហ្នឹង បានខ្ញុំចូលៗរៀននយោបាយបាទ។

[០៩:២៨:៥៨]

**ស៖** សូមអរគុណលោក អែម អឿន។ កាលពីម្សិលមិញ យើងបានជជែកគ្នាបន្តិចបន្តួចដែរអំពីលោកសរ សារិន លោកបានជម្រាបអង្គជំនុំជម្រះថា លោកសរ សារិន បាននិយាយប្រាប់លោកអំពីដំណើរការកាត់ក្តីនៅតុលាការ អ.វ.ត.ក នេះ។ មុនពេលដែលយើងឈប់សម្រាក លោកបានជម្រាបយើងខ្ញុំថា លោក សរ សារិន បានប្រាប់លោកអំពីវគ្គរៀនសូត្រនយោបាយនៅបុរីកីឡា ដែលលោក សរ

សារិន ថាគាត់បានចូលរួមផងដែរ។ តើលោកអាចជម្រាបអង្គជំនុំជម្រះបានដែរឬទេ តើលោក សរ សារិន នោះបាននិយាយប្រាប់លោកអំពីវគ្គរៀនសូត្រនយោបាយនៅបុរីកីឡានោះយ៉ាងម៉េចខ្លះដែរ?

**ផ៖** សូមជម្រាបជូនលោកម្ចាស់សំណួរ ត្រង់នេះគ្រាន់តែខ្ញុំមិនបានអីអ្វីឡើយ ខាងដើមឡើយ គឺខ្ញុំចង់ គ្រាន់តែដឹងថាការដាក់ពាក្យបណ្ដឹងនៅទីណាៗ លោក សរ សារិន បាននិយាយ។ ប៉ុន្តែត្រង់ថាការបញ្ជាក់បរិច្ឆេទថា គាត់ចូលរៀននៅម៉ោងណា? ខែណា? ឆ្នាំណា? នោះ ខ្ញុំគ្រាន់តែបានដឹងថា គាត់ថាចូលទេ តែពេលណា អីណានោះ ខ្ញុំមិនបានដឹងទេ។ បាទ សូមអរគុណបាទ។

**ស៖** តើលោក សរ សារិន នោះបានប្រាប់លោកអំពីវគ្គរៀនសូត្រនយោបាយដែលគាត់ចូលរួមហ្នឹងអ្វីខ្លះដែរ?

**ផ៖** សូមមានយោបល់។ ត្រង់នេះ សូមបញ្ជាក់ ការពិតគាត់មិនបាននិយាយពីបញ្ហាថា ពីអ្វីៗដែរនោះ គាត់អត់ដែលបាននិយាយទេបាទ។ ព្រោះខ្ញុំគ្រាន់តែដឹងថា គាត់ថាបានចូលរៀនប៉ុណ្ណោះឯង។ សូមអស់យោបល់។

[០៩:៣១:១៦]

**ស៖** តើលោក សរ សារិន ហ្នឹងចូលរួមនៅក្នុងវគ្គមួយណាដែរ ឬក៏វគ្គអ្វីដែរ?

**ផ៖** គេគ្រាន់តែថា គេបានចូលរៀនវគ្គនយោបាយ។ ហើយរយៈពេលហ្នឹង បើតាមគាត់បញ្ជាក់ត្រង់ហ្នឹង គ្រាន់ថាចំនួន៦ថ្ងៃ។ សូមបញ្ជាក់បាទ។ ការពិតខ្ញុំមានតែប៉ុណ្ណឹងបាទ។

**ស៖** តើលោក សរ សារិន មានបានប្រាប់លោកអំពីអ្នកឡើងថ្លែងមតិយោបល់ ឬក៏អ្នកឧទ្ទេសនាមដែរឬទេនៅក្នុងការរៀនសូត្រនោះ?

**ផ៖** អត់មានទេបាទ។

**ស៖** តើលោក សរ សារិន មានប្រាប់ថា វគ្គរៀនសូត្រគាត់ចូលរួមហ្នឹង ធ្វើឡើងនៅពេលណាទេ?

**ផ៖** ត្រង់ហ្នឹងក៏ខ្ញុំមិនបានដឹកសួរដែរ។ គ្រាន់ គេគ្រាន់និយាយថា គេបានចូលរៀននៅវគ្គបុរីកីឡានេះឯង។ មានប៉ុណ្ណឹងបាទ។

**ស៖** តើលោកធ្វើយ៉ាងណាទើបដឹងថាលោក សរ សារិន ហ្នឹងបានចូលរួមនៅក្នុងការ -- នៅក្នុងវគ្គរៀនសូត្រនៅបុរីកីឡា? តើគាត់ជាអ្នកចាប់ផ្ដើមនិយាយអំពីវគ្គរៀនសូត្រនៅបុរីកីឡាហ្នឹង ឬមួយក៏លោកសួរគាត់អំពីវគ្គរៀនសូត្រនេះ?

[០៩:៣៣:២០]

**ឆ៖** ត្រង់ហ្នឹងបើតាមខ្ញុំចាំបាន គឺខ្ញុំទេអ្នកនិយាយថាខ្ញុំបានចូលសិក្សារៀនពេទ្យផង ហើយចូលរៀននយោបាយផងនេះ។ ការពិតទៅគាត់មិនបាននិយាយពីបញ្ហាហ្នឹង ខ្ញុំមិនបានដឹងទាល់តែសោះ។ តែក្រោយមកទេ បានដឹងតាមរយៈប្អូនខ្ញុំទេ។ ព្រោះខ្ញុំ គេថាមិត្តភក្តិគេបានចូលរៀនសាលាមែន ហើយពាក្យនេះ គឺពាក្យ សរ សារិន បញ្ជាក់ថាគេបានចូលរៀនមែន។ ហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹង។ សូមអស់បាទ។ អូ៎! លោកនេះ សួរអម្បាញ់មិញ ខ្ញុំសូមបញ្ជាក់បន្ថែមថា ពេលណា ថ្ងៃណា និយាយពីអីនោះ គឺខ្ញុំមិនបានដឹងទេបាទ។

**ស៖** តើលោកគិតថា ប្រហែល ឬក៏អាចទេ ដែលលោកចូលរួមវគ្គរៀនសូត្រជាមួយលោក សរ សារិន នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៣៤:៣២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ម្សិលមិញនោះ សំណួរសួរទៅដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺចង់ដឹងថា តើគាត់បានចូលរួមនៅវគ្គនយោបាយ ដូចគ្នាដែរឬទេ ជាមួយលោក សរ សារិន នេះ? ហើយគាត់បានឆ្លើយហើយម្សិលមិញ គាត់ថាគាត់បានចូលរួមវគ្គផ្សេងគ្នា។ ហើយសំណួរនេះសួរដដែលមកទៀត។ អ៊ីចឹងសូមជំទាស់លោកប្រធាន សំណួរដដែលៗ។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ខ្ញុំគិតថាប្រហែលជាមានការយល់ច្រឡំ ឬក៏មានការច្របូកច្របល់ពាក់ព័ន្ធទៅនឹងការបរិច្ឆេទនៃការចូលរួម ព្រោះថាលោកដើមបណ្តឹងរដ្ឋប្បវេណី គាត់អត់ដឹងថា លោក សរ សារិន ចូលរួមនៅពេលណានោះទេ។ ដូច្នេះហើយ គឺយើង -- ដូច្នេះហើយ គឺថាគាត់បាននិយាយទៅមុខថយក្រោយៗ ទាក់ទងទៅនឹងកាលបរិច្ឆេទនៃការចូលរួម។ ដូច្នេះ ខ្ញុំព្យាយាមស្វែងរកឱ្យបាននូវចម្លើយដើម្បីឱ្យចង់ដឹងឱ្យច្បាស់ ថាតើពួកគាត់ទាំងពីរនាក់ហ្នឹងបានចូលរួមនៅក្នុងវគ្គរៀនសូត្រជាមួយគ្នា ឬមួយក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងនៃសេចក្តីជំទាស់ត្រឹមត្រូវ។ សេចក្តីជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរបែបនេះទេ! សំណួរបែបនេះច្រំដែលផង សំណួរឲ្យសាក្សីឆ្លើយដោយស្មានៗផងដែរ។

[០៩:៣៦:១០]

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោក អែម អឿន តើលោក សរ សារិន គាត់មានបានប្រាប់លោកថាក្នុងវគ្គរៀនសូត្រនយោបាយនៅបុរីកីឡាហ្នឹង គឺគេមាននិយាយអំពីឈ្មោះជនក្បត់ ដូចជា កុយ ធួន ដែរឬទេ?

**លោក អែម អឿន៖**

**ឆ៖** សូមបញ្ជាក់បន្ថែម ត្រង់ណោះដូចសួរដដែលទៀត។ ខ្ញុំសុំសិទ្ធិមិនឆ្លើយបាទ។

**ប្រធានអង្គជំនុំ៖**

លោកសាក្សីមានកាតព្វកិច្ចឆ្លើយ! មានតែយើងតែដែលមានសិទ្ធិថាមិនឲ្យលោកឆ្លើយ។ លោកត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរដោយភាគី ឬក៏អង្គជំនុំជម្រះសួរទៅលោក។

យើងបានរំឭកលោកហើយ គប្បីស្តាប់សំណួរឲ្យបាន ឆ្លើយតបត្រឹមកម្រិតសំណួរដែលសួរ។ កម្រិតភាពចាំបាច់ពេញលេញទៅនឹងសំណួរដែលសួរបានហើយ ចៀសវាងនិយាយវែងឆ្ងាយ ចាកចេញផុតពីវិសាលភាពនៃបំណងនៃការតាំងសំណួរ សម្ពាធនៃបញ្ហានេះនឹងធ្លាក់ទៅលើលោក។ ដោយលោកត្រូវឆ្លើយនឹងសំណួរច្រើនរយសំណួរទៀត។ យើងបានបញ្ជាក់ច្បាស់កាលពីម្សិលមិញរួចហើយ តាំងពីដំបូងនៃដំណើរការនីតិវិធីដេញដោល។ យើងពន្យល់ពាក្យថា តាំងសំណួរដេញដោល តាមនីតិវិធីតុលាការ។

លោកត្រូវឆ្លើយតបនឹងសំណួរ! បើលោកដឹង ឆ្លើយដឹង។ លោកមិនដឹងថា មិនដឹង។ មិនមែនមិនដឹងហើយ ចេះតែស្មានទេ។

[០៩:៣៨:១៩]

**លោក អែម អឿន៖**

**ឆ៖** អរគុណលោកប្រធាន។ ត្រង់ណោះ ខ្ញុំសូមមានមតិមួយថា មូលហេតុដែលខ្ញុំសុំមិនឆ្លើយត្រង់ថា ខ្ញុំបាននិយាយរួចហើយអំមិញហ្នឹងថា រឿងរបស់គេ ខ្ញុំមិនបានដឹងទេ ខ្ញុំគ្រាន់តែដឹងថា សរ

សារិន នេះបានចូលសិក្សាមែនវគ្គនេះ។ ប៉ុន្តែមិនវគ្គជាមួយខ្ញុំទេ។ អ៊ីចឹងខ្ញុំបានបញ្ជាក់រួចហើយលោកប្រធាន។ បាទ សូមអរគុណ។

**សួរដោយលោក ហ្វាស្តេី ប៉ោះ**

**ស៖** សំណួរដែលខ្ញុំចង់សួរលោក គឺថាតើលោក សរ សារិន មានបានប្រាប់លោក ឬក៏មានបានពិភាក្សាជាមួយលោកដោយនិយាយថា ក្នុងវគ្គរៀនសូត្រដែលគាត់បានចូលរួមនោះ គឺមានបុគ្គលមួយចំនួន ដូចជា កុយ ធួន ដែលគេនិយាយថា ជាជនក្បត់នោះ។ តើលោកចាំដែរឬទេ ថាតើមានការពិភាក្សាបែបនេះ ឬក៏អត់?

**ឆ៖** សូមបញ្ជាក់ម្ចាស់សំណួរ ខ្ញុំសូមបញ្ជាក់ថា ត្រង់ដែលខ្ញុំឆ្លើយបដិសេធថាមិនដឹង អាស្រ័យដោយខ្ញុំមិនបានចាំ។ ការពិត គេនិយាយ មិនមែនថាមិននិយាយទេ ប៉ុន្តែខ្ញុំអត់ចាំមិនដឹងគេហៅអ្នកណាជាអ្នកណា។ ខ្ញុំចាំតែរឿងរបស់ខ្ញុំចាំមិនទាំងអស់ផង។ សូមអភ័យទោស បាទ។

**ស៖** ដោយសារមានពេលវេលាកំណត់ ដូច្នេះ ខ្ញុំនឹងបន្តទៅសំណួរមុខទៀត ហើយសង្ឃឹមថាប្រហែលជាសហការីខ្ញុំ គាត់នឹងអាចសួរបញ្ហានេះបន្ថែម។ លោក អែម អឿន សំណួរបន្តដែលខ្ញុំចង់ចោទសួរគឺថា ពាក់ព័ន្ធជាមួយនឹងការទំនាក់ទំនងរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ តើត្រឹមត្រូវដែរឬទេ ដែលថាលោកគឺជាអ្នកសរសេរនូវទម្រង់បែបបទព័ត៌មានជនរងគ្រោះ ដោយខ្លួនលោកនៅមជ្ឈមណ្ឌលឯកសារនាទីក្រុងភ្នំពេញនេះ?

[០៩:៤០:៣០]

**ឆ៖** បាទ សូមបញ្ជាក់ ព្រោះម្សិលមិញ ខ្ញុំបាននិយាយថា សរសេរដៃផ្ទាល់នោះគឺ ខ្ញុំជាអ្នកសរសេរ ឯបន្ថែមក្រដាសបំពេញនោះ គឺខ្ញុំពឹងលើខាងមជ្ឈមណ្ឌលជួយសរសេរ ដោយសារខ្ញុំមិនស្គាល់អក្សរពិបាកមើលផង ម្ល៉ោះហើយខ្ញុំមិនចេះផង ក៏ពឹងគាត់សរសេរបាទ។ ខ្ញុំទទួលស្គាល់ថា ខ្ញុំពឹងមែនបាទ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ តើគេបានផ្តល់នូវការជួយដល់លោក គឺគេជួយលោកនៅមជ្ឈ-មណ្ឌលឯកសារកម្ពុជា ដែលមានទីតាំងនៅទីក្រុងភ្នំពេញ ឬមួយក៏នៅទីតាំងកន្លែងផ្សេងទៀត?

**ឆ៖** ការ ដាក់បន្ថែមបំពេញ គឺបំពេញបន្ថែមនៅមជ្ឈមណ្ឌលនៅទីក្រុងភ្នំពេញ។

**ស៖** តើមានវត្តមានរបស់អ្នកតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា តែមួយរូប ឬមួយក៏មានតំណាងច្រើនរូបដែលនៅជាមួយលោកពេលនោះ?

**ឆ៖** សូមបញ្ជាក់ រឿងដើរទៅនោះថាច្រើនឬតិច ខ្ញុំមិនដឹងថា បុគ្គលណាជាមជ្ឈមណ្ឌលបុគ្គលណាមិនមជ្ឈមណ្ឌល ព្រោះខ្ញុំមិនបានស្គាល់គេ។ អ៊ីចឹងការចូលទៅសរសេរនៅក្នុងកន្លែងរបស់គាត់ គឺមានគ្នាច្រើន ប៉ុន្តែខ្ញុំមិនបានស្គាល់ថា អ្នកណាអ្នកនៅមជ្ឈមណ្ឌល អ្នកណាជាអ្នកណា អត់ស្គាល់ទេបាទ។

**ស៖** តើលោកអាចប៉ាន់ស្មានបានដែរឬទេ ថាតើលោកចំណាយពេលប្រហែលជាប៉ុន្មានម៉ោងនៅពេលដែលលោកនៅបំពេញទម្រង់បែបបទឯកសារព័ត៌មានជនរងគ្រោះ នៅមជ្ឈមណ្ឌលឯកសារនោះ។ តើលោកចំណាយពេល១ម៉ោង ឬមួយក៏៤ម៉ោង ឬមួយក៏លើសពីនេះ?

[០៩:៤២:៥៩]

**ឆ៖** សូមបញ្ជាក់បន្ថែមលោកប្រធាន ហើយលោកម្ចាស់សំណួរ ត្រង់ហ្នឹង ខ្ញុំនៅពេលខ្លីៗទេដោយសារ ខ្ញុំមានកាតព្វកិច្ចមួយគឺរត់ម៉ូតូឌុប ម្ល៉ោះហើយខ្ញុំខំរកស៊ីចិញ្ចឹមជីវិតរបស់ខ្ញុំ។ ខ្ញុំប្រាប់គាត់ថាសុំបំពេញឲ្យផង ព្រោះខ្ញុំមិនយល់ទេ បើខាងហ្នឹងយល់បំពេញឲ្យផងចាំខ្ញុំសរសេរ ស៊ីញេ និងផ្តិតមេដៃឬផ្តិតមេដៃបាទ។ ពេលវេលានោះ គឺជួបម្តងៗជួបបាន១ម៉ោង ១ម៉ោង ១ម៉ោងកន្លះ មានប៉ុណ្ណឹងឯង មិនបានវែងទេ តែគាត់ខំបំពេញខ្លួនគាត់ ទៅតាមដំណើរដែលខ្ញុំសរសេរក្នុងក្រដាសសរសេរដៃខ្លួនឯង ដែលខ្ញុំសរសេរនៅផ្ទះរបស់ខ្ញុំផ្ទាល់បាទ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ គឺលោកនិយាយថា មានមនុស្សជាច្រើនដែលដើរចេញដើរចូលនៅក្នុងមជ្ឈមណ្ឌលនោះ ប៉ុន្តែនៅពេលនោះគឺមានមនុស្សម្នាក់ ដែលលោកជាអ្នកទាក់ទងជាមួយ ឬក៏លោកប្រាស្រ័យទាក់ទងជាមួយ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំទាក់ទងតែបុគ្គលដែលខ្ញុំត្រូវពឹង ខ្ញុំមិនបានទាក់ទងអ្នកណាក្រៅហ្នឹងទេ ព្រោះខ្ញុំមិនដែលស្គាល់គេផងបាទ។ អស់យោបល់។

**ស៖** បុគ្គលដែលផ្តល់ការជួយដល់លោកហ្នឹង តើបុគ្គលហ្នឹងគាត់មានបង្ហាញរូបថត -- ឧទាហរណ៍ថា រូបថតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** អត់មានទេបាទ។ អស់យោបល់។

**ស៖** លោកបាននិយាយថា គាត់ហ្នឹង បានជួយដល់លោក តើលោកអាចជម្រាបលម្អិតបានដែរឬទេថា តើគាត់ជួយហ្នឹង គាត់ជួយអ្វីខ្លះ? តើគាត់ផ្តល់នូវការជំនួយអ្វីខ្លះដល់រូបលោក?

[០៩:៤៥:០៩]

**ឆ៖** ខ្ញុំសូមផ្តល់យោបល់ ផ្តល់ចម្លើយបានន័យថា ការជួយគឺជួយសរសេរបំពេញបន្ថែមទៅតាមដំណើររឿងដែលខ្ញុំបានសរសេរដៃស្រាប់នេះហើយ។ បាទ សូមអស់យោបល់។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ទៅលើបញ្ហានេះ តើលោកចង់និយាយថា អក្សរសរសេរដៃនៅក្នុងទម្រង់របស់លោកហ្នឹងគឺមិនមែនជាអក្សររបស់លោកទេ ប៉ុន្តែវាជាអក្សររបស់សមាជិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា?

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំអាចផ្តល់នូវឯកសារដែលបង្ហាញអក្សរសរសេរដៃហ្នឹង បើអនុញ្ញាត ដើម្បីឲ្យសាក្សី -- ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណី គាត់មានការងាយស្រួល គឺឯកសារដែលមានលេខ D22/3963។ ហើយភាសាអង់គ្លេសគឺមានលេខ 0051-- រហូតទៅដល់--

**អ្នកបកប្រែ៖**

លោកប្រធានស្នើសុំអនុញ្ញាត ឲ្យមេធាវីគាត់អាននូវលេខ ERN ម្តងទៀត។

[០៩:៤៦:២២]

**ប្រធានអង្គជំនុំ៖**

លោក ហ្សាស្តេី ប៉ោ អានលេខ ERN ម្តងទៀត ចាប់ពីលេខ ERN ហើយលោកបញ្ជាក់ម្តងទៀត ពីព្រោះអ្នកបកប្រែមិនអាចបកប្រែបានទេ។

**លោក ហ្សាស្តេី ប៉ោ៖**

គឺឯកសារដែលមានលេខ D22/3963 ហើយភាសាអង់គ្លេសមានលេខ ERN 00751861 ហើយភាសាខ្មែរគឺមានលេខ 00573967។ នេះគឺជាឯកសារដែលខាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាខាងព្រះរាជអាជ្ញាបានពិភាក្សារួចមកហើយ។ ដូច្នេះខ្ញុំគិតថាការផ្តល់ឯកសារនេះ ទៅលោកដើមបណ្តឹងរដ្ឋប្បវេណី គឺជួយឲ្យគាត់មានលក្ខណៈងាយស្រួលក្នុងការពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការពិនិត្យមើលឯកសារនេះ តើមាននៅចំពោះមុខគាត់ហើយឬនៅ? បើអត់មានទេយក -- ទទួលយកពីមេធាវីយកជូនដើមបណ្តឹងរដ្ឋប្បវេណីពិនិត្យ! ហើយរកមើលលេខ ERN ដើម្បីឲ្យគាត់ពិនិត្យផង!

[០៩:៤៧:៣៨]

*(មន្ត្រីតុលាការយកឯកសារជូនដើមបណ្តឹងរដ្ឋប្បវេណី)*

[០៩:៤៧:៥៩]

**សួរដោយលោក ហ្សាស្តេ ប៉ោះ**

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់លោក អែម អឿន ដើម្បីឲ្យខាងមន្ត្រីតុលាការជួយដល់លោកបាន គឺយើងមើលទៅលេខ 00573974 គឺជាកន្លែងដែលគេសរសេរអក្សរជាអក្សរដៃ។ ហើយសំណួរ គឺគ្រាន់តែចង់សួរលោកថាតើជាអក្សរដៃរបស់លោក ឬមួយក៏ជាអក្សររបស់បុគ្គលិក នៅមជ្ឈមណ្ឌលឯកសារកម្ពុជា?

**លោក អែម អឿន៖**

**ឆ៖** សូមឆ្លើយទៅតាមសំណួរ។ អាសរសេរដៃជាខ្មែរនេះ គឺជាអក្សរខ្ញុំផ្ទាល់តែម្តង បើសរសេរជាអង់គ្លេស ជាអីៗនោះ ខ្ញុំអត់ចេះសរសេរទេបាទ។ ហើយមួយសន្លឹកៗទីប៉ុន្មានដែលខ្ញុំបង់លេខ១១ លេខ២ នេះគឺជាអក្សរបងប្អូនដែលខ្ញុំត្រូវពឹងនេះឯង មិនមែនអក្សរខ្ញុំទេ។ តែអក្សរដែលខ្ញុំពឹងនេះ ខ្ញុំបានទទួលស្គាល់រហូតដល់ផ្តិតមេដៃ តែក្នុងចំណុចនេះដោយសារខ្ញុំមានការមមាញឹកក្នុងការរកស៊ីផង ខ្ញុំមិនបានពិនិត្យអស់ហេតុផលទេ ដូច្នេះប្រហែលជាមានខ្វះ ឬក៏ខុសត្រូវការកំណត់ខ្លះ ហ្នឹងសូមអធ្យាស្រ័យបាទ ដោយសារខ្ញុំអត់ចេះសរសេរផង ហើយក៏គ្មានពេលផងដោយសារខ្ញុំក្រ រកស៊ី ម៉្លោះហើយមិនបានផ្ទៀងផ្ទាត់ទេ សូមលោកតុលាការជ្រាបបាទ។

[០៩:៤៩:៥៤]

**ស៖** នៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ គឺទំព័រ 00573987 ដើម្បីឲ្យមន្ត្រីតុលាការអាចជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីបាន គឺមាននៅផ្នែកដែលសរសេរអក្សរដៃមួយទៀត។ ហើយដូច្នេះខ្ញុំសូមសួរសំណួរលោកទាក់ទងទៅនឹងផ្នែកនេះ ថាតើផ្នែកខាងក្រោយហ្នឹង គឺអក្សរដៃផ្នែកខាងក្រៅហ្នឹងជាអក្សរផ្ទាល់ខ្លួនរបស់លោក ឬមួយក៏យ៉ាងម៉េច?

**ឆ៖** បញ្ជាក់ម្តងសំណួរ សូមសួរម្តងទៀត។ ខ្ញុំដូចមិនទាន់ច្បាស់នៅឡើយទេបាទ។

**ស៖** ទំព័រដែលលោកត្រូវពិនិត្យមើលគឺលេខ 00573987។ គឺជាផ្នែកដែលមានអក្សរសរសេរដៃទៀត ហើយផ្នែកនេះគឺភ្ជាប់ជាមួយនឹងទម្រង់បែបបទព័ត៌មានជនរងគ្រោះដែលត្រូវផ្តល់បន្ថែម។ ខ្ញុំចង់ឲ្យលោកជម្រាបយើងថាតើអក្សរនៅផ្នែកនេះ គឺជាអក្សរដៃរបស់លោក ឬមួយក៏អក្សររបស់អ្នកដទៃ?

[០៩:៥១:២៩]

**ឆ៖** ម្ចាស់សំណួរសូមពិនិត្យមើលហេតុផល អក្សរខ្ញុំ និងអក្សរបន្ថែមជួយនេះ គឺអក្សរផ្សេងគ្នាទេ ព្រោះខ្ញុំអត់ដូច សរសេរអត់ដូចគ្នាទេបាទ។ អ៊ីចឹងគឺជាអក្សរមនុស្សដែលខ្ញុំពឹងនេះឯង មិនមែនជាអក្សរខ្ញុំទេ អក្សរបន្ថែមនេះ។ បើអក្សរដែពិតជាអក្សរខ្ញុំ ប៉ុន្តែសាច់រឿងអ្នកបន្ថែម ខ្ញុំបានមើល មើលហេតុផលទៅគឺជារឿងរបស់ខ្ញុំផ្ទាល់តែម្តងបាទ។ សូមអស់យោបល់។

**ស៖** ដូច្នេះ ទម្រង់ព័ត៌មានជនរងគ្រោះរបស់លោក គឺចុះនៅថ្ងៃ២៩ ខែមករា ២០១០ គឺរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តើមែនទេ? អានេះគឺជាអ្វីដែលយើងមើលទៅលើទម្រង់បែបបទ។ ចំណែកទម្រង់បែបបទបន្ថែម គឺចុះនៅថ្ងៃ២៣ ខែមីនា ឆ្នាំ២០១០។ គឺផ្តល់ឲ្យនូវប្រហែលជា២ខែក្រោយ។ តើលោកអាចជម្រាបបានដែរឬទេ ហេតុអ្វីបានជាលោកផ្តល់នូវព័ត៌មានបន្ថែមប្រហែលជា២ខែក្រោយមកទៀតនោះ?

**ឆ៖** សូមបញ្ជាក់ត្រង់ហ្នឹង ខ្ញុំបានជម្រាបរួចហើយថា នៅពេលដែលខ្ញុំពឹងគាត់ ខ្ញុំមិនបាននៅជាមួយគាត់ទេ។ គាត់គ្រាន់ដកស្រង់ពាក្យដែលខ្ញុំសរសេរដៃផ្ទាល់យកទៅបំពេញបន្ថែម ទាំងពីស្រុកកំណើត ទាំងពីអីទាំងអស់នោះ គឺគាត់ដាក់បំពេញបន្ថែមទៅតាមការចម្លងចេញអំពីសរសេរដៃរបស់ខ្ញុំផ្ទាល់តែម្តងថា ការពិតទៅមូលហេតុដែលយូរដោយសារខ្ញុំនៅជនបទ ឯគាត់អ្នកខ្ញុំពឹងនេះ គឺគាត់នៅមជ្ឈមបណ្ឌល។ ម្ល៉ោះហើយការសួរយោបល់ ក៏គាត់មិនបានសួរខ្ញុំដែរ ឯខ្ញុំក៏បានផ្តល់ដែរ គ្រាន់សរសេរទុកក្រដាសស្នាមដែលខ្ញុំសរសេរផ្ទាល់ដៃ សូមឲ្យគាត់ដកស្រង់ចេញវិញចុះ។ អ៊ីចឹងការដកនេះ ខ្ញុំសូមសារភាពទុកជាមុនថា ខ្ញុំមិនបានពិនិត្យអស់ទេ សាច់រឿង ព្រោះមូលហេតុសរសេរអក្សរគាត់តូចផងភ្នែកងងឹតផង ខ្ញុំដើររកស៊ីទៅខ្វះវ៉ែនតា ខ្វះអីអ៊ីចឹង ខ្ញុំពិនិត្យមិនអស់ យល់ឃើញថាអ្វីក៏ដោយដែលកើតឡើងនៅក្នុងសាច់រឿងនេះ គឺខ្ញុំជាអ្នកទទួលខុសត្រូវ។

[០៩:៥៣:៤៦]

ដូច្នេះ ថ្ងៃនេះ ខ្ញុំសូមបញ្ជាក់ហេតុផលថា អ្វីដែលខ្ញុំនិយាយមិនមែនរឿងបដិសេធ ហើយមិនមែនរឿងមិនទទួលស្គាល់នោះទេ គឺការពិត ខ្ញុំបាន១ទទួលស្គាល់រហូតដល់មានស្នាមមេដៃ ដែលខ្ញុំផ្តិតជាប់នូវពាក្យនៅកន្លែង នៅក្រដាសដែលគាត់សរសេរហ្នឹង។ សូមជម្រាប សូមអស់យោបល់ហើយ។

**ស៖** លោក អែម អឿន ខ្ញុំមិនប្រាដកថាខ្ញុំយល់ច្បាស់នូវអ្វីដែលលោកចង់បញ្ជាក់ទេ។ ដូច្នេះដើម្បីបញ្ជាក់ឲ្យលម្អិត គឺខ្ញុំសូមផ្តល់នូវពេលវេលាបន្តិច គឺនៅគម្លាតពេលវេលាបន្តិច គឺថាខ្ញុំចង់បញ្ជាក់

លោកទៅលើបញ្ហានេះ។ នៅថ្ងៃ២៥ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ គឺលោកផ្តល់នូវទម្រង់បែបបទព័ត៍មានជនរងគ្រោះ ហើយលោកបានបញ្ជាក់ថា ទម្រង់ហ្នឹងគឺសរសេរដោយខ្លួនលោក ហើយបី-បួនថ្ងៃក្រោយមក គឺនៅថ្ងៃ២៩ មករា ឆ្នាំ២០១០ គឺលោកបានទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយផ្តល់នូវចម្លើយដែលមាន -- ចម្លើយយ៉ាងវែង ហើយដែលលោកនិយាយថា នៅថ្ងៃនេះ ថាវាជាអក្សរដៃរបស់លោក ហើយបន្ទាប់មកទៀត គឺក្រោយហ្នឹង២ខែ គឺគម្លាតគ្នា២ខែក្រោយមក លោកបានផ្តល់នូវព័ត៍មានបន្ថែម គឺចុះនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០។ អ្វីដែលខ្ញុំចង់សួរលោក គឺថា ហេតុអ្វីបានជាលោកផ្តល់ព័ត៍មានបន្ថែម២ខែក្រោយមកទៀត? ថាតើដោយសារតែមានអ្នកណាម្នាក់ ស្នើសុំឲ្យលោកផ្តល់នូវព័ត៍មានបន្ថែម ឬមួយក៏លោកធ្វើដោយខ្លួនលោកផ្ទាល់ គឺលោកគិតដោយខ្លួនឯងផ្ទាល់ ដែលថាត្រូវផ្តល់ព័ត៍មានបន្ថែមនេះ?

[០៩:៥៦:០៧]

**ឆ៖** សូមឆ្លើយទឹងសំណួរ។ ត្រង់នេះខ្ញុំបានបញ្ជាក់ហើយថា ការសរសេររបស់ខ្ញុំមានពេលខ្លីណាស់។ អ៊ីចឹងអាដាក់មុននោះ ដល់ខ្ញុំពិចារណាហេតុផលមើលទៅនៅខ្វះពាក្យខ្លះ បានខ្ញុំសរសេរបំពេញបន្ថែម។ អានេះឯងហើយ ដែលធ្វើឲ្យគាត់ -- ធ្វើអាពាក្យគឺថា អ្នកថែមនេះ វាមើលទៅដូច -- មើលទៅពីរគន្លាក់ ពីរដង។ ហើយការពិត ពីរដងពិតជារឿងពិតអ៊ីចឹងមែន។ ព្រោះខ្ញុំបាននិយាយថា អ្វីដែលខ្វះខាតខ្ញុំសូមបន្ថែម ដូច្នេះសូមអ្នកដែលជួយនោះ មេត្តាជួយសរសេរបំពេញបន្ថែមទៀតផងបាទ។ ខ្ញុំពឹងផ្អែកលើមជ្ឈមណ្ឌល ព្រោះខ្ញុំមិនដឹងធ្វើការឯណាទេ កាលណាខ្ញុំធ្វើខុសពីហ្នឹង ពឹងក្រៅពីហ្នឹង រឺវរថាខ្ញុំជឿគេជឿឯង។ សូមម្ចាស់សំណួរជ្រាបបាទ។

**ស៖** តើបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាគាត់មាននិយាយអំពីបុរីកីឡាដែរឬទេ? គឺថាគាត់មាននិយាយអំពីវគ្គរៀនសូត្រនៅបុរីកីឡាជាមួយលោកដែរឬទេ?

[០៩:៥៧:១៨]

**ឆ៖** ត្រង់នេះគាត់អ្នកសរសេរមិនទាំងស្គាល់ថា មិនទាំងដឹងថា នៅបុរីកីឡាជំនាន់នោះមានសាលានយោបាយទេ ដូច្នេះគាត់អត់ស្គាល់ទេ។ ហើយខ្ញុំក៏មិនបានសួរព័ត៍មានអីពីគាត់ដែរបាទ។ សូមអស់។

**ស៖** ដើម្បីទទួលបាននូវព័ត៍មានច្បាស់លាស់ នៅពេលដែលលោកមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា តើលោកមានយកនូវទម្រង់បែបបទព័ត៍មានជនរងគ្រោះ គឺទម្រង់បែបបទព័ត៍មានជនរងគ្រោះ

ទី១ នៅថ្ងៃ២៥ មករា មកមជ្ឈមណ្ឌលឯកសារកម្ពុជានេះទេ?

**ឆ៖** សូមសួរសាថ្មី ស្តាប់អត់បានបាទ។

[០៩:៥៨:១៦]

**ស៖** នៅពេលដែលលោកទៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃ២៩ មករា ២០១០ តើលោកមានយកនូវទម្រង់បែបបទព័ត៌មាន ដែលលោកបានរៀបចំនៅថ្ងៃទី២៥ មករា ២០១០ គឺខ្ញុំចង់និយាយពីទម្រង់បែបបទព័ត៌មានទី១ តើលោកមានយកទម្រង់ហ្នឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាទេ?

**ឆ៖** សូមនិយាយថែមបន្តសាច់រឿង ព្រោះថាហេតុផលទាំងអស់នេះ ខ្ញុំបានគ្រាន់តែបានសាកសួរនៅមជ្ឈមណ្ឌលថា ការធ្វើនេះធ្វើយ៉ាងម៉េចៗ? ហើយមជ្ឈមណ្ឌលបានណែនាំខ្ញុំថា អ្នកសរសេរបើមានការឈឺចាប់លើ -- បើអ៊ំមានការរងគ្រោះ សូមអ៊ំយកទម្រង់ដែលៗជាសំណុំបែបបទរបស់មជ្ឈ-មណ្ឌលចុះ តែការចម្លងឃើញយករបស់គេរបស់អីទៅមើល ខ្ញុំអត់មើលទេបាទ។ ព្រោះផែនការរបស់គេ គឺរឿងរបស់គេ ប្រវត្តិរូបខ្ញុំគឺរឿងរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំមិនចម្លងរបស់គេទេបាទ។ ព្រោះខ្ញុំមុននឹងនិយាយនេះ សូមសច្ចាសច្ចារួចថា ខ្ញុំៗសូមនិយាយតែរឿងពិត។ ហ្នឹងសូមម្ចាស់សំណួរជ្រាបបាទ។

[០៩:៥៩:៣៨]

**ស៖** ខ្ញុំចង់និយាយអំពីបុគ្គលិកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺខ្ញុំនិយាយអំពីទម្រង់បែបបទព័ត៌មានជនរងគ្រោះ ហើយលោកនិយាយថា លោកជួបជាមួយ សរៗ -- យារ សារុន និង ខៀវ សំណាញ។ តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេ ថាតើបុគ្គលទាំងពីររូបនេះជាអ្នកណា? ហើយគាត់ជាអ្វីដែរ?

**ឆ៖** ខ្ញុំបញ្ជាក់បន្ថែមលើសំណួរព្រោះថា ខ្ញុំមិនដែលជួប ខៀវ សំណាញ ណាទេ អត់ដឹងទេ។ តែ យារ សារុន ជួប។ ត្រង់នោះខ្ញុំបានដាក់ថា "អ្នកនោះដឹងឮអំពីសកម្មភាពរបស់ឪពុកខ្ញុំមានសរសេរ"។ ប៉ុន្តែការ ថា ខៀវ សំណាញ ណាអត់ស្គាល់ទេបាទ។ សូមជ្រាប។

**ស៖** គឺ ខ្ញុំចង់និយាយអំពី យារ សារុន តើ យារ សារុន ហ្នឹងគឺជាអ្នកណា? ហើយតើគាត់មានព័ត៌មានពាក់ព័ន្ធអ្វីដែលអាចជួយបង្ហាញអំពីឧក្រិដ្ឋកម្មឬក៏បទល្មើសដែលលោកបានឃើញ?

**ឆ៖** ឆ្លើយសំណួរនេះ គឺបើសិនជាលោកនិយាយទៅ មានការពាក់ព័ន្ធវែងឆ្ងាយណាស់ ព្រោះ យារ សារុន នេះ ជាគណៈកម្មាភិបាលរបស់បដិវត្តន៍សម័យនោះនៅតំបន់២០។ អ៊ីចឹងគាត់ត្រូវជាបងជីដូនមួយរបស់ខ្ញុំ។ អ៊ីចឹងគាត់អាចប្រាប់ថា ឪពុកខ្ញុំយ៉ាងម៉េចៗ គឺតាមរយៈគាត់ក៏បានដែរ។ បើសិនជា

អស់លោកចង់ដឹងព័ត៌មានពិត ព្រោះឥឡូវនេះគាត់នៅរស់នៅឡើយ នៅស្រុកកំណើតរបស់ខ្ញុំបាទ។

[១០:០១:៥៤]

**ស៖** ខ្ញុំនឹងសួរបញ្ជាក់ទៅលើចំណុចនេះដែលបានបកប្រែឱ្យខ្ញុំស្តាប់នេះឡើយវិញ ហើយដោយសារពេលវេលា ខ្ញុំសូមបន្តទៅមុខទៀត។ តើលោកចាំទេ នៅពេលណាដែលលោករត់ចូលព្រៃនោះ? តើលោកចាំឆ្នាំទេ ឆ្នាំណាដែរ?

**ឆ៖** សូមសួរបន្ថែម រត់ចូលព្រៃ ព្រោះខ្ញុំរត់ច្រើនដង។ ដូច្នេះជំនាន់ណាបាទ? សម័យណា? សូមបំភ្លឺយោបល់បន្ថែមបាទ។

**ស៖** តើលោកអាចពន្យល់ជារួមលើពេលវេលាដែលលោករត់ចូលព្រៃដែរឬទេ? ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។ តើលោកជួយពន្យល់ជារួមបានដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមបំភ្លឺ មិនមែនសូមបំភ្លឺទេ សូមនិយាយរឿងពិតរបស់ខ្ញុំរត់ចូលព្រៃនៅសម័យនោះ គឺរត់នៅឆ្នាំ៧៨ ចេញពីតំបន់២០។ មូលហេតុដែលៗខ្ញុំរត់ អាស្រ័យដោយខ្ញុំនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា មើលទៅការលំបាក ការរស់នៅរបស់ខ្ញុំពិបាកណាស់ ស្ទើរងាប់ស្ទើររស់។ ដូច្នេះខ្ញុំពីរនាក់ប្តីប្រពន្ធក៏ដឹកដៃគ្នាចេញពីកន្លែងធ្វើការ ក៏រត់ចូលក្នុងព្រៃ ព្រៃនោះក៏មិនទាន់មានអ្នកណាបង្កើតវិធាន -- បង្កើតចលនាប្រឆាំង ប៉ុល ពត ទេ គឺមានតែខ្ញុំជាមួយប្រពន្ធខ្ញុំដំបូង គឺរស់នៅក្នុងព្រៃដូចសត្វទន្សាយ និងសត្វឈ្លូស។ បានស៊ីៗស្លឹកឈើផង ស៊ីគល់អាគល់ផ្គាវផង អីផង ទម្រាំតែនឹងបានរស់។

[១០:០៣:៥៧]

ក្រោយមកទៀត បានមានចលនាបងប្អូនចេះតែរត់ទៅៗ ម្ល៉ោះប្រមូលគ្នានៅក្នុងព្រៃរហូត គឺខ្ញុំៗរត់ក្នុងឆ្នាំ -- ដើមឆ្នាំ៧៨ បាទ។

**ស៖** លោកបាននិយាយថា លោករត់ចូលព្រៃនៅក្នុងឆ្នាំ១៩៧៨ តើលោកអាចបញ្ជាក់ឱ្យបានច្បាស់ជាងនេះដែរឬទេ តើក្នុងខែណាដែរ? ក្នុងខែណាដែរ ក្នុងឆ្នាំ៧៨នោះ?

**ឆ៖** ត្រង់ហ្នឹងសូមទោស ខ្ញុំមិនបានចាំថ្ងៃណាៗទេបាទ។

**ស៖** តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានដែរឬទេ? តើលោកប្រាកដទេ ថាក្នុងឆ្នាំ៧៨នោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ការប្រាកដ គឺពិតជា ៧៨ ប៉ុន្តែខែទេដែលខ្ញុំមិនដឹងថាខែណា គ្រាន់តែដឹងថាៗ ខ្ញុំរត់នោះនៅពេលខែពិសាខ ទឹកច្រើន ខ្ញុំរត់កាត់ទឹកបាទ។ ដល់នឹកឃើញប៉ុណ្ណឹង អារម្មណ៍ពេល

នោះ គឺនឹកឃើញខ្ញុំរត់កាត់ទឹក។ តែខែនោះ ជាខែណាៗ ខ្ញុំមិនដឹងទេ គឺបានដឹងថា ខែភ្លៀងដំបូង គឺខ្ញុំរត់កាត់ទឹក ដើម្បីចូលព្រៃ គឺរត់កាត់ព្រៃ កាត់ត្រែង គឺមានទឹក មានភក់បាទ។ ត្រង់ហ្នឹងខ្ញុំមិនបានចាំបានថា ខែណា ឬជាខែណានោះទេ? គឺខ្ញុំខំដោះស្រាយជីវិត។ ហើយការចាំបាននោះ ចាំបានក្រោយមកទេ យូរណាស់មកហើយបាននឹកឃើញថា ខ្ញុំរត់ខែណា? ខែណា បាននឹកឃើញថា អូ៎ ខ្ញុំរត់ខែដែលមានទឹកដំបូង។ នេះសូមជ្រាបបាទ។

[១០:០៦:០៥]

**ស៖** នៅក្នុងចម្លើយ នៅក្នុងពាក្យសុំព័ត៌មានជនរងគ្រោះដែលលោកផ្ដល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានបញ្ជាក់ថា លោកចាកចេញពីតំបន់២០ ពីស្រុកកំចាយមារ ខេត្តព្រៃវែងនោះ គឺនៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំនឹងបង្ហាញទំព័រជាឯកសារក្រដាស ដើម្បីឲ្យខាងមន្ត្រីតុលាការនោះជួយផ្ដល់បញ្ជាក់ជូនលោក។ ខ្មែរ 00573981, ERN ជាភាសាអង់គ្លេសគឺ 00751868 ខ្ញុំនឹងទុកពេលឲ្យលោកខ្លះ ហើយលោកមើលទៅលើចំណុចដែលខ្ញុំអានអម្បាញ់មិញនេះ ដែលថា “ខ្ញុំរត់ចេញពីមន្ទីរពេទ្យតំបន់២០ តាំងពីភូមិជោរ ឃុំគ្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង នៅឆ្នាំ១៩៧៧”។

**ឆ៖** ខ្ញុំ--

**ស៖** សូមអធ្យាស្រ័យ លោកបន្តឆ្លើយទៀតបានលោក។

**ឆ៖** ខ្ញុំសូមបញ្ជាក់សាច់រឿង ដូចខ្ញុំនិយាយអំមិញហើយថា ការទទួលស្គាល់ ការកើតឡើងនៃរឿងរ៉ាវរត់ចូលនោះ មិនមែនជារឿង ខ្ញុំនិយាយឲ្យពីរោះស្ដាប់នោះទេ។ ប៉ុន្តែខ្ញុំបានសារភាពមុនថា ខ្ញុំមិនអាចចាំពេលវេលាកំណត់បាននោះទេ គ្រាន់តែដឹងថាមានទឹក មានភក់ នៅពេលដែលខ្ញុំរត់។ តែទឹកភក់នៅក្នុងខែណា ឬខែណានោះ ខ្ញុំមិនបានចាំទេ ព្រោះថាឧបទ្ទវហេតុនេះ គឺខ្ញុំធ្វើម៉េចគេចឲ្យផុត ពួនឲ្យបាន។ អីចឹងការរត់ឆ្លងកាត់នោះ គឺជាការមួយរត់ដោយលំបាកណាស់។ ដូច្នេះការចងចាំ គ្រាន់តែដឹងថា រត់កាត់ទឹកប៉ុណ្ណោះឯង។ ប៉ុន្តែគ្រាន់តែថា ក្នុងនោះ ឆ្នាំណា? ឬខែឆ្នាំណា ក្នុងខែណានោះ? សូមអភ័យទោស ខ្ញុំសូមអធ្យាស្រ័យ។ ព្រោះថាការលំបាករបស់មនុស្ស មុននឹងងាប់ត្រូវតែរត់ ទោះបីខែណាក៏ដោយ ឆ្នាំណាក៏ដោយ មិនបានដឹងទេ។ ដល់តែយើងមកចងចាំ រិះរកការរត់របស់យើងនោះ ប្រហែលជាមានការខុស។ ហ្នឹងសូម សូមប្រើពាក្យប្រហែលចុះ ប្រហែលជាមានការខុស អាស្រ័យដោយចាំមិនបានអស់។ អាហ្នឹងសូមទទួលស្គាល់បាទ។

[១០:០៨:៤៥]

**ស៖** លោក អែម អឿន ខ្ញុំដឹងថាវាពិបាកឲ្យលោកនឹកកាលបរិច្ឆេទថ្ងៃខែឡើងវិញ។ ក៏ប៉ុន្តែ ចំពោះយើងខ្ញុំនេះ ថ្ងៃខែកាលបរិច្ឆេទនេះ គឺសំខាន់ណាស់។ តើត្រឹមត្រូវដែរឬទេ ដែលថា លោកមិនចាំទេ លោកមិនចាំប្រាកដទេថា លោករត់ចូលព្រៃនោះ មិនដឹងឆ្នាំ៧៧ ឬក៏៧៨នោះទេនោះ? តើអ៊ីចឹងដែរ ឬទេ?

**ឆ៖** បាទ អរគុណ។ បើចំណុចនេះ ខ្ញុំសូមទទួលស្គាល់ ព្រោះខ្ញុំពិចារណាទៅ ខ្ញុំសរសេរហ្នឹង មានខែ៧ ខែ៨។ ហើយខែ៧ ខ្ញុំនៅទីក្រុងភ្នំពេញ។ ដល់ខែ៧ ខ្ញុំសរសេរថា ខ្ញុំរត់ចេញពីហ្នឹងទៅចូលព្រៃ។ មើលទៅ ការខុស ខុសមែនក្នុងសាច់រឿង។ ដូច្នេះខ្ញុំពិចារណាមើលទៅ ប្រហែលជាខ្ញុំកំណត់ខុស នៅពេលដែលសរសេរនោះឯង។ ដោយសារការនឹក យល់ទៅ នឹករកមិនអស់។ ការសរសេរទៅ ប្រហែលជាខុសមែន សាច់ហ្នឹង។ អ៊ីចឹងខ្ញុំសូមទទួលស្គាល់រឿងមួយថា អ្វីក៏ដោយដែលខ្ញុំរៀបរាប់នេះ គឺជាការពិតរបស់ខ្ញុំ។ ខ្ញុំចងចាំតែរឿងពិតរបស់ខ្ញុំទេ ឯពេលវេលាកំណត់ពេលវេលានោះ ខ្ញុំមិនបានចងចាំថា ឲ្យប្រាកដត្រង់ណា ឲ្យច្បាស់នោះទេ។ សូមអធ្យាស្រ័យបាទ។

**ស៖** សូមអរគុណលោក អែម អឿន។ នៅក្នុងឯកសារដដែលនេះ គឺទម្រង់បែបបទព័ត៌មានជនរងគ្រោះ ដែលលោកបានដាក់ជូនទៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺលោកបាននិយាយថា “នៅក្នុងឆ្នាំ៧៥ គឺគេចាត់តាំងឲ្យខ្ញុំធ្វើការងារជាពេទ្យ ទោះបីជាខ្ញុំមិនមានបទពិសោធន៍ខាងពេទ្យក៏ដោយ”។ ទំព័រខ្មែរ 00573976, ERN ជាភាសាអង់គ្លេស 00751867។

**លោក ហ្សាស្តេី ប៉ោ៖**

មន្ត្រីតុលាការសូមជួយរកទំព័រឲ្យគាត់ផង។

[១០:១១:២៥]

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ខ្ញុំទុកពេលឲ្យលោកមើល ហើយឲ្យលោកផ្តល់យោបល់ទៅលើប្រយោគ ដែលសរសេរបែបនេះនៅក្នុងឯកសារហ្នឹង។ កាលពីសប្តាហ៍មុន លោកបាននិយាយបញ្ជាក់ឆ្លើយយ៉ាងលម្អិត អំពីការបណ្តុះបណ្តាលផ្នែកពេទ្យ ដែលលោកទទួលតាំងពីក្មេងមករហូត។ ដូច្នេះ សំណួររបស់ខ្ញុំនោះ គឺចង់សួរថា តើត្រឹមត្រូវដែរឬទេ អ្វីដែលលោកសរសេរនៅក្នុងប្រវត្តិរូប ទម្រង់បែបបទជនរងគ្រោះ ដែលលោកផ្តល់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺថា លោកមិនមានប្រវត្តិបទពិសោធន៍ខាងពេទ្យនោះទេ ហើយវាផ្ទុយទៅនឹងដែល ចំណុចដែលលោកលើកឡើងថា លោកទទួលការបណ្តុះបណ្តាលផ្នែកពេទ្យ

នេះតាំងពីតូចមករហូតនោះ?

**លោក អែម អឿន៖**

**ឆ៖** ត្រង់នេះ ខ្ញុំសូមបញ្ជាក់មុននឹងនិយាយបន្ត ខ្ញុំសូមបញ្ជាក់ថា មូលហេតុដែលខ្ញុំប្រើពាក្យថា ខ្ញុំធ្វើទាំងមិនចេះ មិនដឹង ដោយសារវិជ្ជាទាំងអស់នេះ ខ្ញុំប្រឹងដោយខ្លួនឯង គ្មានអ្នកណាតែងតាំងថា ធ្វើអីៗ មានសញ្ញាបត្រអីនោះទេ។ ដូច្នេះ ក្របខ័ណ្ឌដែលខ្ញុំដាក់ -- ក្របខ័ណ្ឌជាមនុស្ស យើងត្រូវទទួលស្គាល់ខ្លួនឯងថា អ្វីដែលយើងចេះនោះ មិនមែនជាលក្ខណៈក្របខ័ណ្ឌទទួលស្គាល់ពីរដ្ឋទេ។ ដូច្នេះឯង ហើយដែលខ្ញុំប្រើពាក្យថា ខ្ញុំចេះទាំងងងឹតងងុល។ ដូច្នេះ សូមម្ចាស់សំណួរយល់ពីដំណើរដែលខ្ញុំបានសរសេរដាក់ក្នុងៗព័ត៌មាននេះ សូមលោកជ្រាបបាទ។

[១០:១៣:១១]

**សៈ** សូមអរគុណ។ ចំណុចនេះ គឺបង្ហាញច្បាស់ហើយ កាលពីម្សិលមិញ លោកបានឆ្លើយអំពីថ្នាំ -- អំពីឡាន (កែតម្រូវ) ឡានដែលបានបើកមកដឹកមនុស្សចេញពីពេទ្យទៅ។ ខ្ញុំសូមដកស្រង់ប្រតិចារឹក គឺត្រង់ទំព័រ១៩ និង២០ ជាភាសាអង់គ្លេស។ ខ្ញុំអត់មានទំព័រជាភាសាខ្មែរនៅក្នុងប្រតិចារឹកនោះទេ ក៏ប៉ុន្តែខ្ញុំអាចផ្តល់ជូនទំព័រជាភាសាខ្មែរបានក្នុងពេលឈប់សម្រាក។ ខ្ញុំសូមដកស្រង់សម្តីលោកឆ្លើយ គេបានសួរលោក -- ភាគីបានសួរលោកកាលពីម្សិលមិញ សួរថា "តើលោកអាចនិយាយបន្ថែមទៅលើចំណុចនេះបានដែរឬទេ ខ្ញុំចង់ដឹងថាតើមានឡានបញ្ជូនមកពីខាងសង្គមកិច្ច ឬក៏ខាងសុខាភិបាលនោះ មានបញ្ជូនមកមន្ទីរពេទ្យនេះដែរឬទេ ឬក៏ឡាននោះជាឡានរបស់មន្ទីរពេទ្យតែម្តង ដែលឡាននោះមកដឹកមនុស្សចេញពីមន្ទីរពេទ្យទៅ?" គេសួរលោកដូច្នេះ គឺសំណួរពីខាងសហព្រះរាជអាជ្ញា។ លោកបានឆ្លើយដូចតទៅ "ការពិតទៅ ខ្ញុំមិនដែលឃើញផ្ទាល់ភ្នែក ឃើញឡានមកដឹកមនុស្សដែលគេចាប់ខ្លួននោះទេ។ ជាធម្មតាឡានពេទ្យ វានៅ វាបិទជិត ខ្ញុំមើលមិនឃើញនោះទេ ក៏ប៉ុន្តែខ្ញុំមិនដែល ឃើញឡានមកពីក្រៅមកដឹកមនុស្សពីមន្ទីរពេទ្យនោះទេ"។ បញ្ចប់ការដកស្រង់សម្តីពីប្រតិចារឹក។ កាលពីម្សិលមិញ លោកបានឆ្លើយនៅក្នុងតុលាការថា "លោកមិនដែលឃើញផ្ទាល់ភ្នែកខ្លួនឯង មិនដែលឃើញឡាន មកដឹកមនុស្សចេញពីពេទ្យនោះទេ គឺមកដឹកមនុស្សដែលគេចាប់បាននោះ"។ តើលោកនៅតែរក្សាសម្តីនេះដដែលដែរឬទេ ដែលថា លោកមិនដែលឃើញផ្ទាល់ភ្នែក ឡានមកដឹកមនុស្សដែលគេចាប់បាននៅមន្ទីរពេទ្យនោះទេ តើអីចឹងដែរទេ? លោកនៅរក្សាសម្តីនេះដែរឬទេ?

[១០:១៥:២៥]

**ឆ៖** ខ្ញុំសូមរក្សាសម្ដីណាដែលខ្ញុំនិយាយ សម្ដីណាដែលពិត គឺខ្ញុំសូមរក្សា ប៉ុន្តែក្នុងនោះខ្ញុំបាននិយាយពីរសំឡេង។ សំឡេងទី១ ខ្ញុំមិនបានឃើញឡានទោះដឹកចេញពី -- ឡានពេទ្យដឹកមនុស្សចេញពីមន្ទីរពេទ្យទេដោយអាស្រ័យដោយឡានពេទ្យនោះ ឃ្លុំជិត នោះគឺជាពាក្យសម្ដីពិតរបស់ខ្ញុំ។ ហើយក្នុងនោះដែរ ខ្ញុំបានបញ្ជាក់ថា ឃើញដឹកមនុស្សចេញមានតែឡានទាហាន។ អ៊ីចឹងខ្ញុំសូមរក្សាពាក្យពិតនេះទុក។ បាទ សូមទទួលស្គាល់បាទ។

**ស៖** សូមអធ្យាស្រ័យ ខ្ញុំដូចជាមិនយល់ចម្លើយចុងក្រោយរបស់លោក។ លោកបានឆ្លើយថា លោកមិនបានឃើញគេដឹកមនុស្សតាមឡានពេទ្យនោះទេ ក៏ប៉ុន្តែលោកបានឃើញឡានទាហាននោះ គេមកដឹកមនុស្សចេញទៅ តើអ៊ីចឹងដែរឬទេ? លោកឆ្លើយអ៊ីចឹងទេ?

[១០:១៦:៣៦]

**ឆ៖** ហ្នឹងខ្ញុំបានបញ្ជាក់អំមិញហើយថា ខ្ញុំមិនបានឃើញឡានពេទ្យដឹកមនុស្សចេញពីមន្ទីរពេទ្យទេ តែខ្ញុំឃើញឡានទាហានដឹកមនុស្សចេញពីមន្ទីរពេទ្យ នោះគឺជាពាក្យពិតរបស់ខ្ញុំបាទ។

**ស៖** ប្រហែលជាបញ្ហាបកប្រែនៅក្នុងប្រតិចារឹកដែលខ្ញុំលើកឡើងនោះ ក៏ប៉ុន្តែខ្ញុំនឹងធ្វើការផ្ទៀងផ្ទាត់ក្នុងពេលឈប់សម្រាក។ កាលពីម្សិលមិញនៅក្នុងប្រតិចារឹកជាភាសាអង់គ្លេសនោះ លោកបានឆ្លើយថា "ខ្ញុំមិនដែលឃើញផ្ទាល់ភ្នែកឡានទាហានមកដឹកមនុស្ស ដែលបានចាប់ខ្លួនពីមន្ទីរពេទ្យនេះទៅទេ"។ ក៏ប៉ុន្តែខ្ញុំនឹងពិនិត្យមើលទៅលើប្រតិចារឹកនេះឡើងវិញ ជាមួយនឹងសហមេធាវីជាតិរបស់ខ្ញុំនៅក្នុងភាសាខ្មែរ ដើម្បីផ្ទៀងផ្ទាត់ទៅលើចំណុចនេះ ហើយខ្ញុំនឹងសួរសំណួរ និងលើកឡើងបញ្ហានេះបញ្ជាក់ឲ្យច្បាស់ឡើងវិញ។ កាលពីម្សិលមិញលោកបានបញ្ជាក់ឈ្មោះបុគ្គលម្នាក់ តើលោកបញ្ជាក់ទេតួនាទីរបស់គាត់នោះជាអ្វី?

[១០:១៧:៥៩]

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេបញ្ជាក់ឈ្មោះឡើងវិញ គាត់មិនបានបញ្ជាក់ច្បាស់លាស់ឈ្មោះនោះ។

**លោក ហ្វាស្តើ ប៉ោ៖**

លោកប្រធាន ខ្ញុំអត់ឮចម្លើយនោះទេ។

**សួរដោយលោក ហ្វាស្តើ ប៉ោ៖**

**ស៖** លោកសាក្សី តើលោក ជួន ជឿន នេះតើតួនាទីរបស់គាត់ធ្វើអ្វីដែរ?

**លោក អែម អឿន៖**

**ឆ៖** លោក ជួន ជឿន សម័យដែលខ្ញុំរៀនសូត្រនោះ គាត់ជាប្រធានបច្ចេកទេសនៅក្នុងក្រសួងសុខាភិបាល បាទ។

[១០:១៩:០៩]

**ស៖** តើគាត់ផ្តល់វគ្គអប់រំអ្វីខ្លះជូនលោកនោះ?

**ឆ៖** លោក ជួន ជឿន នៅពេលនោះតាមខ្ញុំចាំបាន គាត់មិនសូវប្រើប្រាស់ពាក្យនយោបាយទេ គាត់ចូលចិត្តដឹកដៃសិស្សទៅមើលជំងឺផ្ទាល់ៗ គាត់មិនសូវបង្រៀនតាមទ្រឹស្តីទេ តា ជួន ជឿន នេះគាត់ភាគច្រើនដឹកដៃសិស្សទៅមើលពេលដែលគាត់នាំធ្វើការមើលពិនិត្យពេទ្យ -- ពិនិត្យជំងឺពិនិត្យអីទាំងអស់ គឺគាត់ជាណែនាំដឹកដៃពេទ្យ នាំពេទ្យដែលទៅរៀននេះ គាត់ធ្វើមើលរូបភាពពិតៗ។ គាត់មិនសូវបាន -- គាត់មិនដែលបានចូលសាលានិយាយអំពីបច្ចេកទេសនេះ បច្ចេកទេសនោះ អត់ទេ គឺគាត់មានតែឯកសារយកមកឲ្យសិស្សទាំងអស់មើល។ តែភាពពិតគាត់ទៅអង្គុយនោះ អត់មានទេ គឺមានតែគាត់នាំសិស្សទៅមើលជំងឺ ពិនិត្យ និងសន្និដ្ឋានជំងឺផ្ទាល់ៗ។ ហ្នឹងសូមអ្នកម្ចាស់សំណួរជ្រាបបាទ។

**ស៖** ខ្ញុំចង់បញ្ជាក់លម្អិតទៅលើចំណុចនេះ។ កាលពីម្សិលមិញលោកឆ្លើយថា គាត់បង្រៀនលោកអំពីបញ្ហាវេជ្ជសាស្ត្រ វិទ្យាសាស្ត្រ។ បញ្ហាវេជ្ជសាស្ត្រនេះ តើលោកអាចបញ្ជាក់ជូនយើងខ្ញុំដែរទេថាតើគាត់មានបានអប់រំលោកអំពីបញ្ហាកោសល្យវិច័យពេទ្យនេះដែរឬទេ?

[១០:២០:៥០]

**ឆ៖** ត្រង់ហ្នឹងអត់យល់លោកម្ចាស់សំណួរបាទ។ ខ្ញុំអត់យល់ សំណួរខ្ញុំអត់យល់ ព្រោះខ្ញុំប្រើពាក្យថា គាត់មិនបាន ។បង្រៀនផ្នែកទ្រឹស្តីទេ គាត់ឯកសារមកឲ្យពួកអ្នកលោកគ្រូអ្នកគ្រូបង្រៀន ព្រោះគាត់ក្នុងឋានៈគាត់ជាដឹកនាំ ម្ល៉ោះហើយគាត់មិនបានមកបង្រៀន បង្ហាត់បង្រៀនផ្ទាល់ទេ គាត់គ្រាន់តែមានឱកាសពេលវេលាខ្លះ បង្រៀនផ្ទាល់ៗមាត់ ផ្ទាល់ដៃ ផ្ទាល់សកម្មភាពគឺនាំជំងឺទៅមើល អ្នកនាំពេទ្យទៅមើលជំងឺ ពិនិត្យជំងឺថា លក្ខណៈអី គ្រុនចាញ់យ៉ាងម៉េច គ្រុនពោះវៀនយ៉ាងម៉េច អ្នកហើមថ្លើមយ៉ាងម៉េច ហើយអ្នករលាកថ្លើមយ៉ាងម៉េច អ្នកខូចប្រមាត់នោះយ៉ាងម៉េច នោះគាត់និយាយជាក់ៗស្តែង។ តែភាពថាគាត់និយាយក្នុងសាលា រឿងនេះគាត់អត់និយាយទេ។ គាត់នាំជំងឺទៅដេក អ្នកជំងឺដេកស្លូកអីចឹងទៅ គាត់បង្ហាញហេតុផលសិស្សដែលគាត់នាំ។ អីចឹងនេះគឺជាហេតុការណ៍ពិតដែលគាត់ចូលចិត្តបង្រៀនសិស្សគាត់អីចឹងឯង។ សូមទទួលស្គាល់បាទ។

[១០:២១:៥២]

**ស៖** សូមអរគុណលោក អែម អឿន។ ខ្ញុំមិនបានសួរលោកអំពីវគ្គនយោបាយដែលលោក ជួន ជឿន អប់រំលោកនោះទេ ខ្ញុំសួរអំពីវគ្គអប់រំខាងវេជ្ជសាស្ត្រ ខាងពេទ្យដែលលោក ជួន ជឿន បានអប់រំលោក។ កាលពីម្សិលមិញលោកក៏បានឆ្លើយពាក់ព័ន្ធទៅនឹងជនជាតិកូរ៉េ និងចិន ដែលអ្នកទាំងពីរនោះបានជួយនៅក្នុងការងារពេទ្យ។ តើលោកអាចជួយពន្យល់បន្ថែមដែរឬទេ ថាតើជនជាតិកូរ៉េ និងជនជាតិចិននោះ បានធ្វើអ្វីខ្លះនៅពេលដែលគេមកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនោះ?

**ឆ៖** ជនជាតកូរ៉េ និងជនជាតិចិន គឺគេមកភាគច្រើនចូលក្នុងសាលាបច្ចេកទេស គឺគេបង្ហាត់បង្រៀនខាងទ្រឹស្តី ប៉ុន្តែពេលនោះ គឺអ្នកបកប្រែអស់ ឬមិនអស់ខ្ញុំមិនដឹងទេ តែការពិតទៅអ្នកពីរនាក់នេះភាគច្រើនចូលសាលាហ្វឹកហ្វឺនផ្នែកវិទ្យាសាស្ត្រនេះឯង។ អ៊ីចឹងអ្នកបច្ចេកទេសផ្ទាល់ គឺលោក ជួន ជឿន ឯទ្រឹស្តីគឺកូរ៉េ ហើយនិងចិន។ ហ្នឹងខ្ញុំសូមនិយាយរឿងពិតបាទ។

[១០:២៣:២៧]

**ស៖** តើលោកចាំទេ គេបង្រៀនលើចំណុចអ្វីខ្លះ?

**ឆ៖** ខ្ញុំមិនដឹងបកស្រាយយ៉ាងម៉េចទេម្ចាស់សំណួរ បើថាការរៀនពេទ្យ ឈ្មោះថារៀនពេទ្យមួយម៉ាត់ វាទាល់តែអង្គុយនិយាយៗឲ្យអស់ ទើបអស់រឿងការងារពេទ្យ និយាយច្រើនដែរ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ការងារពេទ្យគឺ គេបង្ហាត់បង្រៀនបច្ចេកទេសពេទ្យនេះឯង។ ការពិតគេឲ្យយើងចេះដឹងអំពីការចាក់ថ្នាំ ស្គាល់អំពីថ្នាំ សកម្មភាពថ្នាំ សកម្មភាពរបស់ពេទ្យធ្វើយ៉ាងម៉េចដើម្បីជាជំងឺ អានេះ ហេតុផលនេះខ្ញុំលើកឡើងបានខ្លះ បើការរៀនសូត្រសាលា រៀនៗយូររយៈពេល១ឆ្នាំ។ អ្នកម្ចាស់សំណួរសូមជ្រាបថា ដល់ឥឡូវ នេះខ្ញុំស្តាយស្រណោះដែរ ដោយសារឯកសាររបស់ខ្ញុំលោកៗកុម្មុយនីស្តក្រហមនេះឯង លោកស៊ីអស់ហើយឯកសាររបស់ខ្ញុំ ទាំងពេលវេលា ទាំងឯកសារ គឺលោកដុតចោល ហែកចោលខ្ទេចខ្ទី ដោយមិនបានសល់ឡើយ។ អាស្រ័យដោយខ្ញុំរត់ចោលផង គ្មានម្ចាស់ថែ។ ដូច្នេះការសិក្សាពេទ្យ បើនិយាយតាមចិន ចិនភាគច្រើនគេប្រើលក្ខណៈគេប្រើ គឺគេចូលចិត្តប្រើតាមលក្ខណៈវិទ្យាសាស្ត្រតាមម្កុលវិទ្យាសាស្ត្រ។ ឯកូរ៉េគេចូលចិត្តប្រើនាទី អប់រំពេទ្យរៀន គឺអប់រំអំពីជំងឺដែលត្រូវវះកាត់។ វះរបៀបម៉េច វះកាត់ស្បូន វះកាត់ឆ្អឹងឆ្អែង ឆ្អឹងដៃ ឆ្អឹងជើង វះកាត់ក្រពះ វះកាត់សួតថ្លើម យ៉ាងម៉េចៗ គឺខាងកូរ៉េគេអ្នកបង្ហាត់។ ហ្នឹងសូមលោកម្ចាស់សំណួរជ្រាបបាទ។

[១០:២៥:១២]

**ស៖** កាលពីម្សិលមិញលោកក៏បានឆ្លើយផងដែរថា មានមនុស្សម្នាក់ នី នោះដែលថាបង្រៀនលោកផ្នែករបេង។ តើលោកចាំទេថា ជួន ជឿន នោះក៏មានជំនាញបង្រៀនលោកផ្នែកពិសេស ពេទ្យជាក់លាក់ពិសេសមួយផងដែរ តើលោកចាំទេថាគាត់មានជំនាញហ្នឹងដែរ?

**ឆ៖** តាមចាំបាន គឺខ្ញុំមិនបានរៀនផែកលោកគ្រូទេ ប៉ុន្តែតាមគាត់និយាយគាត់បានសិក្សានៅប្រទេសបារាំង។ គាត់ លក្ខណៈជំនាញរបស់គាត់ គឺជំនាញឯកទេសបេះដូង។ ដូច្នេះឱកាសនោះ គាត់បានវះកាត់បេះដូងមួយនៅក្នុងឆ្នាំ៧២ គាត់បានវះកាត់បេះដូងមួយ ដែលខ្ញុំមើលឃើញនឹងភ្នែក គឺគាត់ប្តូរបេះដូង។ អ៊ីចឹងគាត់ប្រើប្រាស់ខ្លាំង គឺគាត់ជំនាញខាងជំងឺក្នុង និងជំងឺៗបេះដូង ជំងឺបេះដូងផ្នែកខាងក្នុងគាត់ស្គាល់ រហូតដល់ខ្ញុំចាំបានថា គាត់ប៊ានសន្និដ្ឋានមុខ -- ដោយគាត់ប្រើពាក្យថា បើខ្ញុំថាបេះដូងឈឺអីៗ បើអ្នកឯងចង់ដឹងយកទៅវះក៏បានដែរ។ អ៊ីចឹងលោក ជួន ជឿន ច្បាស់ណាស់ខាងវិជ្ជាពេទ្យដោយគាត់មានសញ្ញាបត្រមួយចេញពីប្រទេសបារាំង។ គាត់មានសញ្ញាបត្រឯកទេសបេះដូង។ ហ្នឹងតាមសម្តីរបស់គាត់និយាយភាគច្រើន គឺគាត់បង្រៀននោះក្នុងលក្ខណៈឯកទេសបេះដូង។ ហ្នឹងសូមលោកម្ចាស់សំណួរជ្រាបបាទ។

[១០:២៦:៥៩]

**ស៖** លោក ជួន ជឿន គាត់គឺជាអ្នកខាងវះ ជំនាញខាងវះកាត់បេះដូង ទទួលការបណ្តុះបណ្តាលពីបារាំង។ គាត់គឺជាបុគ្គលមួយរូប ដែលបានអប់រំផងដែរ -- អប់រំលោកផងដែរខាងពេទ្យនេះ នៅមន្ទីរពេទ្យខ្មែរ-សូវៀត។ តើខ្ញុំនិយាយដូច្នេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ ប៉ុន្តែខ្ញុំបញ្ជាក់សំណួរមួយខាងដើម ព្រោះខ្ញុំ -- មុនអំមិញនេះគឺថា គាត់សួរអំពីឈ្មោះ នី។ ការពិតឈ្មោះ នី គឺជាឯកទេសស្បូត ជំងឺរបេង។ អ៊ីចឹងគាត់មានគ្នាគាត់បីនាក់ ប៉ុន្តែខ្ញុំអត់ស្គាល់អ្នកណា ចាំបានតែឈ្មោះ នី នេះឯង។ អ៊ីចឹងឥឡូវនៅទីណាក៏ខ្ញុំមិនបានដឹងដែរ ព្រោះខ្ញុំមិនដែលជួប ហើយពីពេលនោះគាត់ចាស់រួចទៅហើយ។ អ៊ីចឹងឈ្មោះ នី ជាអ្នកបង្រៀនខ្ញុំខាងផ្នែក បេះដូង។ អ៊ីចឹងសូមលោកម្ចាស់សំណួរជ្រាបថា ឈ្មោះដែលថាឈ្មោះម្នាក់ហ្នឹងឈ្មោះ នី គឺៗគាត់ ឯកទេសជំងឺស្បូត។ ហ្នឹងសូមលោកម្ចាស់សំណួរជ្រាបបាទ។

**ស៖** តើលោកចាំទេ ថាតើលោក នី នេះទៅរៀននៅឯណាដែរ? គាត់ទទួលការបណ្តុះបណ្តាលពីណាមកដែរ?

[១០:២៨:១៩]

**ឆ៖** លោកម្ចាស់សំណួរខ្ញុំសូមមិនមែនថាបដិសេធទេ ត្រង់ណេះខ្ញុំមិនដែលបានជួបគាត់ទេបាទ។

**ស៖** ខ្ញុំសូមបន្តទៅប្រធានបទបន្ទាប់មួយទៀត។ ប្រធានបទនេះគឺស្តីអំពីវគ្គអប់រំនយោបាយនៅបុរីកីឡា ដែលលោកបានលើកឡើងថា លោកបានចូលរួមវគ្គអប់រំនយោបាយនោះ -- វគ្គរៀនសូត្រនយោបាយនោះ។ នៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ ដំបូងនោះ គឺលោកបានឆ្លើយថា លោកបានលើកឡើងអំពីបុគ្គលមួយរូបឈ្មោះ ខៀវ សំផន។ តាមលោកនោះគឺ ខៀវ សំផន នេះជាអ្នកឧទ្ទេសនាម អំពីនារីដែលបានកម្ទេចម្ជុល ដែលបានកាច់បំបាក់ម្ជុល លេខERN នោះគឺ 00777625 ចំណុចយោងជាភាសាខ្មែរគឺ 005008424 (ស៊ីក) នៅក្នុងចម្លើយរបស់លោកកាលពីសប្តាហ៍មុន គឺលោកនិយាយអំពី ខៀវ សំផន ដែល ខៀវ សំផន នេះឧទ្ទេសនាមអំពីនារីដែលធ្វើឲ្យបាក់ម្ជុលដែរ គឺនៅក្នុងប្រតិចារឹកកាលពីសប្តាហ៍មុនដែលមានសរសេរអំពីចំណុចនេះ។ លោកបាននិយាយពីរដង "អំពី ខៀវ សំផន ដែលធ្វើបទឧទ្ទេសនាម ពាក់ព័ន្ធទៅនឹងនារីធ្វើឲ្យបាក់ម្ជុលដែរ ថាតើត្រូវចាត់ការយ៉ាងម៉េចទៅលើនារីទាំងអស់នោះ?"។ តើលោកនឹងឃើញទេ លោកចាំទេ? តើលោកធ្លាប់ឮមេដឹកនាំផ្សេងទៀតនិយាយអំពីបញ្ហាដែលធ្វើឲ្យបាក់ម្ជុលនេះដែរឬទេ? មានមេដឹកនាំផ្សេងនិយាយអំពីបញ្ហាហ្នឹងដែរឬទេ?

[១០:៣០:៤៤]

**ឆ៖** សូមម្ចាស់សំណួរជម្រាប។ សម្តីនេះ មិនមែនខ្ញុំនិយាយចោទប្រកាន់ទៅលើការបាក់ម្ជុលនោះទេ។ នេះជាពាក្យសម្តីអត្ថាធិប្បាយនយោបាយក្នុងវគ្គសិក្សា។ ខ្ញុំពេលហ្នឹងបានលើកអំពីសកម្មភាពរបស់អ្នកៗប្រើប្រាស់នយោបាយនៅពេលនោះ គឺថាការចាប់ផ្តើមគេតែងតែនិយាយបន្តៗគ្នា ហើយបានគេចាប់ផ្តើមប្រធានបទរបស់គេ។ អ៊ីចឹងចំណុចដែលថា បាក់ម្ជុលនេះ គឺខ្ញុំទទួលស្គាល់ ព្រោះពេលនេះ ខ្ញុំបានសរសេរក្នុងព័ត៌មានក៏មាន ពាក្យសម្តីផ្ទាល់ក៏មាន។ ត្រង់នោះមិនមែនផ្តោតទៅលើតែម្ជុលដែរទេ គឺគ្រាន់ថា ការតឹងតែងរបស់វិន័យបក្សពេលនោះ គេថា "ដើម្បីៗចង់ដឹងនៃជនណាដែលបង្កប់ស៊ីរ៉ូងផ្ទៃក្នុង សូមឲ្យអស់មិត្តរកសត្រូវស៊ីរ៉ូងផ្ទៃក្នុងឲ្យឃើញ។ យើងបង្កើនការងារឲ្យច្រើន ធ្វើការងារតិច"។ អ៊ីចឹងបញ្ជាក់ គេបញ្ជាក់រហូតដល់ថា ដែលខ្ញុំនិយាយមួយម៉ាត់ថា "បាក់ម្ជុល" ដល់ខ្ញុំពិនិត្យមើលផែនការរបស់គាត់គឺ ឲ្យយើងពិនិត្យមើលតាំងពីសកម្មភាពធ្វើស្រែក៏ដោយ ធ្វើអីក៏ដោយ ឲ្យមើលទៅតាមសកម្មភាពថាបុគ្គលណាដែលធ្វើឲ្យរាំងស្ទះដល់ការងាររបស់បក្ស។ បើបុគ្គលណាមួយឧស្សាហ៍ធ្វើឲ្យប៉ះពាល់ កុំគិតឡើងថាការងារធំ សូម្បីតែម្ជុលដែរ ក៏គេគិតតាំងពីម្ជុលដែរ។ បើបុគ្គលណា ឬក៏នារីណាដេរម្ជុលឆាប់បាក់ ឆាប់បែក ឆាប់បាត់ ឬក៏ខ្សៀវអាវឆាប់បាត់បង់ នោះក៏ជាសត្រូវដែរ។ នេះជាពាក្យពិត

របស់ខ្ញុំបាទ។ គឺនិយាយអ៊ីចឹងមិនមែនផ្ដោតទៅលើតែមួយទេបាទ។

[១០:៣២:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណដើមបណ្ដឹងរដ្ឋប្បវេណី។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់សម្រាកសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក។ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរៗ

*(សវនាការសម្រាកពីម៉ោង ១០:៣២នាទី ដល់ម៉ោង ១០:៥២នាទី)*

[១០:៥១:៤៩]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ហ្សាស្ទ៊ី ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនតូចទៀត ពាក់ព័ន្ធទៅនឹងទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់លោក ហើយអ្វីដែលខ្ញុំចង់សួរនោះ គឺឱ្យលោកបញ្ជាក់បំភ្លឺតែប៉ុណ្ណោះ។ នៅទម្រង់បែបបទព័ត៌មានជនរងគ្រោះដំបូង គឺលោកបានសរសេរទីកន្លែងនៅត្រពាំងថ្កុក(ស៊ីក) ស្រុកកំចាយមារ ខេត្តព្រៃវែង។ ពាក្យសុំទី២ ដែលលោកបានដាក់តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺលោកបាន លោកសរសេរថា "ភូមិរើលលើ ឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម"។ ខ្ញុំសូមបញ្ជាក់ ដំបូងលោកបានឆ្លើយថា ភូមិត្រពាំងថ្កុក(ស៊ីក) ឃុំជាវ (ស៊ីក) ស្រុកកំចាយមាស ខេត្តព្រៃវែង។ ហើយក្រោយមកលោកឆ្លើយ ភូមិរើលលើ ឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១០:៥៣:៥៨]

**លោក គីម ម៉េងឃី៖**

បាទ សូមអរគុណលោកប្រធាន។ សំណួរនេះ គឺជាសំណួរច្រំដែល ពីព្រោះខ្ញុំបានសួររួចហើយតាំងពីដំបូង គឺគាត់បានបញ្ជាក់ថា ទីកន្លែងកំណើតរបស់គាត់នៅក្នុងខេត្តព្រៃវែង។ បាទ សូមអរគុណ។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណចំពោះការបញ្ជាក់បំភ្លឺបន្ថែមនេះ។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោក អែម អឿន លោកបាននិយាយថា លោកធ្លាប់ពេទ្យនៅតំបន់២០ ហើយលោកថាលោកនៅក្រោមសមមិត្ត កំ។ លោកមិនស្គាល់ឈ្មោះ គោលត្រនាម បានន័យថាត្រកូលរបស់គាត់នោះទេ ស្គាល់តែឈ្មោះធម្មតាតែប៉ុណ្ណោះ។ តើគាត់នោះ កំ ហ្នឹងទទួលបន្ទុកលើមន្ទីរពេទ្យតែម្តង ឬក៏គាត់ទទួលបន្ទុកគ្រប់គ្រងតែទៅលើពេទ្យនៅតំបន់២០តែប៉ុណ្ណោះ?

[១០:៥៥:១៩]

**លោក អែម អឿន៖**

**ឆ៖** សូមឆ្លើយ។ ឈ្មោះ មិនមែនឈ្មោះ កំ ទេ ព្រោះឈ្មោះ កំ នេះមិនដែលដឹងទេ មិនដែលមានទេ អត់មានសរសេរ កំ ទេ។ អត់មានសរសេរបាទ។ ឈ្មោះ កំ គឺគ្មានទេ តែបើឈ្មោះ អ៊ុត មាន

តាអ៊ុត មាន ព្រោះ តាអ៊ុត ហ្នឹង ជាបើជាតំណែងរបស់គាត់នៅពេលនោះ គឺគាត់ប្រធានពេទ្យតំបន់២០ បាទ។

**ស៖** ខ្ញុំសូមដកស្រង់ប្រតិចារឹក ចេញពីថ្ងៃព្រហស្បតិ៍ សប្តាហ៍មុន ទំព័រអង់គ្លេស គឺ៧៧ ខ្មែរ ៤៨,៤៩ នៃប្រតិចារឹក -- ក៏ប្រហែល ប្រហែលជាមានការបកប្រែនៅពេលនោះ។ ដូច្នេះ ខ្ញុំសូមអានជាភាសាអង់គ្លេស លោកបានឆ្លើយថា៖ "ខ្ញុំធ្វើពេទ្យនៅតំបន់២០ ក្រោមការក្តោបក្តាប់របស់ កំ។ ខ្ញុំមិនស្គាល់ត្រកូលរបស់គាត់ទេ ខ្ញុំស្គាល់តែឈ្មោះ គាត់ឈ្មោះ កំ"។ ប្រហែលជាឈ្មោះនោះគឺមិនបានបញ្ជាក់ និងបកប្រែឲ្យបានត្រឹមត្រូវចំពោះខ្ញុំ ក៏ប៉ុន្តែតើមានបុគ្គលណាម្នាក់ឈ្មោះ កំ ឬក៏ស្រដៀងនឹង កំ ដែរឬទេ ដែលគ្រប់គ្រងនៅពេទ្យតំបន់២០នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក គីម ម៉េងឃី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់នៅក្នុងប្រតិចារឹកជាភាសាខ្មែរ ហើយអ្វីដែលគាត់បាននិយាយគឺឈ្មោះ ខឹម។ ដូច្នេះ ដែលលោកមេធាវី គាត់ស្តាប់ឮថា កំ គឺគ្មាននៅក្នុងប្រតិចារឹកទេ បាទ។ សូមអរគុណ។

**សួរដោយលោក ហ្សាស្តេ ប៉ោះ៖**

**ស៖** ចំណុចនេះ ជួយផ្តល់ព័ត៌មានបន្ថែមឲ្យខ្ញុំច្រើន។ ដូច្នេះត្រង់ឈ្មោះ ខឹម នេះ តើលោកអាចបញ្ជាក់ទេ គាត់មានតួនាទីធ្វើអ្វីដែរ?

[១០:៥៧:៤៩]

**លោក អែម អឿន៖**

**ឆ៖** ត្រង់ហ្នឹង សូមលោកម្ចាស់សំណួរស្តាប់ឲ្យបាន ឈ្មោះ ខឹម នេះគឺជាលេខាតំបន់២០, ឯឈ្មោះ អ៊ុត គឺជាប្រធានមន្ទីរពេទ្យតំបន់២០ បាទ សូមជ្រាប។

**ស៖** សូមអរគុណ។ ចំណុចនេះ គឺបញ្ជាក់បំភ្លឺឲ្យខ្ញុំដឹងច្បាស់ហើយ។

**លោក ហ្សាស្តេ ប៉ោះ៖**

នៅពេលនេះ ខ្ញុំមិនមានសំណួរបន្ថែមសម្រាប់សួរលោកបន្ថែមទៀតទេ។ ខ្ញុំសូមអរគុណ ដែលលោកបានឆ្លើយពន្យល់យើងខ្ញុំ ហើយនិងការអត់ធ្មត់របស់លោក។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន

ផ្តល់វេទិកាទៅដល់សហមេធាវីជាតិ ក៏ប៉ុន្តែសហមេធាវីជាតិ ក៏គាត់ថាគាត់ពុំមានសំណួរបន្ថែមទៀតដែរ។ ដូច្នេះ ខ្ញុំសូមបញ្ចប់ការតាំងសំណួររបស់ខ្ញុំ ហើយផ្តល់វេទិកាទៅដល់ក្រុមមេធាវីផ្សេង។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោល ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ ភាគីទាំងអស់ អស់លោក លោកស្រីជុំវិញ និងក្នុងបន្ទប់សវនាការ។

[១០:៥៩:៣៨]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** អរុណសួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំ កាណាវាស និងលោក អាង ឧត្តម តំណាងការពារក្តីលោក អៀង សារី។ ខ្ញុំសូមបន្តត្រង់ចំណុចដែលមេធាវីអម្បាញ់មិញទុក មិនសួរលោកពាក់ព័ន្ធទៅនឹងចម្លើយរបស់លោក ដែលលោកបានឆ្លើយថា "នៅក្នុងឆ្នាំ១៩៧៥ គេតាំង -- តែងតាំងលោកឲ្យធ្វើការងារនៅពេទ្យ ទោះបីជាលោកពុំមានបទពិសោធន៍ពេទ្យក៏ដោយ"។ ខ្មែរគឺលេខ -- ខ្មែរ ERN គឺលេខ ឯកសារ E3/3963 ខ្មែរ ERN គឺ 00573976 ទៅដល់ 77, បារាំងគឺ 00786185, អង់គ្លេស 00751867 ឬក៏ទំព័រ៧។ ប្រសិនបើយើងមើលត្រង់អត្ថបទនេះ លោកបានបញ្ជាក់ថា "នៅឆ្នាំ៧៥ ពួកនេះត្រូវប្រគល់ឲ្យខ្ញុំបាទធ្វើពេទ្យព្យាបាលប្រជាជនទាំងខ្ញុំមិនទាន់ដែលចេះពេទ្យផង។ តែបើខ្ញុំប៉ិរានប្រកែកគេចោទខ្ញុំថាជាខ្មាំង។ ត្រង់នេះបញ្ជាក់ថា បើយើងមិននេះទេ គេមិន -- យើងមិនធ្វើតាមគេទេ ពួកគេនឹងចោទយើងជាខ្មាំង។ នេះគឺជារឿងដែលខ្ញុំបានជួបនៅក្នុងតំបន់២០ ក្នុង១០៧៥(ស៊ីក) ក្រោមការដឹកនាំរបស់ឈ្មោះ តាអ៊ិត។ ក្រោយមកនៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានអង្គការនេះបញ្ចូលឲ្យខ្ញុំទៅជាសមាជិកសកម្មរបស់របបពួកគេ។ នៅក្នុងឆ្នាំនេះដដែល អង្គការនោះត្រូវឲ្យខ្ញុំបាទទៅរៀននៅទីក្រុងភ្នំពេញ ក្នុងនេះខ្ញុំបានមាន -- ខ្ញុំបាទមានការភ័យណាស់ ព្រោះថាឪពុកខ្ញុំបានបាត់ខ្លួនក៏ការរៀននៅនេះដែរ។ ក្នុងនេះ ខ្ញុំបាទក៏បានទៅនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្រុងភ្នំពេញ"។ ខ្ញុំបញ្ចប់ការដកស្រង់សម្តីរបស់លោកត្រឹមនេះ។ តើលោកមើលឃើញចំណុច ដែលលោកបានឆ្លើយនៅក្នុងចម្លើយរបស់

លោកនោះដែរឬទេ ដែលលោកបានបំពេញនៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ? ហើយការបំពេញនោះ គឺមានខាងមជ្ឈមណ្ឌលឯកសារកម្ពុជាជួយឲ្យលោកបំពេញនៅក្នុង ព័ត៌មាននៅក្នុងហ្នឹង។ តើលោកឃើញចំណុចនេះដែរឬទេលោក?

[១១:០២:៤៣]

**លោក អែម អឿន៖**

**ឆ៖** បាទ ចំណុចនេះឃើញបាទ។ ខ្ញុំសរសេរមែនបាទ។

**ស៖** អ៊ីចឹងលោកសរសេរខ្លួនឯង មិនមានគេជួយសរសេរឲ្យលោកទេ ហើយដែលពាក្យទាំងអស់នេះគឺជាពាក្យរបស់លោកដែលលោកឆ្លើយថា លោកមិនមានជំនាញខាងពេទ្យផងនោះ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ត្រង់ណេះបញ្ជាក់ទាំងអក្សរ បញ្ជាក់តាមការសរសេរ និងយោបល់នេះគឺជារឿងរបស់ខ្ញុំពិត។ ទាំងអក្សរ ទាំងរឿង។ ហ្នឹងសូមម្ចាស់សំណួរទទួលស្គាល់បាទ។

[១១:០៣:២៩]

**ស៖** បានន័យថា មិនមាននរណាម្នាក់សរសេរឲ្យលោកទេ អក្សរនេះ? ហើយមិនមាននរណាសរសេរឲ្យ ហើយគេស្ដាប់មក ហើយកត់ព័ត៌មាននេះខុសឲ្យលោកនោះទេ។ នៅក្នុងនេះ គឺលោកសរសេរខ្លួនឯងថា "លោកមិនទាន់ដែលចេះពេទ្យផង"។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំសរសេរអ៊ីចឹងមែនបាទ។

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលឯកសារ D22/3963/1 មានតែភាសាអង់គ្លេសតែប៉ុណ្ណោះ។ ក្នុងនោះសរសេរថា "របាយការណ៍ពាក់ព័ន្ធទៅនឹងទម្រង់បែបបទព័ត៌មានជនរងគ្រោះ ដែលគេសរសេរឲ្យ"។ អ្នកដាក់ពាក្យសុំបានសរសេរថា "ទោះបីគាត់មិនបានដឹង មិនមានបទពិសោធន៍ក៏ដោយ គេបានចាត់តាំងគាត់ឲ្យធ្វើជាពេទ្យនៅតំបន់២០ ដែលមានប្រធានឈ្មោះ តាអ៊ុត ប្រសិនបើគាត់មិនអត់ធ្មត់ ហើយធ្វើតាមគេទេ គេនឹងសម្លាប់គាត់ចោល"។ ERN គឺ 00573962 ជាភាសាអង់គ្លេសមានតែភាសាអង់គ្លេសតែប៉ុណ្ណោះ។ តើលោកនៅតែរក្សាសម្ដីនេះដដែល ដែលលោកបានឆ្លើយ ឬដែលគេបានរៀបចំជូនលោកនោះ? តើលោករក្សាសម្ដីនេះដដែលដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

មេធាវីការពារក្តីត្រឡប់មកសួរសំណួរពាក់ព័ន្ធទៅនឹងព័ត៌មាននៅក្នុងទម្រង់ព័ត៌មាន ដែលថាអត់មានចំណេះដឹងខាងផ្នែកវេជ្ជសាស្ត្រ។ ពាក់ព័ន្ធទៅនឹងចំណុចនេះ គឺសំណួរនេះ ត្រូវបានសួរដោយខាង នួន ជា រួចមកហើយ។ ហើយដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយច្បាស់ណាស់ ថាគាត់អត់មានដែលបានទទួលការបណ្តុះបណ្តាលវេជ្ជសាស្ត្រផ្លូវការនោះទេ គឺថាបណ្តុះបណ្តាលនៅកន្លែងធ្វើការតែម្តង។ ដូច្នេះហើយគាត់បញ្ជាក់ថា គាត់មិនមានការបណ្តុះបណ្តាលខាងពេទ្យទេ។ ហើយឥឡូវនេះ ខាងមេធាវីការពារក្តី សួរសំណួរនេះដដែល ហើយសំណួរនេះ បានឆ្លើយបំភ្លឺទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីរួចមកហើយ។ សូមអរគុណលោកប្រធាន។

[១១:០៦:០២]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ប្រសិនបើខ្ញុំឆ្លើយតបដោយខ្លី ប្រហែលជា គាត់ សាក្សីដើមបណ្តឹងរដ្ឋប្បវេណីនោះមានតំណាងការពារក្តីខ្ញុំនេះ ការពារក្តីជនជាប់ចោទផ្សេង ហើយអ្នកផ្សេងការពារក្តីជនជាប់ចោទផ្សេង។ យើងធ្វើតំណាងការពារក្តីជនជាប់ចោទខុសៗគ្នា។ ដូច -- ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីនោះគឺមាននៅក្នុងផ្នែករបស់គាត់មានលក្ខណៈខុសគ្នា មានក្រុមខុសគ្នាក៏ដោយ ប៉ុន្តែគាត់ក្តោបទៅលើផលប្រយោជន៍រួមតែប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំមានសិទ្ធិធ្វើការដេញដោលចំណុចនេះ ដោយសារតែខ្ញុំតំណាងការពារក្តីជនជាប់ចោទមួយរូប ដោយឡែក។ ហើយយើងត្រូវតែបញ្ជាក់ថា តើគាត់ហ្នឹង មានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងខ្ញុំត្រូវសួរបញ្ជាក់លម្អិតទៅលើចំណុចនេះ។

[១១:០៦:៥៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៧:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមានលក្ខណៈសមស្រប។ ដោយសារជាសំណួរច្រំដែល ដូច្នេះសេចក្តីជំទាស់មានប្រសិទ្ធភាព។ លោកមេធាវីការពារក្តី អាចតាំងសំណួរផ្សេងទៀត។

[១១:០៨:២២]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សូមអរគុណ។ យើងមើលប្រតិចារឹកត្រង់ទំព័រ៥១ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ អង់គ្លេស ៥១, បារាំង ៥៦, ខ្មែរ ៤៦។ គេបានសួរសំណួរលោកត្រង់ជួរ២១ នៃភាសាអង់គ្លេស។ សូមឲ្យលោកជម្រាបអង្គជំនុំជម្រះ ថាលោកធ្វើអ្វី នៅក្នុងអំឡុងពេលហ្នឹង ហើយលោករស់នៅទីណា? លោកឆ្លើយថា "ក្នុងពេលនោះ ចាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ និងមុនឆ្នាំកាលបរិច្ឆេទនោះ ខ្ញុំធ្វើជាពេទ្យ។ ក្រោយឆ្នាំ៧៥ ខ្ញុំនៅតែធ្វើពេទ្យដដែល"។ ដូច្នេះ តាមពាក្យសម្ដីរបស់លោកនេះ មុនខែមេសា ឆ្នាំ៧៥នោះ គឺលោកធ្វើជាពេទ្យ តើត្រឹមត្រូវដែរឬទេ?

**លោក អែម អឿន៖**

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ឥឡូវនេះ គឺយើងមើលកន្លែងដែលលោកមិនមានបទពិសោធន៍ជាពេទ្យ គឺទំព័រដដែល។ ខ្មែរ គឺ៤៦, អង់គ្លេស គឺ៥០ ទៅ៥១ នៅត្រង់នេះ គឺលោកបានប្រាប់យើងថា "ខ្ញុំមកភ្នំពេញ ខ្ញុំនៅជាមួយពូរបស់ខ្ញុំ ហើយខ្ញុំបានរៀនពេទ្យ។ ដោយសារតែអ៊ំរបស់ខ្ញុំហ្នឹងគឺជាពេទ្យ"។ ខ្ញុំសួរថា តើឪពុកធំរបស់លោកនោះ គឺជាពេទ្យវិជ្ជាជីវៈ ហើយគាត់បានទទួលការបណ្ដុះបណ្ដាលផ្លូវការដែរឬទេ? ឬក៏គាត់ជាពេទ្យបុរាណ ពេទ្យសាមញ្ញ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា ឪពុកធំនោះគាត់មានវិជ្ជាជីវៈជាពេទ្យ ហើយគាត់ជាពេទ្យក្របខ័ណ្ឌនៅពេទ្យរុស្ស៊ីផ្ទាល់តែម្ដង កាលពីអតីតសម័យ គឺថាសម័យសង្គមរាស្ត្រនិយម។ អ៊ីចឹងខ្ញុំចេះពេទ្យតាមអ៊ំនេះ តាំងពីឆ្នាំ សម័យសង្គមរាស្ត្រនិយមម្ល៉េះ។ ព្រោះគាត់យកខ្ញុំទៅបណ្ដុះបណ្ដាលតាមដំណើរជាក់ស្ដែង។ នេះសូមជ្រាបបាទ។

[១១:១១:០៩]

**ស៖** សូមអរគុណ។ ដើម្បីឲ្យយើងបញ្ជាក់ឲ្យបានច្បាស់ តើគាត់មានសញ្ញាបត្រជាក់លាក់ដែលអនុញ្ញាតឲ្យគាត់ធ្វើពេទ្យនៅក្នុងរបបនោះដែរឬទេ ប្រសិនបើលោកដឹងនោះ?

**ឆ៖** ឪពុកមាខ្ញុំសម័យនោះ គឺគាត់មានសិទ្ធិធ្វើជាលោកគ្រូពេទ្យនៅក្នុងមន្ទីរពេទ្យ ដូច្នេះការដឹងឮថាមានសញ្ញាបត្រ ឬមិនមាននោះ ខ្ញុំក្នុងឋានៈជាក្មួយរបស់គាត់ប៉ុណ្ណោះឯង។ អ៊ីចឹងការសាកសួរ ខ្ញុំមិនបានសួរគាត់ទេ។ គ្រាន់តែដឹងថាគាត់ធ្វើពេទ្យ លោកគ្រូពេទ្យនៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ សូមជ្រាបបាទ។

**ស៖** សូមអរគុណ។ ចំណុចនេះដែលខ្ញុំចង់សួរ ថានៅពេទ្យណា។ នៅទំព័រដដែល នៅពេលនោះ គឺលោកមានអាយុតែ១០ឆ្នាំទេ នៅពេលដែលឪពុកមា ឪពុកធំរបស់លោកនោះមកបង្រៀនលោក ផ្នែកពេទ្យ និងការព្យាបាលជំងឺទូទៅ។ តើត្រឹមត្រូវដែរឬទេចំណុចនេះ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១១:១២:២៣]

**ស៖** នៅត្រង់ទំព័របន្ទាប់ ខ្មែរគឺ ៥២, បារាំង ៦១, អង់គ្លេស គឺ៥៧ លោកបានឆ្លើយថា "នៅពេលមួយនោះ គេបញ្ជូនលោកទៅវៀតណាម ទៅបណ្តុះបណ្តាល -- គេបញ្ជូនលោកទៅបណ្តុះបណ្តាលនៅវៀតណាម"។ តើត្រឹមត្រូវដែរឬទេចំណុចនេះ?

**ឆ៖** បាទ ត្រឹមត្រូវបាទ។

**ស៖** តើលោកអាចពន្យល់ជូនយើងខ្ញុំដែរឬទេ តើវគ្គបណ្តុះបណ្តាលអ្វីដែលលោករៀននៅវៀតណាមនោះ? ហើយគេបណ្តុះបណ្តាលលោកនៅវៀតណាមនោះរយៈពេលប៉ុន្មានដែរ?

**ឆ៖** រយៈពេលបណ្តុះបណ្តាលនោះ ខ្ញុំមិនវែស្មានទេ ប៉ុន្តែខ្ញុំដឹងកាលណោះ ខ្ញុំក៏ទៅពីភ្នំពេញដែរ ក្រោយពេល -- នៅពេលដែលៗកើតខ្មែរក្រហមហើយ គឺថា ឪពុកខ្ញុំជាមេខ្មែរក្រហមដែរ ហើយពួកខ្មែរក្រហមក៏វាក្រពេទ្យ។ អ៊ីចឹងនៅពេលដឹងថា ឪពុកខ្ញុំមានកូនចេះពេទ្យ ពួកខ្មែរក្រហមក៏សុំឪពុកខ្ញុំទៅឲ្យរៀនពេទ្យនៅជាមួយវៀតណាម។ ហ្នឹងសូមជ្រាបបាទ។

[១១:១៣:៤៧]

**ស៖** សូមឲ្យលោកឆ្លើយសំណួររបស់ខ្ញុំ។ តើលោកនៅវៀតណាមនោះរយៈពេលប៉ុន្មានដែរ ដែលពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាលពេទ្យជាក់លាក់ ដែលគេផ្តល់ជូនលោកនៅវៀតណាមនោះ លោកទទួលការអប់រំហ្នឹងរយៈពេលប៉ុន្មានដែរ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់នឹងសំណួរនេះ គឺថា កូនក្តីខ្ញុំបានឆ្លើយថា ទៅរៀនជាមួយពួកវៀតណាម មិនមែនទៅរៀននៅប្រទេសវៀតណាមទេ។ ហើយលោកមេធាវីការពារក្តី គាត់

ព្យាយាមជជីកសួរពីរឿងទៅរៀននៅប្រទេសវៀតណាម។ សំណួរនេះគឺខុសគ្នាបាទ។ សូមជំទាស់។

[១១:១៤:៤២]

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំសូមដកស្រង់សម្ដីចេញពីប្រតិចារឹក លោកប្រធាន ហើយខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី អាចមើលបាន គឺទំព័រ៥២ ជាភាសាខ្មែរ, បារាំងគឺ ៦១ ដល់ ៦២ ហើយអង់គ្លេសគឺ ៥៧។ ដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយថា "នៅពេលនោះខ្មែរក្រហមមើលឃើញថាបទពិសោធន៍ពេទ្យរបស់ខ្ញុំនោះ មិនគ្រប់គ្រាន់ ហើយក្រោយពីពិភាក្សាជាមួយនឹងឪពុករបស់ខ្ញុំនោះ គេបានបញ្ជូនខ្ញុំទៅបណ្ដុះបណ្ដាលនៅក្នុងប្រទេសវៀតណាម ក្រោមការបង្គាប់ដឹកនាំរបស់លោក សោ ភឹម ជាមេភូមិភាគបូព៌ា"។ តើលោកចាំថាលោកបានឆ្លើយដូច្នេះដែរឬទេ លោកដើមបណ្ដឹងរដ្ឋប្បវេណី? ហើយប្រសិនបើលោកចាំថាលោកឆ្លើយដូច្នេះនោះ តើលោកនៅតែរក្សាសម្ដីនេះដដែល ដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនបានឆ្លើយអ៊ីចឹងទេ គ្រាន់តែបញ្ជាក់ថា "ខ្ញុំបានទៅរៀនវៀតណាម"។ មិនបាននិយាយថា "ប្រទេសវៀតណាម" នោះទេបាទ។

[១១:១៦:០៨]

**ស៖** ដូច្នេះមិនជាអ្វីទេ។ ក៏ប៉ុន្តែខ្ញុំនឹងពិនិត្យមើលថាតើខ្ញុំយល់ត្រឹមត្រូវដែរឬទេ នៅក្នុងចម្លើយរបស់លោក ក្នុងនេះលោកបានឆ្លើយថា ខ្ញុំសូមទៅទំព័រមុនហ្នឹងបន្តិច។ "ក្រោយពេលចេញពីភ្នំពេញ ខ្ញុំទៅផ្ទះរបស់ខ្ញុំដើម្បីចិញ្ចឹមឪពុក និងគ្រួសាររបស់ខ្ញុំ។ ឪពុករបស់ខ្ញុំហ្នឹងជាបុគ្គលមួយរូបជាន់ខ្ពស់នៅក្នុងខ្មែរឥស្សរៈ។ ក្រោយមកខ្មែរក្រហមបានដឹងថា ខ្ញុំជាកូនពេទ្យមួយរូប គឺកូនដែលក្នុងគ្រួសារមានជំនាញខាងពេទ្យ។ ដូច្នេះហើយ គេសុំឲ្យខ្ញុំធ្វើការឲ្យខ្មែរក្រហម។ ក្រោយមក ខ្មែរក្រហមបានកត់សម្គាល់ឃើញថា ជំនាញរបស់ខ្ញុំមិនល្អគ្រប់គ្រាន់សម្រាប់យកមកប្រើប្រាស់។ ក្រោយពិភាក្សាជាមួយឪពុករបស់ខ្ញុំនោះ គឺគេអនុញ្ញាតឲ្យខ្ញុំទៅរៀននៅវៀតណាម ក្រោមការបង្គាប់ដោយផ្ទាល់ពី សោ ភឹម ដែលជាមេភូមិភាគបូព៌ា"។ នៅក្រោមនេះបន្តិច លោកនិយាយថា "ខ្ញុំអាយុ ខ្ញុំ២១ -- ក្រោម២១ -- ក្រោម ២០ឆ្នាំ។ ដូច្នេះហើយពេលនោះ ខ្ញុំចាប់ផ្ដើមអាជីពពេទ្យ ហើយចិញ្ចឹមគ្រួសាររបស់ខ្ញុំ"។ តើនៅថ្ងៃនេះលោកបញ្ជាក់ឆ្លើយថា លោក សោ ភឹម នោះគឺចាប់អារម្មណ៍លោក ឲ្យលោកទៅរៀនវៀតណាម មិនមែនរៀនពេទ្យ ឬក៏យ៉ាងម៉េច? ក៏ប៉ុន្តែនៅក្នុងអ្វីដែលលោកឆ្លើយពីមុននោះ គឺលោកនិយាយថា "លោកមិនមានជំនាញគ្រប់គ្រាន់ខាងពេទ្យ ទើបគេបញ្ជូនឲ្យលោកទៅរៀន"។ តើមួយណាដែលជាចម្លើយរបស់

លោកត្រឹមត្រូវនោះ?

[១១:១៧:៥៨]

**ឆ៖** ចម្លើយពិតរបស់ខ្ញុំ គឺនៅពេលដែលខ្ញុំត្រឡប់មកពីភ្នំពេញ តាមរយៈឪពុកខ្ញុំផង តាមលោក សោ ភឹម ផងឲ្យខ្ញុំទៅរៀននៅវៀតណាម គឺជាសម្ដីរបស់ខ្ញុំពិតបាទ។ ហើយមិនមែនរៀនអី គឺរៀនពេទ្យនេះឯង។

**ស៖** សូមអរគុណលោក។ ដូច្នេះ នៅពេលនេះ គឺលោកនិយាយថា គេបញ្ជូនលោកទៅវៀត-ណាមរៀនពេទ្យ។ ដូច្នេះ តើគេបញ្ជូនលោកទៅរៀនពេទ្យនៅវៀតណាមនោះ រយៈពេលប៉ុន្មានដែរ?

**ឆ៖** រៀនពេទ្យនៅវៀតណាមរយៈពេល៣ឆ្នាំ។ អាហ្នឹងតាមចាំបាន គឺ៣ឆ្នាំ។ បើការខុសក្រែងលោខ្ញុំភ័ន្តច្រឡំ សូមអភ័យទោសទុកជាមុន ត្រង់ហ្នឹងអាចដោយជាការកំណត់អ៊ីចឹង ខ្ញុំមិនប៊ានថាយ៉ាងណានោះទេ ព្រោះថាការកំណត់វែងឆ្ងាយវាអាចនឹងភ្លេចភ្លាំងបាទ។ សូមទទួលស្គាល់។

[១១:១៩:១៣]

**ស៖** ដូច្នេះ ៣ឆ្នាំក្រោយបណ្ដុះបណ្ដាលនៅពេទ្យ នៅវៀតណាម លោកត្រឡប់មកប្រទេសកម្ពុជាវិញ។ តើអ៊ីចឹងដែរឬទេ? ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ដូច្នេះនៅពេលដែលលោកនិយាយត្រង់នេះ លោកអាយុក្រោម២០ឆ្នាំ ដែលលោកចាប់ផ្ដើមធ្វើពេទ្យ រៀនពេទ្យ។ ដូច្នេះ តើនៅពេលដែលលោកធ្វើជាពេទ្យក្រោមអាយុ២០ឆ្នាំ អាយុតិចជាង២០នោះ គឺក្រោយពេលដែលលោកទៅបណ្ដុះបណ្ដាលនៅវៀតណាម ឬក៏មុនពេលដែលលោកទៅបណ្ដុះបណ្ដាលនៅវៀតណាម?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំបានបញ្ជាក់ថា ខ្ញុំចេះពេទ្យតាំងពីខ្ញុំនៅតូច ទៅរៀននៅឪពុកខ្ញុំ -- នៅជាមួយឪពុកធំម្ដ៉េះ។ នេះជាការពិតរបស់ខ្ញុំបាទ។

**ស៖** ខ្ញុំបន្តទៅមុខបន្តិចសិន។ យើងមើលទំព័របន្ទាប់ទៀតខ្មែរ គឺ៥៣ ទំព័រ៥៣, បារាំង៦២, អង់គ្លេស៥៨។ នៅត្រង់នេះ លោកឆ្លើយទៅនឹងចម្លើយរបស់លោក "ក្រោយពេលចាកចេញពីវៀត-ណាម ឪពុករបស់ខ្ញុំ និងតា សោម ភឹម និង តាគង់ សុំឲ្យខ្ញុំធ្វើពេទ្យនៅតំបន់"។ តើត្រឹមត្រូវដែរឬទេ? ការពិតដែរឬទេ ដែលនៅពេលនោះឪពុករបស់លោក សោ ភឹម និង ខឹម បានសុំឲ្យលោកនោះធ្វើជាពេទ្យនោះ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១១:២១:២១]

**ស៖** ដូច្នេះហើយគេមិនបានបង្ខំលោកឲ្យធ្វើពេទ្យនោះទេ គឺក្រោយពេលដែលលោកបណ្តុះបណ្តាល ទទួលការបណ្តុះបណ្តាល៣ឆ្នាំនៅវៀតណាម និងការមើលជាក់ស្តែងអំពីបញ្ហាពេទ្យពីអ៊ំរបស់លោក ពីឪពុកមា ឪពុកធំរបស់លោកនៅក្នុងក្រុងភ្នំពេញនេះហើយនោះ ទើបគេស្នើសុំឲ្យលោកធ្វើពេទ្យ គេមិនបង្ខំលោកទេ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមជជែកក្នុងបញ្ហាហ្នឹងបន្តិច ព្រោះខ្ញុំបានបញ្ជាក់ខាងដើមថា ឈ្មោះថារៀនៗ វាទាល់តែការទទួលស្គាល់ មានសញ្ញាប័ត្រ មានអី អាហ្នឹងហៅថាលក្ខណៈរៀន។ តែនោះការឃើញចេះប្រើៗ មិនមែនជាលក្ខណៈរៀន មិនមែនរៀនឲ្យចេះទេ។ សូមលោកម្ចាស់សំណួរឲ្យបានយល់នូវការឆ្លើយរបស់ខ្ញុំបាទ។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ក្រោយពេលដែលលោកវិលត្រឡប់ពីប្រទេសវៀតណាមវិញនោះ នៅពេលដែលគេ សិស្សស្នើសុំលោកឲ្យធ្វើពេទ្យ ដោយ សោ ភឹម និងឪពុករបស់លោកនោះ គឺក្រោយខែមេសា ឆ្នាំ៧៥ ឬក៏មុនខែមេសា ឆ្នាំ៧៥?

**ឆ៖** សូមសួរម្តងទៀត ថាក្រោយ ឬមុន ឬថាម៉េចក្នុង៧៥ -- ១៧ មេសា ៧៥? បើតាមការបញ្ជាក់ ខ្ញុំចង់សួរបញ្ជាក់ បើសិនជាខ្ញុំស្តាប់ ក្រែងលោថាស្តាប់ច្រឡំសំណួរ។ មើល៍សូមបញ្ជាក់ម្តងទៀតបាទ។

[១១:២៣:១៣]

**ស៖** ខ្ញុំសូមអធ្យាស្រ័យ។ នៅពេលដែលលោកវិលត្រឡប់ពីប្រទេសវៀតណាម ហើយធ្វើជាពេទ្យនៅក្នុងតំបន់២០ តើវាមុនពេលបែកភ្នំពេញ ឬក៏ក្រោយបែកភ្នំពេញ?

**ឆ៖** ខ្ញុំធ្វើពេទ្យតំបន់២០ ស្ថិតនៅតំបន់២០ មុនៗបែកភ្នំពេញបាទ។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ធ្វើពេទ្យនោះមុនបែកភ្នំពេញនោះ មុនរយៈពេលប៉ុន្មានខែដែរ ឬក៏មុនរយៈពេលប៉ុន្មានឆ្នាំដែរ ទើបបែកភ្នំពេញ?

**ឆ៖** ចាំមិនបានទេ បាទ។

**ស៖** សូមអរគុណ។ ក៏ប៉ុន្តែ បាទ ខ្ញុំសូមបន្តទៅមុខទៀត។ យើងបន្តទៅមុខទៀតត្រង់ទំព័រខ្មែរ ៥៨, ទំព័របារាំង៦៧ ទៅដល់ ៦៨, អង់គ្លេស៦៣។ លោកបានឆ្លើយនៅត្រង់នេះថា "ក្រោយពេលដែល

ធ្វើពេទ្យនោះ គឺគេចាត់តាំងខ្ញុំឲ្យបង្រៀនប្រជាជន ហើយឲ្យខ្ញុំធ្វើការព្យាបាលប្រជាជនទូទៅ"។ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ តើលោកចាប់ផ្ដើមបង្រៀនជំនាញពេទ្យទៅដល់អ្នកផ្សេងនោះ មុនឆ្នាំ៧៥, ៧៦ មិនថា ឆ្នាំណាទេ ឬក៏លោកបង្រៀនជំនាញពេទ្យគេនោះ ក្រោយឆ្នាំ៧៥ ឬក៏ ៧៦ ដែលលោកនិយាយនោះ?

[១១:២៥:២៥]

**ឆ៖** ខ្ញុំបង្រៀនពេទ្យនៅក្នុងតំបន់២០ គឺក្រោយឆ្នាំ៧៥ ក្រោយខ្ញុំចេញភ្នំពេញវិញបាទ ព្រោះខ្ញុំចេញភ្នំពេញវាពីរដង។ ម្ដងខ្ញុំនៅក្មេង ទៅវៀតណាម ចេញមកទៅវៀតណាម ក្រោយទៀតទៅរៀនភ្នំពេញទៀត ត្រឡប់ពីភ្នំពេញមក មកបង្រៀន -- ម្ដងហ្នឹងទៅបង្រៀនពេទ្យនៅតំបន់២០។ ហ្នឹងសូមអ្នកម្ចាស់សំណួរស្ដាប់ឲ្យបានបាទ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំដែរឬទេ តើលោកចាប់ផ្ដើមបង្រៀនជំនាញពេទ្យនោះ នៅពេលណាឲ្យបានជាក់លាក់? តើមុនបែកភ្នំពេញ ឬក៏ក្រោយបែកភ្នំពេញ?

**ឆ៖** ឯបង្រៀនពេទ្យហ្នឹងមុនបែកភ្នំពេញក៏ខ្ញុំបានបង្រៀន ក្រោយបែកក៏បានបង្រៀន។ ប៉ុន្តែរយៈបែក -- មុនបែក គឺការរៀនទៅតាមដំណើរ ចេះតិច បង្រៀនតិច អ្នកចេះបង្រៀនអ្នកមិនចេះ អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ អ្នកចេះខ្លាំងបង្រៀនអ្នកចេះតិច។ នោះលក្ខណៈប៉ុណ្ណឹងទេ។ ដល់ពេលខ្ញុំត្រឡប់ពីភ្នំពេញវិញ បានខ្ញុំមានសិទ្ធិទទួលខុសត្រូវវគ្គបណ្ដុះបណ្ដាលពេទ្យ នៅក្នុងតំបន់២០។ សូមជ្រាបបាទ។

**ស៖** សូមអរគុណ។ ប្រសិនបើនៅត្រង់ទំព័រដដែលនេះ បើសិនយើងមើលទំព័រដដែលនេះ លោកបានបន្តឆ្លើយថា "ខ្ញុំបានបង្រៀនអ្នកផ្សេងលើសុជីវធម៌នៃការរស់នៅ និងបញ្ហាពេទ្យ ហើយខ្ញុំដឹងថា គោលនយោបាយរបស់បក្សនោះ វាសមរម្យត្រឹមត្រូវណាស់។ ដូច្នេះហើយទើបខ្ញុំបង្រៀនគោលនយោបាយនេះទៅដល់អ្នកផ្សេង។ ខ្ញុំបង្រៀនពួកគេឲ្យយល់អំពីតួនាទីរបស់ពេទ្យ។ ប្រសិនបើធ្វើជាពេទ្យនោះ ទទួលខុសត្រូវខាងព្យាបាលមនុស្ស ហើយត្រូវដឹងថា បើសិនជាមានអ្នកជំងឺស្លាប់ក្រោមការព្យាបាលរបស់ខ្លួននោះ ក៏ត្រូវទទួលខុសត្រូវដោយខ្លួនឯងផងដែរ។ ខ្ញុំក៏បានបង្រៀនគេអំពីជំងឺ ថាតើត្រូវព្យាបាលជំងឺមួយចំនួននោះដោយរបៀបណា"។ យើងអាចមើលចំណុចនេះ ត្រង់ទំព័រ៥៨ ជាភាសាខ្មែរត្រង់ទំព័រ -- ត្រង់នាទីម៉ោង១៣ នាទីត្រង់៤១ ម៉ោង ១៣:៤១:១០ តើលោកចាំទេថាលោកបានឆ្លើយដូច្នេះ ហើយលោកបាននិយាយបង្រៀនអំពីគោលនយោបាយបក្ស គឺគោលនយោបាយដែលលោក

បង្រៀននោះ គឺគោលនយោបាយរបស់បក្សមុនបែកភ្នំពេញតើអ៊ីចឹងដែរឬទេ? លោកចាំចំណុចដែលលោកឆ្លើយដូច្នេះដែរឬទេ?

[១១:២៨:៥៧]

**ឆ៖** ខ្ញុំស្តាប់អត់បានបាទ។

**ស៖** ខ្ញុំសួរលោកមួយដំណាក់ម្តងៗ។ នៅទីនេះលោកបាននិយាយថា លោកបានបង្រៀនអំពីក្រមសីលធម៌ក្នុងនាមជាពេទ្យ ក្រឹត្យក្រមពេទ្យ ហើយគោលនយោបាយបក្សនោះ លោកបង្រៀនថាល្អណាស់។ គឺគោលនយោបាយនោះ ដែលលោកយល់ថា ល្អនោះ គឺគោលនយោបាយមុនឆ្នាំ៧៥ហ្នឹងមែនដែរឬទេ ក្រឹត្យក្រមគោលនយោបាយរបស់នុ៎ង?

**ឆ៖** ឈ្មោះថាល្អ ដែលខ្ញុំយល់ថាល្អ គឺមុនរំដោះ៧៥។ អ៊ីចឹងគោលការណ៍របស់បក្សហ្នឹងមើលការងារដូចជាល្អ បើសិនជាមិនល្អពីខាងដើម ប្រហែលជាអត់នៅជាមួយទេបាទ។

**ស៖** តើគោលនយោបាយហ្នឹងវាដូចគ្នានឹងគោលនយោបាយក្រោយឆ្នាំ៧៥ ដែរឬទេ គឺផ្អែកទៅតាមការបណ្តុះបណ្តាលដែលលោកទទួលបាននៅភ្នំពេញ? តើគោលនយោបាយមុន៧៥ និងក្រោយ ៧៥ ហ្នឹងដូចគ្នាដែរឬទេ?

**ឆ៖** សូមបញ្ជាក់ម្ចាស់សំណួរការពិត។ ខ្ញុំរឿងរៀននយោបាយ ខ្ញុំមិនដែលបង្រៀនទេ គ្រាន់តែចូលអប់រំតាមភូមិករណ៍មាន បើថាវគ្គនយោបាយ ខ្ញុំមិនដែលបង្រៀនទេ គឺបង្រៀនៗតែពេទ្យប៉ុណ្ណោះឯង។ សូមជ្រាបបាទ។

**ស៖** អានេះគឺយើងកំពុងតែនិយាយ អំពីការបង្រៀនក្រមសីលធម៌ជាពេទ្យ គឺថាពេទ្យត្រូវមានការទទួលខុសត្រូវ អានេះខ្ញុំកំពុងតែនិយាយពីបញ្ហានេះ។ តើគោលនយោបាយក្រោយឆ្នាំ៧៥ តាមដែលលោកដឹង តើម៉េចដែរ?

[១១:៣១:១០]

**ឆ៖** ត្រង់ហ្នឹងខ្ញុំបានបញ្ជាក់ថា គោលនយោបាយរបស់បក្សពីមុន៧៥ ល្អមនឹងរស់កើត ធ្វើបានប៉ុន្តែប្លែកៗគឺក្រោយ៧៥ ខ្ញុំមិនយល់បាទ។ ហ្នឹងសូមជ្រាបបាទ។

**ស៖** ឥឡូវនេះយើងនិយាយអំពីពេទ្យ ហើយលោកគឺជាពេទ្យ ហើយលោកបាននិយាយអំពីបរិបទនៃគោលនយោបាយដែលលោកយកមកនិយាយនេះ។ ឥឡូវនេះ ខ្ញុំសូមបន្ត ក្នុងទំព័រ៥៨, ៥៩ ភាសាខ្មែរ បារាំង៦៧, ៦៨ ហើយអង់គ្លេស ៦៤ គឺនៅខាងក្រោមម៉ោង ១៣:៤៤ នាទី លោកបាន

និយាយថា "បន្ទាប់ពីប្រជា -- មនុស្សដែលដឹងថា ខ្ញុំទទួលបានជំនាញ គេចង់ឲ្យខ្ញុំបន្តការងារនេះ ហើយខ្ញុំមានសាច់ញាតិរបស់ខ្ញុំជាពេទ្យ។ ហើយក្នុងនាមជាពេទ្យ ដែលមានជំនាញពេទ្យគេកោតសរសើរខ្ញុំ មានអ្នកដទៃកោតសរសើរខ្ញុំជាច្រើន ហើយគេស្នើសុំឲ្យខ្ញុំចូលរួមនៅក្នុងការព្យាបាលអ្នកជំងឺ ឬក៏ព្យាបាលអ្នកឈឺ"។ នេះគឺជាប្រវត្តិរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំសូមសួរលោក តើអ្វីដែលលោកនិយាយហ្នឹងគឺមុនឆ្នាំ៧៥ ឬក៏ក្រោយ៧៥ គឺថា ដែលគេកោតសរសើរលោកដែលមានជំនាញពេទ្យហ្នឹង តើការកោតសរសើរហ្នឹងមុន៧៥ ឬក្រោយ៧៥?

**ឆ៖** ការនិយាយគឺមុន៧៥ បាទ។

[១១:៣៣:១១]

**ស៖** ប្រសិនបើគេកោតសរសើរលោកមុនឆ្នាំ៧៥ តើគេនៅតែបន្តកោតសរសើរជំនាញពេទ្យរបស់លោកក្រោយឆ្នាំ៧៥ ដែរឬទេ? ជាពិសេសគឺក្រោយពេលដែលលោកមកទីក្រុងភ្នំពេញ ដើម្បីមកទទួលការបណ្តុះបណ្តាលផ្នែកពេទ្យនោះបន្ថែមទៀត តើគេនៅបន្តកោតសរសើរលោកទៀតទេ?

**ឆ៖** សូមបញ្ជាក់ត្រង់ណេះ ខ្ញុំមិនបានដើរជួបគេជួបឯងថា សរសើរ ឬមិនសរសើរ ខ្ញុំអត់ដឹងទេ ព្រោះថា អ្នកសរសើរពីខាងក្រៅ ឯខ្ញុំគ្រាន់ទទួលនាទីពេទ្យ។ ដូច្នេះការធ្វើនេះទាំងប្រជាជនទាំងខ្ញុំ ដល់ថ្ងៃភ័យរួចទៅហើយ ក្រោយ៧៥ សុទ្ធតែពោរពេញទៅដោយការភ័យហើយ។ ខ្ញុំក៏នៅតំបន់ខ្លះ ហើយក៏នៅមន្ទីរពេទ្យរុស្ស៊ីខ្លះ។ ហ្នឹងសូមម្ចាស់សំណួរឲ្យបានមេត្តាជ្រាបបាទ។

[១១:៣៤:០៨]

**ស៖** ប្រហែលមានការបកប្រែមានបញ្ហា។ ខ្ញុំចង់សួរថា លោកក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ត្រូវបានគេសរសើរដោយសារតែជំនាញពេទ្យរបស់លោកនៅក្រោយឆ្នាំ៧៥ ឬក៏អត់? លោកនិយាយថាគេសរសើរលោកនៅមុនឆ្នាំ៧៥ ប៉ុន្តែខ្ញុំចង់ដឹងថាគេនៅតែសរសើរ គេនៅតែពេញចិត្តដោយសារជំនាញពេទ្យរបស់លោកក្រោយឆ្នាំ៧៥ ទៀត ឬមួយក៏យ៉ាងណា?

**ឆ៖** ជំនាញពេទ្យរបស់ខ្ញុំ។ សូមនិយាយរឿងពិតរបស់ខ្ញុំ បានន័យថាក្នុងមុន៧៥ ក៏ប្រជាជនសរសើរ ប្រើប្រាស់ ក្រោយ៧៥ ក៏នៅតែប្រជាជនប្រើនៅតែប្រើ រហូតដល់ឥឡូវនៅតែប្រើ ព្រោះគេទទួលស្គាល់ថាការប្រើរបស់ខ្ញុំ ពិតជាមិនគ្រោះថ្នាក់ដល់គេ។ ហ្នឹងសូមម្ចាស់សំណួរជ្រាបបាទ។

**ស៖** នៅពេលដែលលោកមកទីក្រុងភ្នំពេញ ដើម្បីទទួលការបណ្តុះបណ្តាលពេទ្យបន្ថែម។ ខ្ញុំដឹងថា នៅពេលហ្នឹង លោកក៏មានការបណ្តុះបណ្តាលផ្នែកទ្រឹស្តីនយោបាយ គឺបន្ថែមទៅលើពេទ្យ។ តើ

លោកចាំដែរឬទេ ថាលោកទទួលការបណ្តុះបណ្តាលហ្នឹង ប្រហែលជាប៉ុន្មានខែ? គឺការបណ្តុះបណ្តាលដែលលោកទទួលបាននៅទីក្រុងភ្នំពេញ គឺការបណ្តុះបណ្តាលផ្នែកពេទ្យនោះ តើលោកបណ្តុះបណ្តាលប៉ុន្មានខែ? ឬក៏ប៉ុន្មានឆ្នាំ?

[១១:៣៥:៥២]

**ឆ៖** អាហ្នឹង បើនិយាយពីខ្លួនឯង បណ្តុះបណ្តាលវិជ្ជាពេទ្យហ្នឹងខ្លួនឯងហ្នឹង គឺដូចខ្ញុំនិយាយក្នុងឯកសារខ្ញុំរួចហើយ គឺថាបើវគ្គត្រូវប្រចាំ -- វគ្គដែលត្រូវឡើងទៅរៀននោះ គឺរយៈ១ឆ្នាំ។ ប៉ុន្តែដល់ៗ ខ្ញុំបានរៀនបានត្រឹមតែ៩ខែ ឬក៏១០ខែ ប៉ុណ្ណោះឯង។ ប៉ុន្តែបើសិនជា -- បើសិនខ្ញុំនិយាយពីលក្ខណៈដែលបង្រៀននៅក្នុងតំបន់ គឺខ្ញុំបង្រៀនគេ មួយវគ្គៗ ស្មើនឹង៣ខែ គឺថាវគ្គបណ្តុះបណ្តាលពេទ្យ វិជ្ជាជីវពេទ្យឱ្យស្គាល់អំពីដំណើរលក្ខណៈការពារ មិនមែនជាលក្ខណៈមន្ទីរពេទ្យព្យាបាលទេ គ្រាន់តែឱ្យស្គាល់ថាអ្នកហ្នឹងអាចស្គាល់វិជ្ជាពេទ្យ អាចប្រើប្រាស់បណ្តោះអាសន្ន នៅពេលដែលគ្មានគេនោះឯង។ តែតាំងថាឧទ្ទេសនាមថា ឱ្យគេជាអ្នកនេះ អ្នកនោះ អត់មានសិទ្ធិទេ។ ព្រោះកាលណោះ ខ្ញុំធ្វើដោយការប្រយ័ត្នប្រយែងបំផុត។ ព្រោះបក្សបដិវត្តន៍សម័យនោះ កាលណាធ្វើអី ច្បាស់ហ្នឹង បើមិនច្បាស់ទេ យើងនឹងត្រូវគ្រោះថ្នាក់ជីវិត។ ហ្នឹងសូមជ្រាបបាទ។

[១១:៣៧:០៧]

**ស៖** តើលោកអាចប្រាប់យើងបានដែរឬទេ ថាតើលោកបំពេញការងារជាពេទ្យហ្នឹង ប្រហែលជាប៉ុន្មានឆ្នាំ មុនលោកមកទីក្រុងភ្នំពេញនោះ? គឺថាមុនពេលដែលលោកមកភ្នំពេញ ដើម្បីទទួលការបណ្តុះបណ្តាលបន្ថែមនោះ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំចាំមិនបានទេបាទ។

**ស៖** លោកបាននិយាយថា លោកបានទៅរៀន៣ឆ្នាំ នៅវៀតណាម គឺរៀនពេទ្យ។ តើលោកចាំដែរឬទេ ថាបន្ទាប់ពីត្រឡប់មកពីវៀតណាមវិញនោះ តើលោកអនុវត្តជំនាញពេទ្យហ្នឹងប៉ុន្មានឆ្នាំ មុនពេលដែលលោកមករៀនពេទ្យបន្ថែមទៀតនៅទីក្រុងភ្នំពេញ?

**ឆ៖** តាំងពីចេញពីវៀតណាមមក គឺខ្ញុំទទួលការងារពេទ្យនៅក្នុងតំបន់២០រហូត។ អឺចឹង ថាឆ្នាំណា? ខែណានោះ? ខ្ញុំមិនបានចាំទេបាទ។

[១១:៣៨:៣២]

**ស៖** តើលោកចាំដែរឬទេ តើនៅពេលនោះ លោកមានអាយុប៉ុន្មានដែរ?

**ឆ៖** ខ្ញុំមិនអាចចាំបានទេបាទ។

**ស៖** តើលោកចាំទេ នៅឆ្នាំ៧៥, ៧៦ ហ្នឹង លោកអាយុប្រហែលប៉ុន្មាន?

**ឆ៖** ខ្ញុំមិនអាចឆ្លើយបាន ត្រង់ហ្នឹង ព្រោះខ្ញុំមិនបានចាំបាទ។

**ស៖** តើលោកអាចប្រាប់ទេ ថាលោកកើតនៅឆ្នាំណាដែរ?

**ឆ៖** ត្រង់ហ្នឹង លោកបានសួររួចហើយ បានដឹងរួចហើយថា ខ្ញុំឆ្នាំ -- កើត ឥឡូវអាយុបច្ចុប្បន្នអាយុខ្ញុំ ៦១ បាទ។

**ស៖** ខ្ញុំចង់ដឹងថា តើលោកធ្វើការនៅក្នុងផ្នែកពេទ្យហ្នឹង ប៉ុន្មានឆ្នាំ? ព្រោះក្នុងលិខិតពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក លោកនិយាយថា លោកមិនមានចំណេះដឹងពេទ្យ ហើយលោក ឥឡូវនេះ លោកនិយាយថា លោករៀនពេទ្យ ហើយទទួលការបណ្តុះបណ្តាលផ្នែកពេទ្យ តាំងពីលោកមានអាយុជាង១០ឆ្នាំ។ ដូច្នេះ ត្រឹមឆ្នាំ៧៥ ខ្ញុំព្យាយាមស្វែងរកឲ្យឃើញ ថាតើលោកធ្វើពេទ្យហ្នឹងប្រហែលជាប៉ុន្មានឆ្នាំ? ថាតើលោកមានប្រវត្តិខាងពេទ្យ ឬក៏ចំណេះដឹងពេទ្យហ្នឹងប្រហែលជាប៉ុន្មានដែរនៅពេលត្រឹមឆ្នាំហ្នឹង? ដូច្នេះសូមលោកជម្រាបយើង ថាតើលោកកើតនៅឆ្នាំណា?

**ឆ៖** ត្រង់ហ្នឹង បើនិយាយអំពីរើករកអាយុរបស់ខ្ញុំពិបាករក ព្រោះខ្ញុំដើរផ្លាស់ៗទៅខាងនេះបន្តិចទៅនោះបន្តិច ម្ល៉ោះហើយខ្ញុំ ធ្វើឲ្យខ្ញុំចាំអាយុមិនបាន។ ខ្ញុំកើតនៅឆ្នាំ១៩៥១ បាទ។

**ស៖** ខ្ញុំគ្រាន់តែចង់ឆ្ងល់ ហេតុអ្វីបានជាលោកផ្លាស់ប្តូរពីមួយពេលទៅមួយពេល ព្រោះថា អ្វីដែលខ្ញុំគិត គឺថាលោកហាក់ដូចជាចង់ -- ហាក់ដូចជាចង់កែប្រែ ឬក៏ចង់ផ្លាស់ប្តូរនូវអាយុរបស់លោក?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:៤១:២០]

**លោក វ៉ាំងសង់ វ៉ាយជ៍ ដេស្សាឯល៖**

មានចំណុចពីរ លោកប្រធាន។ ទី១ ខ្ញុំមិនយល់ទេ ថាតើគាត់ចង់បានអី? ទី២ សាក្សីហាក់ដូចជាគាត់បានប្រាប់ហើយថាគាត់ឆ្នាំ -- គាត់កើតឆ្នាំ៥១ គាត់មិនបានប្តូរឆ្នាំកំណើតទេ គាត់គិតថា អាយុរបស់គាត់ទេដែលប្រែប្រួលនោះ។

**លោក ម៉ៃខល កាណាវ៉ាស៖**

លោកប្រធាន ខ្ញុំសូមនិយាយថា នេះគឺជាបញ្ហានៃការសាកសួរ ថាតើគាត់គួរឲ្យទុកចិត្តក្នុងនាម

ជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏អត់ ដូចដែលមេធាវី នួន ជា បានធ្វើអ៊ីចឹង។ ហេតុដូច្នេះហើយទើបមានសំណួរបែបនេះ។ ព្រោះថាមានការផ្លាស់ប្តូរ ហើយឥឡូវនេះគេប្រាប់យើងថា គាត់ផ្លាស់ប្តូរនូវកាលថ្ងៃខែឆ្នាំកំណើត។ អានេះគឺជាអ្វីដែលយើងស្តាប់យល់តាមភាសាអង់គ្លេស គឺគាត់ផ្លាស់ប្តូរថ្ងៃខែឆ្នាំកំណើត។ ប្រសិនបើមានការផ្លាស់ប្តូរបែបនេះមែន ខ្ញុំចង់សួរថា ហេតុអ្វីបានជាគាត់ចាំបាច់ត្រូវផ្លាស់ប្តូរឆ្នាំកំណើត? ថាតើមានហេតុផលអ្វី? ដូច្នេះ ខ្ញុំចោទសួរនេះ គឺដើម្បីស្វែងរកនូវការ -- ភាពអាចជឿទុកចិត្តបានចំពោះដើមបណ្តឹងមួយនេះ។ ដូច្នេះខ្ញុំស្នើសុំឱ្យមានការបញ្ជាក់ពីដើមបណ្តឹងរដ្ឋប្បវេណី ថាតើគាត់មានផ្លាស់ប្តូរនូវថ្ងៃខែឆ្នាំកំណើត ឬក៏អត់? ឬមួយក៏គាត់ប្រើប្រាស់ថ្ងៃខែឆ្នាំកំណើតសម្រាប់ឱកាសផ្សេងៗ ឬក៏គោលដៅផ្សេងៗគ្នា ឬមួយក៏បុគ្គលណាផ្សេងៗដែរឬអត់?

[១១:៤២:៥៦]

**លោក អែម អឿន៖**

**ឆ៖** ត្រង់ហ្នឹង ខ្ញុំសូមតបនឹងសំណួរបន្តិច ព្រោះថា លោកព្រះរាជអាជ្ញា ក៏គាត់មានប្រសាសន៍ហើយ ខាងមេធាវីរបស់ខ្ញុំគាត់បានបញ្ជាក់ហើយថា ការផ្លាស់ប្តូរអាយុសម្រាប់ខ្ញុំមិនមានទេ បើការផ្លាស់ប្តូរពេលវេលាហ្នឹងមាន។ បើអាយុខ្ញុំនិយាយថា ៥៣ គឺ ៥៣ -- បើ ៥១ គឺ៥១ រហូតបាទ។ មិនដែលប្រើពាក្យថាម៉េច ខ្លាចខុសពីហ្នឹងទេ។ ដូច្នេះការកែប្រែអត់មានទេខ្ញុំបាទ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** គឺខ្ញុំទទួលយក។ ដូច្នេះប្រសិនបើលោកកើតឆ្នាំ១៩៥១ ហើយលោកចាប់ផ្តើមរៀនពេទ្យនៅពេលដែលលោកអាយុប្រហែលដប់ឆ្នាំ គឺថាលោកទទួលការបណ្តុះបណ្តាលនៅពេលអាយុ១០ហ្នឹង គឺនៅឆ្នាំ៧៥ គឺថាលោកប្រហែលជាមានការ មានបទពិសោធន៍ផ្នែកពេទ្យប្រហែលជា១៣ ឬក៏១៤ ឆ្នាំ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១១:៤៤:០១]

**ឆ៖** សូមតប។ ខ្ញុំមិនបាននិយាយថា រៀននៅអាយុប៉ុន្មានៗនោះទេ តែខ្ញុំបាននិយាយប្រាប់ថា ខ្ញុំចាប់ផ្តើមរៀនពេទ្យតាំងពីខ្ញុំដឹងក្តី ដោយសារឪពុកមាខ្ញុំឃើញម្តាយខ្ញុំក្រពេក គាត់ក៏ចង់ឱ្យខ្ញុំចេះ គាត់ក៏យកទៅទីក្រុងភ្នំពេញ។ អាហ្នឹងសូមស្តាប់បាទ។

**ស៖** ឥឡូវនេះខ្ញុំត្រឡប់ទៅលើអ្វីដែលលោកបានឆ្លើយ គឺចម្លើយដែលលោកផ្តល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចង់ឱ្យលោកពិនិត្យមើលទៅលើចម្លើយហ្នឹង ហើយថាតើលោកគាំទ្រនូវចម្លើយ

ព្រោះថាអ្វីដែលលោកនិយាយនៅទីនេះ គឺដើម្បីគោលដៅក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី។ "នៅក្នុងឆ្នាំ៧៥ គេចាត់តាំងឲ្យខ្ញុំទៅធ្វើជាពេទ្យ ដើម្បីព្យាបាលអ្នកជំងឺ។ ទោះបីថាខ្ញុំមិនមានចំណេះដឹងពេទ្យក៏ដោយ"។ ផ្អែកទៅលើចម្លើយដែលលោកផ្តល់នៅក្នុងតុលាការ គឺនៅថ្ងៃមុន គឺថ្ងៃមុន និងថ្ងៃនេះ តើលោកនៅរក្សាចម្លើយថាត្រឹមឆ្នាំ៧៥ លោកមិនមានចំណេះខាងពេទ្យ? តើលោកនៅរក្សាចម្លើយនេះដែរឬទេ?

**ឆ៖** ខ្ញុំសូមរក្សាចម្លើយដែលខ្ញុំសរសេរជាៗព័ត៌មានសូមរក្សាទាំងអស់។ ពាក្យបន្ថែមក្រោមការផ្តិតមេដៃរបស់ខ្ញុំក៏នៅតែខ្ញុំទទួល ដល់ថ្ងៃនេះក៏នៅខ្ញុំទទួល ព្រោះអ្វីដែលពិត គឺត្រូវតែទទួល។

ដូច្នេះខ្ញុំសូមបញ្ជាក់ សូមលោកតុលាការសូមបញ្ជាក់ប្រាប់គាត់ឲ្យបានច្បាស់សិនថា លោកខាងមេធាវី លោកបាននិយាយក្នុងតុលាការរួចហើយថា ដើមបណ្តឹងម្តងនេះហាក់ដូចជាមានពេលប្លែក ព្រោះខ្ញុំដើម្បីកុំឲ្យមនុស្សសង្ស័យ គឺខ្ញុំសូមយកព្រះជាសាក្សី។

[១១:៤៦:១០]

**ស៖** ឥឡូវនេះ យើង--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីតំណាងបណ្តឹងរដ្ឋប្បវេណី!

**លោក គីម ម៉េងឃី៖**

សូមលោកប្រធានមេត្តាផ្អាកការសួររបស់លោកមេធាវីការពារក្តីរបស់លោក អៀង សារី បន្តិចសិន ព្រោះខ្ញុំយល់ថាកូនក្តីរបស់ខ្ញុំមានអារម្មណ៍ក្តុកក្តួល ហើយគាត់មិនអាចឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវីភ្លាមៗបន្តទៀតទេបាទ។ សូមអរគុណលោកប្រធាន។

**លោក ម៉ៃខល កាណាវាស៖**

យើងមិនមានការជំទាស់អ្វីទេលោកប្រធាន។

[១១:៤៧:១៧]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកដែរហើយ ខ្វះ១៥នាទី ហើយដោយសារបញ្ហានៃការរំជួលចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះក្នុងការឆ្លើយតបទៅនឹងសំណួរដេញដោលដោយសារមេធាវីការពារក្តី ឃើញថាមិនអាចដំណើរការបាន ហើយពេលនេះអង្គជំនុំជម្រះសម្រេចប្រកាសសម្រាក

ដើម្បីពិសារអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងពីររសៀលនេះសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់ទីកន្លែងសម្រាកដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ក្នុងអំឡុងពេលឈប់សម្រាកពិសារអាហារថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ត្រឡប់ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងពីររសៀល។

អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនជ្រាបថា នៅរសៀលនេះ និងនៅរសៀលថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការនៅពេលរសៀល គឺចាប់ផ្តើមពីម៉ោងពីរ ដោយហេតុនៅរសៀលនេះ និងនៅរសៀលថ្ងៃស្អែក នៅក្នុងពេលឈប់សម្រាកពិសារអាហារថ្ងៃត្រង់ ជនជាប់ចោទ អៀង សារី និងត្រូវទទួលនូវការត្រួតពិនិត្យសុខភាពពីសំណាក់អ្នកជំនាញខាងជំងឺមនុស្សចាស់ ដែលកិច្ចការនេះត្រូវការពេលវេលាសមស្របសម្រាប់បំពេញភារកិច្ចរបស់អ្នកជំនាញ។

[១១:៤៨:៤៥]

សូមអញ្ជើញមេធាវី!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ លោក នួន ជា ស្នើសុំអនុញ្ញាតតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងខាងក្រោម ដោយសារតែគាត់ឈឺខ្នង ឈឺក្បាល និងមិនអាចផ្តង់អារម្មណ៍បាន។ ហើយយើងបានរៀបចំនូវលិខិតលះបង់សិទ្ធិ និងដាក់ជូនទៅអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលនេះ ដោយមូលហេតុមានបញ្ហាសុខភាព មិនអាចអង្គុយយូរបានក្នុងបន្ទប់សវនាការ។

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់ពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក នួន ជា បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីលោក នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការកិច្ចសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ នៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងពីររសៀល។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥១ នាទី ដល់ម៉ោង ១៤:០៣ នាទី)*

[១៤:០៣:២១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក អៀង សារី ក្នុងការបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះសូមរំឭកដាស់តឿនដល់ដើមបណ្តឹងរដ្ឋប្បវេណី លោក អែម អឿន សូមលោកអត់ធ្មត់នៅក្នុងការឆ្លើយតបទៅនឹងរាល់សំណួរដែលសួរ។ អង្គជំនុំជម្រះបានរំឭក និងជម្រាបលោកហើយថា នីតិវិធីនៃការសួរដេញដោលនៅតាមនីតិវិធីតុលាការ គឺត្រូវតែប្រព្រឹត្តទៅតាមរបៀបដែលបានធ្វើកន្លងមកនេះ។ អាស្រ័យហេតុនេះ សូមលោកពង្រឹងស្មារតី ហើយនិងអត់ធ្មត់ក្នុងការស្តាប់ ហើយនិងឆ្លើយតប

ទៅនឹងសំណួរ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថា សូមឲ្យលោកស្ដាប់សំណួរឲ្យបាន ហើយឆ្លើយតបទៅនឹងភាពចាំបាច់និងពេញលេញ ទៅនឹងក្របខ័ណ្ឌនៃសំណួរដែលសួរបានហើយ ជៀសវាងលោកធ្វើអត្ថាធិប្បាយវែងអន្លាយ ឬក៏និយាយទៅមិនឆ្លើយតបទៅនឹងសំណួរ សំណួរដដែលនេះ នឹងសួរលោកជាបន្តទៀត។ អ៊ីចឹងធ្វើឲ្យពេលវេលាហ្នឹងអាចអូសបន្លាយ ខាតពេលវេលាឥតប្រយោជន៍។

អង្គជំនុំជម្រះ សូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក អៀង សារី ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោល ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអញ្ជើញ!

[១៤:០៥:១២]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ ភាគីទាំងអស់ អស់លោក លោកស្រី នៅក្នុងបន្ទប់សវនាការ និងក្រៅបន្ទប់សវនាការ។

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី។ យើងសូមបន្តត្រង់ចំណុចដែលយើងទុកចោល។ យើងនិយាយសក្ខីកម្មរបស់លោកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ អង់គ្លេសទំព័រ៨០, បារាំង ៩២-៩៣ ហើយនិងអង់គ្លេស ៨៩, ខ្មែរ ៨០។ ចម្លើយរបស់លោកបានឆ្លើយនៅក្នុងហ្នឹង ហើយលោកបាននិយាយចំណុចហ្នឹងផងដែរ នៅពេលដែលមេធាវីការពារក្ដី នួន ជា បានសួរ "ខ្ញុំបានឃើញបរទេសចិន និងកូរ៉េមកផ្ដល់ការបណ្ដុះបណ្ដាលពេទ្យនៅមន្ទីរពេទ្យ ហើយលោក ជួន ជឿន នោះមានជំនាញខាងពេទ្យ។ គាត់បានផ្ដល់ការបណ្ដុះបណ្ដាលខាងពេទ្យ ហើយខ្ញុំស្គាល់គាត់ ប្រសិនបើគាត់មកឈរនៅក្នុងបន្ទប់ក្នុងថ្ងៃនេះ។ គាត់មានមាឌធំល្មម គាត់និយាយអំពីបញ្ហាវេជ្ជសាស្ត្រពេទ្យ កូរ៉េ និងចិន នោះក៏បានបង្រៀនយើងបច្ចេកទេសវះកាត់ផងដែរ"។ តាមរយៈចម្លើយនេះ គឺបានបង្ហាញថា លោក ជួន ជឿន នោះក៏បានផ្ដល់ការបណ្ដុះបណ្ដាលលោកខាងផ្នែកពេទ្យផងដែរ។ តើត្រឹមត្រូវដែរឬទេ?

[១៤:០៦:៥៨]

**លោក អែម អឿន៖**

**ឆ៖** បាទ ត្រង់ហ្នឹងត្រឹមត្រូវបាទ។

**ស៖** នៅពេលដែលលោកនិយាយថា គាត់ពូកែជំនាញខាងពេទ្យនោះ តើលោកអាចជម្រាប

យើងខ្ញុំបានដែរឬទេ ថាតើគាត់នោះ ជួន ជឿន នោះបានពន្យល់ក្នុងពេលវគ្គអប់រំនោះ គាត់ក៏បានពន្យល់អំពីសារៈសំខាន់នៃការងាររបស់ពេទ្យ ដែលត្រូវធ្វើការព្យាបាលអ្នកជំងឺផងដែរ។ តើគាត់មានពន្យល់ចំណុចនេះដែរឬទេ?

**ឆ៖** គាត់មិនដែលបានពន្យល់ទេត្រង់ហ្នឹង។

**ស៖** តើគាត់មានពន្យល់ប្រាប់លោកថា តើលោកធ្វើយ៉ាងណាមិនចាំបាច់ធ្វើជាពេទ្យដែលល្អមួយរូបទេ ហើយក៏មិនចាំបាច់មានសីលធម៌ផងដែរ។ តើគាត់មានពន្យល់និយាយប្រាប់ឲ្យធ្វើអ៊ីចឹងទេ?

**ឆ៖** អត់ពាក្យនេះទេ អត់មានប្រើពាក្យនេះទេ។

**ស៖** តើការបណ្តុះបណ្តាលពេទ្យ ដែលលោកទទួលបានការអប់រំនៅទីក្រុងភ្នំពេញ ក្រោមការដឹកនាំរបស់ ជួន ជឿន ឬក៏ជនជាតិកូរ៉េ ឬជនជាតិចិន ឬអ្នកផ្សេងនោះ តើគេមានបង្រៀនបច្ចេកទេសពេទ្យត្រឹមត្រូវចំពោះលោកទេ តាមដែលលោកយល់នោះ?

**ឆ៖** លក្ខណៈបង្រៀនរបស់អស់លោកទាំងអស់នោះ គេរៀនតាមលក្ខណៈត្រឹមត្រូវក្នុងខណៈក្នុងពេលដែលខ្ញុំរៀនសូត្របាទ។

[១៤:០៨:៥០]

**ស៖** នៅពេលនេះយើងមើលសក្ខីកម្មថ្ងៃដដែល ទំព័រខ្មែរ ៩០ ទៅ ៩១, បារាំង ១០៤, អង់គ្លេស គឺទំព័រ ១០១ គឺត្រង់ម៉ោង ១៥:៥៣:២១ ត្រង់ប្រតិចារឹកថ្ងៃដដែល។ លោកបាននិយាយប្រាប់ថា "ពេលដែលខ្ញុំត្រឡប់ពីភ្នំពេញ រហូតដល់មូលដ្ឋានរបស់ខ្ញុំវិញ គឺតំបន់២០ ខ្ញុំទៅមន្ទីររបស់ខ្ញុំ ខ្ញុំទទួលបន្ទុកបណ្តុះបណ្តាលខាងពេទ្យ ហើយខ្ញុំក៏ទទួលបន្ទុកបច្ចេកទេសសាលានយោបាយ សម្រាប់ប្រជាជននៅតាមមូលដ្ឋានផងដែរ ហើយខ្ញុំក៏បានទៅពិនិត្យមន្ទីរពេទ្យមួយចំនួនផងដែរ នៅពេលដែលពេលវេលាអនុញ្ញាត។ ខ្ញុំទៅមើលនៅទីនោះ ថាតើមានជំងឺ រោគអ្វីកើតឡើងដែរឬទេ នៅតាមមន្ទីរស្រុក ឬក៏មន្ទីរតាមកន្លែងទាំងអស់នោះ"។ នៅពេលនេះ ខ្ញុំសូមឲ្យលោកមើលចម្លើយដែលលោកឆ្លើយនេះ។ ក្រៅពីការបណ្តុះបណ្តាលពេទ្យដែលលោកធ្វើការបណ្តុះបណ្តាលនៅតំបន់២០ តើលោកអាចពន្យល់ជូនយើងខ្ញុំផងបានដែរឬទេ តើវគ្គនយោបាយអ្វីខ្លះដែលលោកបានពន្យល់ បង្រៀនប្រជាជននៅតាមមូលដ្ឋានទាំងអស់នោះៗ?

**ឆ៖** ក្នុងចំណុចនេះ ខ្ញុំឧស្សាហ៍បានទៅណែនាំបងប្អូន ប្រជាពលរដ្ឋយើងឲ្យស្គាល់អំពីរបៀបកាលណោះ ខ្ញុំនិយាយអំពីខាងអនាម័យ។ បើសិនជាយើងមិនគិតពីអនាម័យទេ វានាំឲ្យខាតពេលវេលា

របស់យើងឈឺស្កាត់ កាលណាយើងមិនគិតអនាម័យវាធ្វើឲ្យយើងឈឺ ម្ល៉ោះហើយខ្ញុំអប់រំខាងអនាម័យ។ សូមអស់។

**ស៖** ដូច្នេះ នៅពេលដែលលោកនិយាយអំពីការបណ្តុះបណ្តាលនយោបាយ ជាពិសេសវគ្គនយោបាយដែលលោកបណ្តុះបណ្តាលនោះ គឺពាក់ព័ន្ធទៅនឹងបញ្ហាអនាម័យ និងស្ថានភាពរស់នៅឲ្យមានអនាម័យតែប៉ុណ្ណោះ។ នេះជាអ្វីដែលលោកឆ្លើយហ្នឹង តើមែនដែរឬទេ?

[១៤:១១:២២]

**ឆ៖** មែន។

**ស៖** តើនរណាជាអ្នកអនុញ្ញាតលោក ឲ្យទៅបណ្តុះបណ្តាលវគ្គនយោបាយនេះ?

**ឆ៖** គឺប្រធានមន្ទីរតំបន់២០ គឺលោក តាអ៊ុត។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ តើមន្ទីរណាខ្លះដែលលោកបានទៅពិនិត្យមើល ដើម្បីពិនិត្យមើលថា តើមានការរីករាលដាល ឬជំងឺកើតឡើងដែរឬទេ? មន្ទីរពេទ្យណាខ្លះដែលលោកបានទៅមើលនោះ?

**ឆ៖** ពេលដែលខ្ញុំទៅមើលភាគច្រើន ខ្ញុំចូលទៅដល់ឃុំ ពេទ្យរបស់ឃុំ តាមឃុំ។ ក្នុងនោះ ខ្ញុំចាំបានថា ខ្ញុំឧស្សាហ៍ដើរជាងគេគឺឃុំកញ្ជ្រោច នៅស្រុកកញ្ជ្រោច, ឃុំស្មោងខាងត្បូង, ស្មោងខាងជើង ក្នុងស្រុកកំចាយមារ។

**ស៖** តើមន្ទីរពេទ្យឃុំទាំងអស់នោះ គឺដូចគ្នាទៅនឹងមន្ទីរពេទ្យនៅតំបន់ដែលលោកតាំងនៅនេះដែរឬទេ ដែលតំបន់ដែលលោកព្យាបាលធ្វើជាពេទ្យនោះ?

[១៤:១៣:០១]

**ឆ៖** នៅតាមមន្ទីរពេទ្យរបស់ឃុំ លក្ខណៈព្យាបាលគ្នាមិនមានប្រើថ្នាំសម័យដូចនៅតាមមន្ទីរពេទ្យតំបន់ទេ គឺគ្នាប្រើភាគច្រើនគឺថ្នាំស្លដោយខ្លួនឯង គឺគេហៅថា "អាចម៍ទន្សាយ" នេះឯង។

**ស៖** សូមអរគុណ។ មុនឆ្នាំ៧៥ តើមានមន្ទីរពេទ្យអីត្រឹមត្រូវនៅតំបន់នោះដែរឬទេ?

**ឆ៖** នៅមុន៧៥ គឺក្នុងតំបន់មានមន្ទីរពេទ្យត្រឹមត្រូវ តំបន់២០ មានមន្ទីរពេទ្យត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ខ្ញុំចង់ផ្តោតទៅលើសក្ខីកម្មដែលលោកបានឆ្លើយរួចមកហើយ តែក្នុងនោះលោកបានឆ្លើយអំពីការវះកាត់។ សូមមើលទំព័រខ្មែរនៅប្រតិចារឹកនៅទំព័រ៧៨ ដល់ ៧៩, បារាំង ៩១, អង់គ្លេស៨៧ ប្រតិចារឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២។ ខ្ញុំសូមឲ្យលោកជួយបញ្ជាក់បំភ្លឺជូនយើងខ្ញុំ

បន្តិចលើចំណុចនេះ គេសួរថា "តើមានការវះកាត់មនុស្សដែរឬទេ ដែលជាការពិសោធនោះ?" លោកឆ្លើយថា "នៅថ្ងៃ -- នៅពេទ្យ១៧មេសា ឬក៏មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានពេទ្យមកពីតំបន់២០ វាជាពេទ្យមួយធំនៅសម័យនោះ។ ខ្ញុំមិនបានឃើញការវះកាត់ណាមួយនោះទេ ក៏ប៉ុន្តែខ្ញុំឃើញការវះកាត់នេះ គេវះកាត់សាកសពនៅមូលដ្ឋាន។ នៅពេលដែលអ្នកដែលត្រូវបានគេយកសម្លាប់ចោលនោះ គេយកទៅវះកាត់ទាំងរស់"។ បន្ទាប់មកលោកឆ្លើយថា "ការពិតនោះ គឺថា ខ្ញុំក៏ចូលរួមនៅក្នុងការងារនេះផងដែរ"។ ហើយលោកបានបន្តលើកឡើងផងដែរថា "អ្នកដែលសិក្សាទទួលការអប់រំនោះ គេឲ្យមើលថាតើគេកាត់គ្រឿងក្នុងនោះ កាត់ដៃ ម្រាមដៃនោះយ៉ាងម៉េច"។ នេះសូមឲ្យលោកផ្តល់ត្រង់ចំណុចហ្នឹងសិន។ លោកមិនបានឃើញមានការវះកាត់នៅក្នុងទីក្រុងភ្នំពេញនោះទេ។ តើត្រឹមត្រូវដែរឬទេ ចំណុចនេះ?

[១៤:១៦:០៥]

**ឆ៖** នោះជាពាក្យត្រឹមត្រូវ ក្នុងក្រុងភ្នំពេញ ខ្ញុំមិនឃើញវះកាត់ប្រភេទនោះទេ។ ហើយខ្ញុំជួបរឿងវះកាត់ ពិសោធនោះ កាត់ -- វះកាត់នៅក្នុងតំបន់២០។ ស្ថិតនៅក្នុងពេទ្យរបស់យោធាតំបន់២០។

**ស៖** តំបន់២០ នោះ គឺកន្លែងដែលលោកធ្វើការងារនុ៎ងហើយ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គឺជាកន្លែងរបស់ខ្ញុំធ្វើការ។ ធ្វើការ ខ្ញុំធ្វើនៅពេទ្យប្រជាជន។ ឯកន្លែងគេធ្វើហ្នឹង គឺនៅពេទ្យយោធា។ ដាក់ពិសោធនៅពេទ្យយោធា បាទ។

**ស៖** ក្រោយមកលោកបានឆ្លើយទៀតថា "ការពិតនោះ ខ្ញុំក៏ចូលរួមក្នុងការវះកាត់នោះផងដែរ"។ ដូច្នេះតើលោកអាចជួយពន្យល់យើងខ្ញុំបានដែរឬទេ តើលោកចូលរួមការពិសោធវះកាត់សាកសពទៅលើមនុស្សរស់នោះ ត្រឹមកម្រិតណាដែរ?

**ឆ៖** បើមនុស្សណាដែលបក្សគេកំណត់ត្រូវប្រហារជីវិតចោល គឺគេកាត់ពីដៃ រហូតដល់កាត់ទាំងអស់តែម្តង គឺកាត់ដល់ផ្តាច់ជីវិតចោលតែម្ដង។

[១៤:១៨:០២]

**ស៖** សូមឲ្យលោកជួយពន្យល់ត្រង់ចំណុចនេះ។ កាលពីមុននេះ ចំណុចមុននោះ គឺលោកបាននិយាយថា នៅពេលដែលលោកទៅមូលដ្ឋានវិញនោះ គឺលោកចាប់ផ្តើមបណ្តុះបណ្តាលមនុស្សលើបច្ចេកទេសពេទ្យ។ ហើយនៅក្នុងសក្ខីកម្មនេះ ក៏លោកបានបង្ហាញឆ្លើយផងដែរថា អ្នកដែលទទួលការអប់រំផ្នែកពេទ្យនោះ គឺគេក៏ឲ្យពួកគេនោះ ពិនិត្យមើលថាតើគេកាត់ម្រាមដៃនេះ ដោយរបៀបណាផងដែរ។

លោកបានឆ្លើយថា "លោកក៏បានចូលរួមក្នុងការពិនិត្យ និងការកាត់ដូច្នោះផង -- ការវះកាត់ដូច្នោះផងដែរ"។ តែនៅពេលនេះលោកបែបជានិយាយថា "លោកត្រឹមតែទៅមើលតែប៉ុណ្ណោះ នៅពេទ្យដែលលោកធ្វើការនុ៎ង។ ត្រឹមតែមើលតែប៉ុណ្ណោះ លោកអត់បានចូលរួមការកាត់ម្រាមដៃនោះទេ"។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ឲ្យបានស្មោះត្រង់ តើការពិសោធវះកាត់នោះ តើលោកបានចូលរួមត្រឹមកម្រិតណាដែរ?

[១៤:១៩:០៨]

**ឆ៖** ត្រង់ចំណុចនេះ ខ្ញុំនិយាយទៅតាមលក្ខណៈពេទ្យ ដែលខ្ញុំបានជួប និងបានធ្វើពីពេលនោះ គឺវះកាត់តាំងពីខ្នាតតូច រហូតដល់ខ្នាតធំ។ ខ្នាតតូច គឺការដោះគន្លាក់ដៃ គន្លាក់ម្រាមដៃ គន្លាក់ម្រាមជើង។ ឯខ្នាតធំ គឺកាត់ដល់ឆ្អឹង ឆ្អឹងដែលយើងត្រូវវះ ត្រូវអារកាត់តែម្តង។ អារកាត់ដោះគន្លាក់ គេហៅថា វះកាត់តូច។ បើយើងកាត់ឆ្អឹងដៃ ឬឆ្អឹងជើង គឺគេហៅថា កាត់កណ្តាលឆ្អឹង ពាក់កណ្តាលឆ្អឹង គេហៅថា មហាវះកាត់។ អ៊ីចឹង ការណ៍នេះ គឺខ្ញុំត្រួតពិនិត្យ មិនត្រឹមតែត្រួតពិនិត្យទេ ខ្ញុំបានបង្ហាត់ថា ចូលអ្នកវះកាត់ទាំងអស់ មុននឹងវះកាត់សាច់គេ ត្រូវមើលពីសរសៃឈាមឲ្យបានច្បាស់ជាមុនថា សរសៃធំស្ថិតនៅត្រង់ណា។ សរសៃតូច ស្ថិតនៅក្រោមស្រទាប់ទីប៉ុន្មានៗ សូមអស់លោកមើលឲ្យច្បាស់ហើយចាំបាន -- ចាំការធ្វើ។ ទោះបីបក្សអនុញ្ញាតថា ឲ្យអ្នកឯងវះដល់ប្រហារជីវិតក៏ដោយចុះ ក៏ប៉ុន្តែអ្នកឯងត្រូវតែ ទទួលខុសត្រូវពីលក្ខណៈបច្ចេកទេសរបស់អ្នកឯងឲ្យច្បាស់"។ ហ្នឹងខ្ញុំបានមានប្រសាសន៍អ៊ីចឹងមែន បាទ។

**ស៖** បើសិនជាលោកនៅទីនោះត្រឹមតែសង្កេតមើលតែប៉ុណ្ណោះ។ តើលោកអាចជម្រាបទេ អ្នកណាជាអ្នកអញ្ជើញលោកឲ្យទៅត្រឹមតែសង្កេតមើលការវះកាត់តែប៉ុណ្ណោះ ដោយសារតែលោកមានបទពិសោធន៍ត្រឹមតែអ្នកដែលទទួលការបណ្តុះបណ្តាលផ្នែកពេទ្យតែប៉ុណ្ណោះ ក្នុងរយៈពេល១០ជាងឆ្នាំ ១៤ឆ្នាំនេះ នោះ?

[១៤:២០:៥១]

**ឆ៖** ត្រង់ហ្នឹងលោកម្ចាស់សំណួរគួរយល់បានហើយ គឺថា ខ្ញុំថាអម្បាញ់មិញថា បើសិនជាបុគ្គលណាដែលបក្សសម្រេចឲ្យប្រហារជីវិត ដូច្នេះការធ្វើនេះគោរពបក្សទាំងអស់។ បាទ សូមៗជ្រាបបាទ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណីខ្ញុំសួរសំណួរជាក់លាក់ លោកនៅតំបន់២០ លោកនៅទីនោះ

បណ្តុះបណ្តាលវគ្គបច្ចេកទេសពេទ្យ និងវគ្គនយោបាយមនោគមន៍វិជ្ជាទៅដល់អ្នកផ្សេង។ ខ្ញុំសួរឲ្យលោកឆ្លើយឲ្យបានជាក់លាក់ តើនរណាគេជាអ្នកអញ្ជើញលោកទៅធ្វើការពិនិត្យការវះកាត់នៅទីនោះ? សូមឲ្យលោកផ្តល់ឈ្មោះអ្នកអញ្ជើញលោកទៅពិនិត្យការវះកាត់នៅទីនោះ។

**ឆ៖** អ្នកដែលអនុញ្ញាតឲ្យខ្ញុំនាំសិស្សានុសិស្សទៅមើលនៅទីនោះ គឺបក្សរបស់តំបន់២០ ជាអ្នកសម្រេច។ បន្ទាប់មក គឺបក្សរបស់ប្រចាំ បក្សប្រចាំពេទ្យនេះតែម្តង។ សូមម្ចាស់សំណួរជ្រាបបាទ។

[១៤:២២:១៥]

**ស៖** ផ្អែកទៅលើចម្លើយនេះ ខ្ញុំសូមសួរបញ្ជាក់។ លោកនិយាយថា លោកទៅទីនោះដោយស្ម័គ្រចិត្ត ដើម្បីទៅសង្កេតមើលការវះកាត់ ឬក៏គេជាអ្នកចាត់តាំងឲ្យលោកទៅ?

**ឆ៖** ត្រង់ណេះសូមម្ចាស់សំណួរជ្រាបថា ក្នុងនាមយើងជាលោកគ្រូរបស់គេដាច់ខាតត្រូវតែដើរជាមួយសិស្ស។ ប៉ុន្តែការអនុញ្ញាតដែលធ្វើ ឬមិនធ្វើនោះ គ្រូមានសិទ្ធិត្រឹមនាំសិស្សបង្ហាត់បង្រៀនប៉ុណ្ណោះឯង។ ត្រង់ការអនុម័តយ៉ាងណាៗនោះ គឺស្រេចលើបក្ស។ នៅទីនោះ គឺអ្នកធំជាងគេគឺប្រធានបក្សរបស់មន្ទីរពេទ្យនោះតែម្តង បាទ។

**ស៖** តើនរណាគេជាប្រធានបក្សមន្ទីរពេទ្យ ជាអ្នកបញ្ជាលោកឲ្យទៅសង្កេតការវះកាត់នោះ? នេះជាសំណួរដែលខ្ញុំចង់សួរ។ ឧទាហរណ៍ថា បុគ្គលនោះជាអ្នកបញ្ជាលោក ចាត់តាំងលោកឲ្យទៅនោះទៅធ្វើការសង្កេតការវះកាត់ តើជានរណាដែរ?

[១៤:២៣:៣៥]

**ឆ៖** អ្នកម្ចាស់សំណួរគួរយល់បានថា អ្នកធ្វើទាំងអស់នោះសុទ្ធតែក្រោមការគោរពរបស់អ្នកដឹកនាំខាងលើ។ ទោះបីក្រុមនោះ នៅកន្លែងនោះគឺមានអ្នកណាធំជាងគេ គឺប្រធានមន្ទីរពេទ្យនេះឯង។ ដូច្នេះមិនគួរបើអ្នកសួរនោះចោទសួរដដែលទេ ព្រោះថាដំណើរឋានៈនិងឋានៈ ខ្ញុំបានប្រាប់អស់ហើយ ព្រោះខ្ញុំធ្វើនោះធ្វើគោរពកិច្ចការរបស់អ្នកដឹកនាំបាទ។ សូមជ្រាប។

**ស៖** ខ្ញុំសួរសំណួរនេះចុងក្រោយ។ តើអ្នកណាគេជាប្រធានមន្ទីរពេទ្យនុង? បើសិនលោកមិនដឹងទេប្រាប់ខ្ញុំថាមិនដឹងទៅ។ តើនរណាគេជាប្រធានមន្ទីរពេទ្យ? ឈ្មោះ សូមលោកបញ្ជាក់ឈ្មោះឲ្យបានច្បាស់លាស់ ដែលជាអ្នកបញ្ជាបង្គាប់លោកឲ្យទៅសង្កេតការវះកាត់នោះ? សូមលោកប្រាប់ឈ្មោះ។

**ឆ៖** លោកជ្រាបឲ្យបានច្បាស់ថា ខ្ញុំឆ្លើយថា មន្ទីរពេទ្យតំបន់២០ គឺ តាអ៊ុត ជាអ្នកប្រធាន អ៊ីចឹងលោកជ្រាបឲ្យបានច្បាស់បាទ។

[១៤:២៤:៣៦]

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលទំព័របន្ទាប់ សំណួរមួយបានចោទសួរលោក "ថាតើនរណាគេជាអ្នកបញ្ជាឲ្យវះកាត់?" លោកទើបតែបានប្រាប់ថា គេឲ្យលោកទៅសង្កេតការវះកាត់។ ដូច្នេះខ្ញុំចង់ឲ្យលោកឆ្លើយនឹងសំណួរនេះ។ ខ្ញុំសូមសួរលោកថា តើនរណាគេបញ្ជាលោកឲ្យធ្វើការវះកាត់នោះ? អង់គ្លេសទំព័រ៨៨ ត្រង់ម៉ោង -- ក្រោមម៉ោង ១៥:១៥:០២ ទំព័រខ្មែរ ៧៩, ទំព័របារាំង ៩១ ដល់៩២។ សូមលោកបញ្ជាក់ និងឆ្លើយថា តើនរណាគេបង្គាប់លោកឲ្យធ្វើការវះកាត់នោះ?

**ឆ៖** អ្នកបញ្ជាឲ្យធ្វើគឺ បញ្ជារបស់បក្ស សម្រាប់ប្រចាំមន្ទីរពេទ្យតំបន់តែម្តង។

**ស៖** សូមឲ្យលោកជួយប្រាប់ឈ្មោះ តើនរណាគេ? ឈ្មោះគាត់ហ្នឹងឈ្មោះអ្វី? គឺលោកដឹងហើយ ខ្ញុំចង់សួរឈ្មោះ។ ដូច្នេះសូមឲ្យលោកបញ្ជាក់ឈ្មោះហ្នឹង តើឈ្មោះអ្វីដែរ? កុំឲ្យខ្ញុំសួរសំណួរនេះប្រាំដងទៀត សូមលោកជួយបញ្ជាក់ឈ្មោះមុនពេលដែលខ្ញុំចូលទៅដល់សំណួរបន្ទាប់។

[១៤:២៦:១៤]

**ឆ៖** លោកបានជ្រាបអត់ ហើយនៅឲ្យខ្ញុំឆ្លើយប៉ុន្មានដងទៀត? ព្រោះខ្ញុំប្រាប់ថា អ្នកដែលបញ្ជាគឺប្រធានពេទ្យឈ្មោះ តាអ៊ុត ស្តាប់បាននៅ?

**ស៖** សូមអរគុណ។ តើបុគ្គលហ្នឹងនៅឯណាដែរសព្វថ្ងៃនេះ បើសិនជាលោកដឹងនោះ?

**ឆ៖** ខ្ញុំមិនបានដឹងថាគេរស់ ឬគេស្លាប់ទេ។ មានប៉ុណ្ណឹងបាទ។

**ស៖** អរគុណ។ តាអ៊ុត នេះ គឺជាឈ្មោះបដិវត្តន៍ ឈ្មោះហៅក្រៅ ឬក៏ឈ្មោះប្រាកដរបស់គាត់?

**ឆ៖** ខ្ញុំអត់ដឹងថាគាត់មានឈ្មោះប៉ុន្មានទេ តែពេលដែលចូលដល់គឺឈ្មោះ មានឈ្មោះនៅឈ្មោះថា តាអ៊ុត តែម្តងបាទ។

**ស៖** សូមអរគុណ។ យើងនៅពេលនេះចូលទៅដល់ប្រធានបទមួយទៀត គឺពាក់ព័ន្ធទៅនឹងបញ្ហាបុរីកីឡា។ លោកប្រាប់ថា លោកបានទទួលវគ្គរៀនសូត្រនយោបាយនៅទីនោះ។ សំណួរដែលខ្ញុំចាប់អារម្មណ៍ចង់ចោទសួរលោកនោះ តើលោកមានបានឃើញ អៀង សារី ដែរឬទេ? នៅក្នុងប្រតិចារឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ទំព័រ៧៩ -- ៧០ ទៅ ៧១, ទំព័រ ៧០-៧១ ជាភាសាខ្មែរ, អង់គ្លេសទំព័រ ៧៩, បារាំងគឺអត់មានលេខទំព័រទេ តែក្រោមម៉ោង ១៤:២៧ នាទី លោកបានឆ្លើយថា "នៅពេលនោះខ្ញុំឃើញសមមិត្ត ប៉ុល ពត, នួន ជា និង ខៀវ សំផន ហើយខ្ញុំដូចជាមិនប្រាកដទេ ថាតើខ្ញុំបានឃើញ អៀង សារី ឬក៏អត់"។ នេះជាអ្វីដែលលោកឆ្លើយនៅពេលនោះ។ នៅពេលនេះយើងមើលសក្ខីកម្មដែល

លោកឆ្លើយកាលពីម្សិលមិញវិញម្តង។ ដំបូង ពីដំបូងសហព្រះរាជអាជ្ញាបានសួរលោក ដូចតទៅ "តើលោកធ្លាប់ឃើញ ប៉ុល ពត, អៀង សារី, នួន ជា ឬក៏ ខៀវ សំផន ដែរឬទេ នៅពេលដែលពួកគេទៅដល់ទីនោះ?" នេះគឺត្រង់ទំព័រ១៩ ប្រតិចារឹកកាលពីម្សិលមិញ គឺព្រឹកខាងក្រោម ០៩:៥២:៣៧ "តើលោកធ្លាប់ឃើញពួកគេដែរឬទេ?" នេះសំណួរសួរដោយសហព្រះរាជអាជ្ញាកាលពីម្សិលមិញ។

[១៤:២៩:៣០]

"លោកទាំងបួនឈ្មោះដែលលោកបានសួរនោះ ខ្ញុំបានជួបគាត់ខ្លីទេ នៅពេលដែលខ្ញុំទៅរៀននយោបាយនៅបុរីកីឡា"។ ផ្អែកទៅតាមសំណួរហ្នឹង លោកបានឆ្លើយថា លោកបានជួប អៀង សារី។ នៅពេលនេះ គឺយើងសូមឲ្យមើលនាពេលក្រោយមក គឺខាងក្រោមចុច -- ម៉ោង ១០:១៤:០៣ ទំព័រ២៦ ជាភាសាអង់គ្លេស ប្រតិចារឹកដដែល។ សហព្រះរាជអាជ្ញាបានសួរថា ខ្ញុំបានឮកាលពីថ្ងៃពុធមុន លោកនិយាយអំពី យុន យ៉ាត, ប៉ុល ពត, នួន ជា, ហ៊ូ នឹម នៅក្នុងចំណោមមេដឹកនាំផ្សេងទៀត ដែលធ្វើសុន្ទរកថា ធ្វើបទឧទ្ទេសនាមនៅក្នុងវគ្គនយោបាយ ដែលលោកបានចូលរួម ហើយលោកបាននិយាយថាពាក់ព័ន្ធទៅនឹង អៀង សារី គឺលោកប្រាកដណាស់បានឃើញគាត់។ ហើយគឺនៅពេលនេះគឺមានពាក្យថា "ប្រាកដណាស់ គឺបានឃើញ"។ ដូច្នេះ ខ្ញុំសូមសួរលោកសិន មុនពេលដែលខ្ញុំចូលទៅដល់ចំណុចដែលឆ្លើយផ្សេងទៀត។ នៅក្នុងថ្ងៃនេះ តើលោកនឹកឃើញដោយឯកឯងតែម្តងដែរឬទេថាបាន ឃើញលោក អៀង សារី មានវត្តមាននៅក្នុងវគ្គរៀនសូត្រនយោបាយនាពេលនោះ?

[១៤:៣១:០៩]

**ផៈ** ត្រង់ហ្នឹង គឺខ្ញុំបានឃើញ តែគាត់មិនបានធ្វើអីទេ គឺបានតែឃើញបាទ។

**សៈ** សូមអរគុណ។ នេះជាសក្ខីកម្ម លោកឆ្លើយអឺចឹងនៅក្នុងថ្ងៃហ្នឹង។ លោកប្រាកដណាស់ថាលោកបានឃើញគាត់។ កាលពីប៉ុន្មានថ្ងៃមុន លោកឆ្លើយថាលោកមិនប្រាកដទេ ហើយលោកមិនប្រាកដ។ ដូច្នេះនៅពេលនេះ លោកបែរជានិយាយថាលោកប្រាកដណាស់បានឃើញគាត់។

នៅពេលនេះយើងពិនិត្យទៅលើទម្រង់បែបបទព័ត៌មានដែលលោកបានបំពេញវិញម្តង។ គឺចាប់ផ្តើមចាប់ពីឯកសារ D22/3963។ នេះជាព័ត៌មានបន្ថែមមួយផ្នែក ទៅលើឯកសារដែលលោកបានដាក់ជូនតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្មែរគឺ 00573976 ទៅ 77, បារាំងគឺ 00786185, អង់គ្លេសគឺ 00751867។ នេះជាអ្វីដែលលោកបានឆ្លើយនៅក្នុងនុំង។ "ខ្ញុំបានឃើញ ប៉ុល ពត, នួន ជា, លោក ខៀវ សំផន, និង អៀង ធីរិទ្ធ នៅទីនោះ"។ តើលោកអាចបញ្ជាក់ជូនយើងខ្ញុំដែរឬទេ? តើកន្លែងណា

ដែលលោកបានឆ្លើយថា លោកបានឃើញ អៀង សារី នៅទីនោះ? អ៊ីចឹងលោកចង្អុល ហើយបញ្ជាក់ខ្ញុំឲ្យច្បាស់លាស់មើលត្រង់ចំណុចនេះ។ តើត្រឹមត្រូវដែរឬទេ ដែលយើងនិយាយបានថា លោកនៅត្រង់នេះមិនបាននិយាយអ្វីទាក់តែសោះពាក់ព័ន្ធទៅនឹងលោក អៀង សារី?

[១៤:៣៣:២៨]

**ឆះ** ត្រង់នេះខ្ញុំសូមបញ្ជាក់ថា ធម្មតាទេការសួរចុះសួរឡើងអាចនឹងភ័ន្តពាក្យភ័ន្តអីខ្លះ ប៉ុន្តែខ្ញុំកាលណោះឃើញៗប៉ុន្មាននាក់ថ្នាក់ដឹក ខ្ញុំយល់ការពិតគឺឃើញ អៀង សារី មែនដែរ ដោយសារខ្ញុំខ្ជិលនិយាយបន្តច្រើនដង គឺខ្ញុំនិយាយអ៊ីចឹងទៀតទៅបាទ។

**សះ** ជាដំបូង ឥឡូវយើងមើលបែបនេះវិញ។ ថាតើនេះជាចម្លើយដែលខ្លួនលោកផ្ទាល់ជាអ្នកសរសេរ តើមែនទេ? បានន័យថា វាជាចម្លើយមួយដែលលោកនិយាយថា លោកមិនមានចំណេះដឹងខាងពេទ្យនោះ គឺឯកសារតែមួយ គឺនៅទំព័រតែមួយ ទំព័រដូចគ្នានេះ។ តើលោកជាអ្នកសរសេរឯកសារហ្នឹងដោយផ្ទាល់ដៃ តើមែនទេ?

[១៤:៣៤:៣១]

**ឆះ** ខ្ញុំសរសេរផ្ទាល់ដៃបាទ។

**សះ** ដូច្នេះនេះមិនមែនជាអ្វីដែលលោកឆ្លើយតបទៅនឹងសំណួរទេ គឺលោកសរសេរ -- គឺលោកធ្វើឡើងដោយខ្លួនឯង។ គឺថានៅពេលដែលលោកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី តើមែនទេ?

**ឆះ** បាទ ខ្ញុំជាអ្នកតាំង។ ខ្ញុំជាអ្នកតាំងមែនបាទ។

**សះ** នៅពេលដែលលោកដាក់ពាក្យសុំតាំងខ្លួនហ្នឹង តើលោកចង់សុំតាំងខ្លួនដោយប្រាកដប្រជាឬមួយគ្រាន់តែជាការដែលលេងសើចទេ?

**ឆះ** ខ្ញុំតាំងខ្លួនសួរជាដើមបណ្ដឹងមិនមែនជាពាក្យលេងសើចទេ ការពិត គឺការឈឺចាប់ បាត់ម្ដាយបាត់ឪពុក បាត់បង បាត់ប្អូនអស់ដោយសារអំពើពួកថ្នាក់ដឹកនាំនេះឯង។ ដូច្នេះ ខ្ញុំងើបឡើងដើម្បីតាំងជាពាក្យបណ្ដឹង ដើម្បីស្វែង ទាញរឿងពិតប្រាប់ដល់តុលាការថា រឿងពិតរបស់អ្នកទាំងបីហ្នឹងយ៉ាងម៉េចខ្លះ គឺខ្ញុំសុំនិយាយតែរឿងពិតទេ។ ត្រង់ថាគេធ្វើយ៉ាងណានោះ ជារឿងរបស់គេ។ ឯខ្ញុំឃើញយ៉ាងណានោះជារឿងរបស់ខ្ញុំ។ ខ្ញុំសូមលោកម្ចាស់សំណួរជ្រាបបាទ។

[១៤:៣៥:៥៧]

**ស៖** ឥឡូវនេះយើងមើលឯកសារ D22/3963/1 ដែលជារបាយការណ៍នៃការពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីគឺនៅថ្ងៃ០៣ ខែមេសា ឆ្នាំ២០១០។ គឺវាបង្ហាញថា -- ប៉ុន្តែនៅលើឯកសារហ្នឹងគឺចុះហត្ថលេខាថ្ងៃ២៩ មករា ២០១០។ នៅលើឯកសារនេះ គឺនៅទំព័រទី១ សូមអភ័យទោស គឺនៅទំព័រទី២ គឺ ERN មានលេខ 00573962 ហើយនៅទីនេះបាននិយាយថា គាត់បានបញ្ជាក់ថា "ក្នុងការសិក្សា -- ក្នុងវគ្គសិក្សា គឺឃើញវត្តមានរបស់ ប៉ុល ពត, នួន ជា, ខៀវ សំផន ហើយនិង អៀង ធីរិទ្ធ"--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ ឯកសារដែលមេធាវីលោក អៀង សារី កំពុងតែប្រើប្រាស់នេះ គឺជាឯកសារដែលមានចំណងជើងថា "របាយការណ៍ស្ដីពីការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី"។ ឯកសារនេះ គឺធ្វើឡើងដោយអង្គភាពគាំពារជនរងគ្រោះ ដោយផ្អែកទៅលើសំណៅដើមនៃសំណើសុំ គឺឯកសារលេខ D22/3963។ ខ្ញុំគិតថា មិនត្រូវអាននូវសេចក្ដីសង្ខេបរបស់អង្គភាពផ្សេងទេ។ យើងមានឯកសារដើមដែលផ្ដល់សុពលភាព ដោយដើមបណ្ដឹងរដ្ឋប្បវេណីរួចនេះហើយ។ ដូច្នេះសុំឲ្យគាត់កម្រិតត្រឹមតែការប្រើឯកសារដើម ដែលចុះហត្ថលេខាផ្ទាល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺលេខ D22/3963។ ខ្ញុំគិតថា គាត់មិនគួរយោងទៅលើឯកសារសង្ខេបរបស់អង្គភាពគាំពារជនរងគ្រោះនោះទេ។ នេះគ្រាន់តែជាឯកសារសង្ខេបចេញពីឯកសារដើម ដែលខ្លួនបានរកឃើញព័ត៌មាន ដែលមាននៅក្នុងទម្រង់ព័ត៌មានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ ដូច្នេះសូមឲ្យមេធាវីការពារក្ដីកុំប្រើប្រាស់នូវឯកសារមួយនេះ ពីព្រោះថាវាមិនមានខ្លឹមសារអ្វីទេ ដែលយោងទៅលើឯកសារមួយនេះនោះ។ សូមយកឯកសារដែលលេខ D22/3963 ទៅបានហើយ កុំយកឯកសារ D22/3963/1 អី។

[១៤:៣៨:៣៣]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំត្រូវតែបន្ត ព្រោះអ្វីដែលខ្ញុំចង់និយាយ គឺថានៅពេលដែលយើងផ្អែកទៅព័ត៌មាននេះ គឺជាព័ត៌មានដែលមិនគ្រប់គ្រាន់។ ប៉ុន្តែពាក្យស្នើសុំនេះ គឺមានព័ត៌មានដែលមិនគ្រប់គ្រាន់ផងដែរ។ ហេតុដូច្នេះហើយទើបមានរបាយការណ៍នៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ យ៉ាងណាក៏ដោយ

ខ្ញុំត្រូវតែបន្តទៅមុខទៀត។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឥឡូវនេះ យើងមើលទៅលើឯកសារ D230/3/4.2.277A ហើយភាសាខ្មែរ ERN គឺមានលេខ 00508424 ដល់ 26, ភាសាបារាំងគឺមានលេខ 00822270 ដល់ 71, ភាសាអង់គ្លេសគឺមានលេខ 00777625។ ហើយនៅត្រង់ឯកសារនេះលោកបាននិយាយអំពី “នៅឆ្នាំ៧៥ ខ្ញុំធ្វើការជាគ្រូពេទ្យឲ្យខ្មែរ” គឺលោកនិយាយថា លោកធ្វើការ មិនមែនសិក្សាទេ។ គឺលោកនិយាយថា “ខ្ញុំធ្វើការជាគ្រូពេទ្យឲ្យខ្មែរក្រហមនៅមន្ទីររុស្ស៊ី។ ហើយសកម្មភាពក្នុងទីក្រុងមានភាពស្ងាត់ជ្រងំតាំងក្រៅនិងក្នុងមន្ទីរពេទ្យ។ ពេលនោះ គេឲ្យខ្ញុំទៅរៀនពីគោលនយោបាយរបស់បក្សកុម្មុយនីស្តនៅបុរីកីឡា។ ខ្ញុំបានឃើញ និងស្គាល់អ្នកបង្រៀនខ្ញុំ ដែលបានបង្រៀនរយៈពេល១ម៉ោងដំបូង ឈ្មោះ ប៉ុល ពត ក្រៅពីនេះ មានលោក នួន ជា”។ ហើយលោកក៏បាននិយាយផងដែរ “អំពី ខៀវ សំផន” គឺថា លោកមិនបាននិយាយទាល់តែសោះអំពី “អៀង សារី ទាំងជាអ្នកបង្រៀន ក៏ដូចជាអ្នកចូលរួម ទាំងវត្តមាន”។ ថាតើលោកបានឃើញវត្តមានរបស់ -- តើលោកបានឃើញឯកសារនេះទេ?

[១៤:៤០:៥៣]

**ឆ៖** ខ្ញុំជម្រាបប្រាប់ចំពោះ អៀង សារី ខ្ញុំគ្រាន់តែបានឃើញក្នុងការចូលរួមមួយភ្លែត មិនបានយូរទេ។ ដូច្នេះ អ្នកម្ចាស់សំណួរគួរតែស្គាល់ហើយ ដឹងហើយ។ មួយបែបទៀត ខ្ញុំសូមរំឭកឡើងវិញថាពីនោះមកដល់ណេះ ខ្ញុំបូកបោះឆ្នាំមើលទៅ៤០ឆ្នាំ។ ដូច្នេះការចងចាំប្រហែលជាបាត់អស់ ក្នុង១០០បាត់អស់ប្រហែល២០ ឬក៏៣០ភាគរយរួចទៅហើយអស់លោក។ អ៊ីចឹងការចងចាំនេះ គឺ -- នេះគឺជាការចងចាំ មិនមែនជាការថតទុកទេ សូមលោកម្ចាស់សំណួរស្វែងយល់អំពីដំណើរពេលវេលាផង។ សូមអរគុណ។

**ស៖** សំណួររបស់ខ្ញុំគឺថា តើលោកបានឃើញថា លោកបានសរសេរឈ្មោះ ថា អៀង សារី បានផ្តល់នូវការបង្រៀន ឬក៏ផ្តល់ឧទ្ទេសនាម ថាតើលោកមានឃើញថានៅក្នុងចម្លើយរបស់លោកហ្នឹងមាននិយាយអំពីឈ្មោះ អៀង សារី ឬក៏អត់? ថាតើលោកបានឃើញថា មានឈ្មោះលោក អៀង សារី នៅក្នុងឯកសារហ្នឹងអត់?

**ឆ៖** ត្រង់ហ្នឹងលោកស្គាល់លោកអ្នកម្ចាស់សំណួរស្គាល់ទេ ពាក្យខ្ញុំថា បន្ថែម ឈ្មោះថាបន្ថែមនឹកឃើញ ច្រើននឹកឃើញទៅអាចនឹងសរសេរ។ អ៊ីចឹងការពិតខាងដើម ខ្ញុំសរសេរមិនបានសរសេរមែន

ប៉ុន្តែដល់ក្រោយមក ខ្ញុំនឹកឃើញ បានខ្ញុំថែមឯកសារថា បានឃើញ។ ដូច្នេះ សូមនិយាយរឿងពិតថា ត្រឹមបានឃើញប៉ុណ្ណោះឯង។ ខ្ញុំសូមម្ចាស់សំណួរទទួលស្គាល់បាទ។

[១៤:៤២:៣១]

**ស៖** នៅពេលដែលខ្ញុំពិនិត្យមើលលើពាក្យសុំទាំងអស់ ខ្ញុំពិនិត្យមើលទៅលើឯកសារដែលលោកដាក់ទាំងអស់ គឺខ្ញុំអត់មានឃើញការនិយាយយោងណាមួយ សូម្បីតែមួយក៏គ្មានដែរ ដែលនិយាយថា អៀង សារី នៅបុរីកីឡា គឺថាមិនបាននិយាយថា ឃើញ អៀង សារី នៅក្នុងវគ្គរៀនសូត្រនៅបុរីកីឡា។ តើលោកប្រាប់បានដែរឬទេ ថាតើលោកបង្ហាញព័ត៌មាននៅកន្លែងណា គឺក្នុងឯកសារណាមួយ ធ្វើម៉េចខ្ញុំរកឃើញឯកសារណាមួយ ដែលមានឈ្មោះនោះ? សូមលោកប្រាប់ខ្ញុំ។

**ឆ៖** សូមបញ្ជាក់លោកម្ចាស់សំណួរ។ បើសិនជាលោកមិនបានឃើញ ចុះហេតុអ្វីបានយកមកសួរបាទ? អ៊ីចឹងលោកសូមពិចារណាឡើងវិញសិនថា ធម្មតាទេ ការសរសេរដូចខ្ញុំនិយាយអំមិញថា កុំថាឡើយដល់ធ្វើឃើញ ឮ សូម្បីធ្វើខ្លួនឯង ក៏មានការភ្លេចភ្លាំងដែរលោកប្រធាន លោក។ ដូច្នេះ ខ្ញុំសូមទទួលស្គាល់ថា ខ្ញុំជាអ្នកសរសេរ មូលហេតុដែលថា យ៉ាងនេះ ព្រោះការនឹកសាចុះសាឡើងវាមិនបានដូចការឃើញ និងការសរសេរផ្ទាល់ភ្លាមៗនោះទេអស់លោក។ អ៊ីចឹងសូមជម្រាបលោក ទទួលស្គាល់តាមពាក្យសម្តីខ្ញុំចុះបាទ។

[១៤:៤៣:៥៨]

**ស៖** តាមដែលខ្ញុំយល់គឺថា គឺខ្ញុំយល់អំពីបញ្ហានេះហើយ ប៉ុន្តែឥឡូវនេះយើងនិយាយអំពីការដែលថា លោកមិនមានចំណេះដឹងខាងពេទ្យ គឺលោកបានប្រាប់ព័ត៌មាននេះទៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ តើលោកភ្លេចដោយសារតែពេលវេលាកន្លងមក ទើបលោកនិយាយថា លោកមិនមានចំណេះដឹងខាងពេទ្យ ដែលលោកនិយាយថា លោកមានចំណេះដឹង ដោយសារលោកមានចំណេះដឹងខាងពេទ្យ ១៣-១៤ ឆ្នាំ ប៉ុន្តែចុងក្រោយលោកថា លោកអត់មានចំណេះដឹង ខាងពេទ្យ។ តើអាហ្នឹងយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំមានការកត់សម្គាល់ពីរលោកប្រធាន។ ការកត់សម្គាល់ទី១ គឺពេលវេលាដែលប្រើប្រាស់ដោយមេធាវីការពារក្តី អៀង សារី។ នេះគឺជាពេលវេលាមួយដែលខ្ញុំគិតថា មានលក្ខណៈមួយដែល -- មាន

លក្ខណៈបំពាន។ សូមទោសគឺថា យើងមិនគួរប្រើពាក្យសម្តីបែបនេះទេ ការនិយាយអ៊ីចឹងមានលក្ខណៈគំហកខ្លាំងពេក។ ហើយពាក់ព័ន្ធទៅនឹងវគ្គរៀនសូត្រពេទ្យនេះ ខ្ញុំបានជំទាស់អម្បាញ់មិញហើយ ពីព្រោះថាដើមបណ្តឹងរដ្ឋប្បវេណីនេះ គាត់បានបញ្ជាក់ច្បាស់ណាស់ថាគាត់អត់មានបានទទួលការរៀនពេទ្យជាផ្លូវការ ដោយមានសញ្ញាបត្រពេទ្យជាផ្លូវការនោះទេ គាត់គ្រាន់តែរៀនសូត្រនៅកន្លែងធ្វើការជាលក្ខណៈមិនផ្លូវការ។ ដូច្នេះ ឥឡូវនេះមេធាវីការពារក្តីត្រឡប់មកនិយាយអំពីការរៀនសូត្រខាងពេទ្យនេះទៀតហើយ គាត់ចំណាយពេលប៉ុន្មានម៉ោងហើយទៅលើបញ្ហានេះ គាត់បានបដិសេធហើយថា គាត់មិនបានរៀនជាផ្លូវការទេ ឥឡូវមកសួរអ៊ីចឹងបែបនេះទៀត ហើយនិងយកមកភ្ជាប់ជាមួយនឹងការរៀនសូត្រនៅបុរីកីឡាទៀត។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមឆ្លើយដោយសង្ខេបលោកប្រធាន។ ហេតុផលដែលខ្ញុំត្រឡប់មកនិយាយពីចំណុចនេះព្រោះគាត់និយាយថា ដោយសារតែពេលវេលា ដោយសារតែបញ្ហានានាទើបគាត់មិនអាចចាំអំពីលោក អៀង សារី។ ហើយឥឡូវនេះនៅពេលដែលមានឱកាសហ្នឹងគាត់បាននិយាយបែបនេះ។

[១៤:៤៦:០០]

ព្រោះថាបន្ទាប់ពី៤០ឆ្នាំ គាត់អាចនិយាយនូវព័ត៌មានលម្អិត។ ហើយដោយសារតែការពន្យល់បែបនេះ ខ្ញុំចង់ឲ្យលោកដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ថា ឥឡូវនេះដែលគាត់មានបទពិសោធន៍ពេទ្យ១៤ឆ្នាំ ប៉ុន្តែហេតុអ្វីបានជាគាត់មិននិយាយ -- ហេតុអ្វីបានជាគាត់និយាយថាគាត់គ្មានចំណេះដឹងខាងពេទ្យទាល់តែសោះ។ ដោយសារតែការភ្លេចភ្លាំង ឬក៏ដោយសារលោកដើមបណ្តឹងហ្នឹងគាត់មិននិយាយការពិតនៅពេលដែលគាត់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ។

[១៤:៤៦:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៧:៤១]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសម្អាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមានមូលហេតុសមស្រប។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់មេធាវីការពារក្តីលោក អៀង សារី ទេ។ លោកមេធាវីអាចបន្តសំណួរថ្មីៗទៀត។

[១៤:៤៨:០៤]

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** លោកបានប្រាប់យើងថាគេបង្ខំឲ្យលោករៀបការ ហើយបន្ទាប់មកលោកលែងលះគ្នា។ តើលោកលែងលះគ្នានៅពេលណាដែរ?

**លោក អែម អឿន៖**

**ឆ៖** សូមលើកឡើងពីបញ្ហាលែងលះ ត្រង់ណេះមើលទៅដំណើររបស់ខ្ញុំហាក់ដូចជាគ្មានទម្ងន់នឹងពាក្យទេ ដូចនេះយើងនិយាយហាក់ដូចជាខាតពេល។ សូមមានមតិប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកមានកាតព្វកិច្ចឆ្លើយតបទៅនឹងសំណួរ លើកលែងតែសំណួរឯណាមានការជំទាស់ ឬដោយឆន្ទានុសិទ្ធ អង្គជំនុំជម្រះមិនឲ្យលោកឆ្លើយតប។ បើពុំដូច្នេះទេកាតព្វកិច្ចរបស់លោក គឺឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលតាំងសំណួរចំពោះលោកនៅចំពោះមុខតុលាការនេះ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី! លោកមេធាវីៗនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១៤:៤៩:២២]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ តាមការពិតសំណួរនេះត្រូវបានសួររួចមកហើយ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីក៏បានឆ្លើយរួចមកហើយដែរ។ លោកប្រធានបានបញ្ជាក់រឿងចំណុចផ្សេងមួយទៀតថា ដើមបណ្ដឹងរដ្ឋប្បវេណីមានកាតព្វកិច្ចនៅក្នុងការឆ្លើយតប។ ត្រង់ចំណុចនេះ យើងខ្ញុំខាងដើមបណ្ដឹងរដ្ឋប្បវេណីក៏សំណូមពរផងចំពោះជនជាប់ចោទដែលជាភាគី ដូចដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ នៅ -- ថាមានកាតព្វកិច្ចនៅក្នុងការឆ្លើយតបផងដែរចំពោះករណីជនជាប់ចោទ ដោយសារជនជាប់ចោទក៏ជាភាគី ដើមបណ្ដឹងរដ្ឋប្បវេណីក៏ជាភាគីដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ប្រសិនបើលោកបានរក្សាសិទ្ធិមិនឆ្លើយតបទាំងពីដំបូង នោះគឺយើងមិនបាច់កោះហៅគាត់មកផ្តល់សក្ខីកម្មទេ ពីព្រោះចម្លើយតបរបស់គាត់ គឺតបជាមួយនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី និងវាអាចសហព្រះរាជអាជ្ញាពេញលេញហើយ មិនអាចមិនឲ្យឆ្លើយតបមួយចំហៀង ហើយមួយចំហៀងទៀត មិនអាចមិនឆ្លើយតបនោះទេ។ ប្រសិនបើលោកប្រើប្រាស់នូវសិទ្ធិមិនឆ្លើយតប គឺសុំដកចេញនូវដើមបណ្តឹងរដ្ឋប្បវេណីឯណាដែលរក្សាសិទ្ធិមិនឆ្លើយតប កុំឲ្យរំខានដល់ការកំណត់កាលបរិច្ឆេទសម្រាប់ធ្វើសវនាការដេញដោលរបស់អង្គជំនុំជម្រះ។ សូមពិនិត្យឡើងវិញ ក្រែងលោមានការភ័ន្តច្រឡំ។

សូមអញ្ជើញលោកមេធាវី ម៉ែខល កាណាវ៉ាស!

[១៤:៥១:១១]

**លោក ម៉ែខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ែខល កាណាវ៉ាស៖**

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរសំណួរសាជាថ្មី។ លោកបានប្រាប់យើងកាលពីសប្តាហ៍មុនថា ខ្ញុំមាននូវប្រតិចារឹក គឺនៅថ្ងៃទី២៣ ខែសីហា គឺទំព័រ៥២ ជាភាសាអង់គ្លេស, គឺ៤២ ជាភាសាខ្មែរ ហើយនិងទំព័រ៥៦ ជាភាសាបារាំង។ ហើយនៅថ្ងៃដដែលនេះ គឺទំព័រភាសាខ្មែរ ៩៣ ដល់៩៤, បារាំង ១០៨ និងអង់គ្លេស ១០៤។ គឺលោកនិយាយអំពីការលែងលះភរិយារបស់លោក គឺភរិយាដែលគេបង្ខំឲ្យលោករៀបការ។ សំណួរដែលខ្ញុំចង់សួរគឺសាមញ្ញ។ តើលោកចាំឆ្នាំ ដែលលោកលែងលះនោះដែរឬទេ គឺឆ្នាំដែលលោកលែងលះជាមួយភរិយារបស់លោក តើលោកចាំឆ្នាំដែរទេ?

**លោក អែម អឿន៖**

**ឆ៖** ឆ្នាំដែលលែងខ្ញុំចាំ ប៉ុន្តែរឿងរ៉ាវខ្លះ ខ្ញុំមិនចង់និយាយ។ ឆ្នាំលែងគឺក្នុងឆ្នាំពីរពាន់-- ២០០២។

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលឯកសារ D22/3963 ដែលជាចម្លើយរបស់លោក គឺចម្លើយដែលលោកសរសេរដោយផ្ទាល់ដៃ ហើយប្រគល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា។ ភាសាខ្មែរ ដែលមានលេខ 00573981 ទៅ 82, ភាសាអង់គ្លេស គឺមានលេខ 00751866 និងភាសាបារាំង គឺមានលេខ 00766187។ គឺទំព័រទី៨ ជាភាសាអង់គ្លេស។ នេះគឺជាអ្វីដែលលោកបានសរសេរ។ នៅ

ពេលដែលលោកផ្តល់ព័ត៌មានទៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលដែលលោកស្នើឲ្យគេជួយជាមួយនឹងព័ត៌មានដែលលោកចង់សរសេរនោះ។

[១៤:៥៣:៣៩]

"បន្ទាប់ពីត្រឡប់មកពីភូមិ អង្គការត្រូវឲ្យខ្ញុំបានត្រូវរៀបការជាមួយប្រពន្ធសព្វថ្ងៃនេះ"។ នៅពេលដែលលោកសរសេរនេះ បើតាមដែលខ្ញុំមើល គឺនៅក្នុងឆ្នាំ២០១០។ សូមទោសទៅ គឺនៅថ្ងៃ២៩ ខែមករា ឆ្នាំ២០១២។ ថាតើលោកនិយាយស្មោះត្រង់ ហើយពិតប្រាកដ និងត្រឹមត្រូវដែរឬទេ នៅពេលដែលលោកសរសេរថា "លោកបានរៀបការជាមួយប្រពន្ធសព្វថ្ងៃនេះ គឺអង្គការបានបង្ខំលោករៀបការជាមួយប្រពន្ធសព្វថ្ងៃនេះ"។ បានន័យថា លោកមិនធ្វើការ -- មិនបានលែងលះទេ ឬមួយក៏លោកមិនបានលែងលះនោះទេ នៅពេលដែលលោកសរសេរនូវព័ត៌មានមួយនេះ។ តើលោកមានយោបល់យ៉ាងម៉េចដែរ?

**ឆ៖** លោកម្ចាស់សំណួរ ខ្ញុំសូមជម្រាបថា រឿងទាំងអស់នេះ គឺប្រពន្ធខ្ញុំដើមនោះ គឺលែងនៅឆ្នាំ២០០២។ គឺអ៊ីចឹង ក្រោយមក ខ្ញុំបានយកប្រពន្ធមួយទៀត។ ដើម្បីកុំឲ្យវែងឆ្ងាយ ខ្ញុំអត់មាន វាអត់មានអេតាស៊ីវិលផង ខ្ញុំអត់និយាយចូលក្នុងហ្នឹងទាំងអស់។ អ៊ីចឹងគ្រាន់ដាក់ថាប្រពន្ធទី១, ទី២ និយាយបន្ត អត់ដែលមាននិយាយទី១, ទី២ ទេ ខ្ញុំច្រើនប្រើភ្ជាប់គ្នាតែម្តង។ អ៊ីចឹងសូមលោកម្ចាស់សំណួរទទួលស្គាល់។

**ស៖** នៅពេលដែលលោកដាក់នៅទីនេះ លោកនិយាយថា ប្រពន្ធសព្វថ្ងៃហ្នឹង បានន័យថាជាចម្លើយដែលមិនត្រឹមត្រូវ គឺជាចម្លើយដែលខុស។ តើមែនទេ?

[១៤:៥៥:៤១]

**ឆ៖** យល់ថាជាចម្លើយខុសក៏ខ្ញុំទទួលស្គាល់ដែរ ប៉ុន្តែអាត្រង់ចំណុចហ្នឹង គឺខុសហើយ ព្រោះថាខ្ញុំប្តូរអត់មានប្រាប់ក្នុងរបាយការណ៍ បាទ។ សូមទទួលបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងសូមផ្លាស់ប្តូរប្រធានបទ ហើយនេះជាប្រធានបទចុងក្រោយរបស់ខ្ញុំ។ ខ្ញុំមានកាតព្វកិច្ចត្រូវចោទសួរនូវសំណួរនេះ គឺទាក់ទងនឹងឪពុករបស់លោក។ លោកបានបញ្ជាក់ថា គឺបញ្ជាក់នៅក្នុងឯកសារ D22/3963 ហើយទំព័រភាសាខ្មែរគឺមានលេខ 00573974 ដល់ 75, ភាសាបារាំងគឺមានលេខ 00786184, ភាសាបារាំង -- ភាសាអង់គ្លេសគឺមានលេខ 00751866។ លោកបាននិយាយថា "ក្នុងឆ្នាំ១៩៧៤ ឪពុករបស់ខ្ញុំឈ្មោះ អ៊ូច សាអែម ត្រូវចាប់ខ្លួនដោយលោក សោ

ភឹម ប្រធានភូមិភាគបូព៌ា ដោយថាហៅទៅរៀន ហើយបាត់ខ្លួនរហូតសព្វថ្ងៃ ដែលគាត់មានតួនាទីពេលនោះជាគណៈកម្មការតំបន់២០។ បាត់រហូតដល់ឆ្នាំ៧៥ ទើបខ្ញុំដឹងថាគាត់ត្រូវគេសម្លាប់តាំងពីពេលដែលគាត់ទៅរៀននោះម៉្លេះ”។ ហើយបន្ទាប់មកលោកនិយាយថា “អ្នកដែលទៅជាមួយគាត់នោះត្រូវបានគេយកទៅដែរ ប៉ុន្តែនៅរស់” ហើយលោកនិយាយថា “មានឈ្មោះ ម៉ៅ ជាង, លោក ស៊ឹម កា, លោក ឃាវ សារុន និងអ្នកដទៃទៀត”។ ឆ្នាំដែលលោកសរសេរនេះគឺឆ្នាំ៧៤។

[១៤:៥៨:០០]

ប្រសិនបើយើងពិនិត្យមើលទៅលើឯកសារ D22/3963 ដែលភាសាខ្មែរមានលេខ 00573986 ដល់ 87, ភាសាបារាំងគឺមានលេខ 00786192 ដល់ 93, ភាសាអង់គ្លេសគឺមានលេខ 00751872។ ហើយនៅត្រង់ចំណុចនេះ គឺជាព័ត៌មានបន្ថែម គឺព័ត៌មានដែលលោកបន្ថែម។ លោកនិយាយថា “ប្រហែលជាដើមឆ្នាំ៧៧ ឪពុកខ្ញុំត្រូវអង្គការបក្សហៅទៅរៀនសូត្រនៅមជ្ឈិម (សោ ភឹម ជាអ្នកហៅទៅរៀន) ក៏បាត់ដំណឹងឪពុកខ្ញុំរហូត”។ លោកបានមើលឃើញទេ គឺមួយនិយាយថា ៧៤ ហើយមួយទៀតនិយាយថាចិត -- ១៩៧៧? តើលោកឃើញនូវភាពខុសគ្នានេះដែរឬទេ លោកដើមបណ្តឹងរដ្ឋប្បវេណី?

**ឆ៖** ត្រង់នេះខ្ញុំសូមបញ្ជាក់ប្រាប់ ត្រង់នេះដែលខ្ញុំនិយាយថា ដល់ខ្ញុំផ្តល់ព័ត៌មានទៅឲ្យខាងអ្នកជួយសម្រួលខ្ញុំ គឺមជ្ឈមណ្ឌលឯកសារនេះ យកមកផ្តិតមេដៃ។ ក្នុងនោះខ្ញុំមិនបានពិនិត្យមើលទាំងអស់ដោយយល់ឃើញថា ជារឿងរបស់ខ្ញុំហើយ មិនបានពិនិត្យថា គេសរសេរមកត្រូវឬខុសដែរទេ។ ដូច្នេះអា៧៧ នេះ មិនមែនជាអក្សរខ្ញុំទេបាទ។ អ៊ីចឹងខ្ញុំសូមបដិសេធ បានន័យថា យកភាសា៧៤ នេះវិញបាទ។ គឺ៧៧ គឺអ្នកជំនួយ ហើយដល់ខ្ញុំមិនបានពិនិត្យវាអាចដល់មកអ៊ីចឹង។ សូមទោសដោយសារការប្រហែសបាទ។ ប៉ុន្តែជារឿងពិតរបស់ខ្ញុំ គឺជារឿងពិតៗអ៊ីចឹងមែន។ ខុសតែថ្ងៃ -- ថ្ងៃកំណត់អ្នកសរសេរបញ្ចូលមកខុសថ្ងៃនោះឯង។ ប៉ុន្តែមិនមែនគេបញ្ចូលទេ គឺគ្រាន់តែការបញ្ចូលថ្ងៃហ្នឹងខុសគ្នា តែរឿងអ៊ីចឹងមែន អ៊ីចឹងមែនបាទ។

**ស៖** ដូច្នេះ ខ្ញុំសូមបញ្ជាក់ គឺថាលោកបាននិយាយថា ឪពុករបស់លោកត្រូវបានគេយកទៅ -- យកទៅនៅឆ្នាំ១៩៧៤ គឺថាតាមដែលលោកចាំ។ តើអ៊ីចឹងមែនទេ?

[១៥:០០:៥៨]

**ឆ៖** ត្រង់នេះ ដើម្បីឆ្លើយកុំឲ្យពាក់ព័ន្ធ ខ្ញុំសូមបកស្រាយឲ្យហើយ ព្រោះខ្ញុំមើលទៅតាមដំណើរនេះ ខ្ញុំបានមើលឯកសារហ្នឹងដែរ តែខ្ញុំមិនដឹងបកស្រាយជាមួយអ្នកណាទេ ព្រោះក្រដាសស្នាមហ្នឹងវា

នៅទីហ្នឹងអស់ទៅហើយ។ ការពិត ខ្ញុំដាក់នោះដាក់ថា -- ខ្ញុំដាក់នោះដាក់គ្រាន់ថា ម្ដាយខ្ញុំស្លាប់ក្រោយពេលគាត់ឃើញគេយកឪពុកខ្ញុំទៅ រហូតដល់គាត់ឈឺស្លាប់ពេលនោះតែម្ដង។ អ៊ីចឹង ក្នុងឱកាសដែលខ្ញុំសរសេរនោះ មិនបានដាក់ថា ក្រោយឪពុកៗ ដែលក្រោយ ឬមុនម្ដាយទេ។ គឺគ្រាន់ថា ម្ដាយខ្ញុំស្លាប់ក្រោយពេលដែលគេនាំឪពុកខ្ញុំទៅ ប៉ុណ្ណោះឯង។ នោះមិនមែនថា ម្ដាយខ្ញុំស្លាប់ក្រោយទេ។ មិនមែនថា ម្ដាយខ្ញុំស្លាប់ឆ្នាំនេះ ឆ្នាំនោះ អត់មែនទេ។ គ្រាន់តែដាក់ថា ម្ដាយខ្ញុំបានស្លាប់ក្រោយពេលគាត់ឃើញថា គេហៅឪពុកខ្ញុំទៅ។ នោះឯងគឺជាការៗពិត។ ដល់ខ្ញុំពិនិត្យមើលឯកសារត្រង់ហ្នឹង មើលទៅឃើញខ្ញុំមិនបានដាក់អ៊ីចឹងទេ ចុះហេតុម៉េចបានដាក់? ប៉ុន្តែយ៉ាងណាក៏ដោយ វាគ្រាន់ខុសតែថ្ងៃទេ សូមអ្នកតាំងសំណួរសូមទទួលស្គាល់ថា នេះគឺជារឿងដែលខ្ញុំត្រូវទទួលស្គាល់។ ប៉ុន្តែការវិលចុះ វិលឡើងអាចខុសគ្នាដោយសារពេលវេលា ឬក៏កាលវេលាដែលខ្ញុំមិនបានពិនិត្យ។ កំហុសរបស់ខ្ញុំត្រង់ ស្ថិតនៅត្រង់មិនបានពិនិត្យ។ ហ្នឹងសូមៗទទួលស្គាល់បាទ។

[១៥:០២:២៥]

**ស៖** សូមអរគុណ។ ខ្ញុំសូមត្រឡប់ទៅចំណុចនេះឡើងវិញ។ ក៏ប៉ុន្តែខ្ញុំអធ្យាស្រ័យ ដែលខ្ញុំសួរចុចទៅលើចំណុចនេះ។ ឯកសារនេះ យើងឃើញថា សរសេរ ២៩ ខែមករា ឆ្នាំ២០១២ ដោយ -- ឯកសារដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ D22/3963។ បារាំង 00766184, អង់គ្លេស 00751866 លោកបានឆ្លើយថា ឯកសារទីមួយលោកឆ្លើយថា ឆ្នាំ៧៤។ ឯកសារដំបូងនោះ គឺលោកសរសេរដោយដៃផ្ទាល់របស់លោក។ តើត្រឹមត្រូវទេ ដែលលោកដាក់ថា ឆ្នាំ៧៤នោះ?

[១៥:០៣:២៤]

**ឆ៖** សូមបញ្ជាក់ឲ្យហើយ កុំឲ្យពិបាកដេញដោលទៀតថា ការសរសេរកំណត់ថ្ងៃខែនេះប្រហែល មិនមែនប្រហែល គឺពិតជាមានខុសត្រូវខ្លះ ព្រោះថា ខ្ញុំចាំ ចងចាំពេលសរសេរថ្ងៃនោះ ចាំឆ្នាំទៅ នឹកឃើញថា បើដាក់ទៅ ពេលសរសេរក្រោយមកអាចនឹងខុសថ្ងៃ។ ដូច្នេះសូមទោសទុកជាមុនឲ្យហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី អរគុណដើមបណ្ដឹងរដ្ឋប្បវេណី ឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីដប់ប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅពេលម៉ោងបានកំណត់អម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៥:០៤ នាទី ដល់ម៉ោង ១៥:២១ នាទី)*

[១៥:២១:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក អៀង សារី ក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះសូមសួរទៅមេធាវីការពារក្តី អៀង សារី ថាតើត្រូវការចំណាយពេលវេលាប៉ុន្មានទៀតក្នុងការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ? ហើយតើមានការបែងចែកយ៉ាងដូចម្តេចដែរ រវាងពេលវេលាសម្រាប់មេធាវី ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ពីព្រោះពេលវេលានៃការតាំងសំណួរដេញដោលនេះ គឺតែមួយពេលនៃថ្ងៃស្អែកទៀតទេ យ៉ាងយូរ គឺត្រឹមម៉ោងដប់សាមសិបនាទី ដោយគិតទាំងការថ្លែងអំពីទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានសិទ្ធិក្នុងការធ្វើដូច្នេះផង។

[១៥:២២:៤២]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រូវការ២ ឬក៏៣នាទី ឬក៏៥នាទីច្រើនបំផុតសម្រាប់យើងខ្ញុំ។ គឺ ៥នាទីទៀតតែប៉ុណ្ណោះ។ សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី យើងសូមលើកឡើងប្រធានបទដដែល ទាក់ទងទៅនឹងកាល

បរិច្ឆេទដែលគេចាប់ឪពុករបស់លោកយកចេញទៅ។

ប្រសិនបើយើងមើលឯកសារ D202/2/4.2277A។ ឯកសារនេះ ដាក់ជាប់នឹងឯកសាររបស់លោកថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ លោកបានសរសេរថា "ក្នុងពេលនោះ ម្ដាយឪពុកខ្ញុំនៅតំបន់២០ ក្នុងខេត្តព្រៃវែង ត្រូវបានគេយកទៅសម្លាប់ចោល ដោយគេចោទថាក្បត់បក្សកុម្មុយនីស្តកម្ពុជា ហើយសម្លាប់នៅភូមិកោះខ្នាយ ឃុំជាវ (ស៊ីក) ស្រុកកំចាយមារ ព្រៃវែង តំបន់២០ នៅចុងឆ្នាំ១៩៧៥"។ សូមអធ្យាស្រ័យបើការប្រកបទីតាំងកន្លែងនោះខុស។ នៅទីនេះ គឺយើងឃើញមានកាលបរិច្ឆេទមួយទៀត គឺចុងឆ្នាំ១៩៧៥។ ដូច្នេះ យើងមានកាលបរិច្ឆេទឆ្នាំ៧៤ កាលបរិច្ឆេទចុងឆ្នាំ៧៥ និងកាលបរិច្ឆេទឆ្នាំ១៩៧៧ ដែលវាពាក់ព័ន្ធទៅនឹងការយកឪពុករបស់លោកចេញទៅសម្លាប់ចោល។

[១៥:២៤:២៩]

ដូច្នេះសូមឲ្យលោកបញ្ជាក់កាលបរិច្ឆេទទាំងបីនេះទៅមើល ថាតើគាត់គេយកគាត់ទៅនៅក្នុងឆ្នាំ៧៤ លោកប្រាកដហើយដែរឬទេ មិនមែនចុងឆ្នាំ៧៥ទេនោះ?

**លោក អែម អឿន៖**

**ឆ៖** ប្រាកដរឿងពិតគឺស្ថិតនៅក្នុងឆ្នាំ៧៤ នេះឯង។

**ស៖** ដូច្នេះ ខ្ញុំសូមសួរលោក ហេតុអ្វីបានជាលោកយកឆ្នាំ -- ចុងឆ្នាំ៧៥ និងឆ្នាំ៧៧នេះមកដាក់ថាជាថ្ងៃដែលចាប់ឪពុករបស់លោក? ហេតុអ្វីថ្ងៃខែឆ្នាំនេះ គឺវាខុសគ្នាដែលវាពាក់ព័ន្ធទៅនឹងការបាត់ខ្លួនឪពុករបស់លោកនោះ?

**ឆ៖** ម្ចាស់សំណួរខ្ញុំសូមឆ្លើយតបត្រង់ហ្នឹង ខ្ញុំបានបញ្ជាក់រួចហើយថា ការដាក់ថា តាំង ថាយកទៅសម្លាប់នោះមិនមែនទេ ឪពុកខ្ញុំ ខ្ញុំគ្រាន់តែដាក់ថា "គាត់បាត់ខ្លួននៅ -- បាត់ខ្លួននៅឆ្នាំ៧៤" ដោយខ្ញុំនឹកឃើញថានៅពេលក្រោយឆ្នាំ៧៤ ឪពុកខ្ញុំ -- ម្ដាយខ្ញុំស្លាប់ផ្ទួនគ្នា។ ដល់ស្លាប់ផ្ទួនគ្នា ដល់នឹកឃើញទៅ គាត់ថា ដែលឃើញគាត់ស្លាប់នោះ គឺនៅពេលដែលគាត់ឃើញគេយកឪពុកខ្ញុំទៅ។ អ៊ីចឹងហើយបានខ្ញុំចាំជាប់ គឺចាំនៅពេលដែលម្ដាយស្លាប់។ នេះឯង គឺកាលណាចុះខុសពីហ្នឹង ខ្ញុំសូមទទួលស្គាល់ថារឿងពិតរបស់ខ្ញុំ ពិតជាជួបអ៊ីចឹងមែន។ ប៉ុន្តែការខុសចុះថ្ងៃខែ គឺជាលក្ខណៈមួយដែលខ្ញុំ វាច្របូកច្របល់ក្នុងឱកាសនោះ។ សូមអ្នកម្ចាស់សំណួរទទួលដឹងផងថា នៅពេលនោះអស់លោកទាំងអស់ដែលនៅក្នុងស្រុកខ្មែរពិបាកវេទនាណាស់។ អ៊ីចឹងការចងចាំប្រហែលជាមិនចងចាំអស់ទេ។ សូមទោសបាទ។

[១៥:២៦:៣៨]

**ស៖** លោកក៏បានលើកឡើថា មានអ្នកផ្សេងក៏គេយកទៅផងដែរ។ លោកបានលើកឡើងលោក ម៉ៅ ឆេង, លោក ស៊ឹម កា និងលោក ឃាវ សារ៉ន -- គឺលោក ឃាវ សារុន។ តើលោកហេតុអ្វីបានជាដឹងថា គេយកអ្នកផ្សេងទៅផងនោះ ហើយមានតែបុគ្គលមួយចំនួនទេ ដែលនៅសល់ជីវិតនោះ?

**ឆ៖** ខ្ញុំសូមជម្រាបឆ្លើយបញ្ជាក់ ត្រង់នេះ ខ្ញុំមិនបានដាក់ថា អ្នក ឃាវ សារុន, លោក ម៉ៅ ជាង, លោក ស៊ឹម កា នេះថាទៅ ឬក៏យកទៅសម្លាប់នោះ មិនមែនទេ។ គឺការពិតទៅ ខ្ញុំគ្រាន់តែដាក់បញ្ជាក់ថា អ្នកនៅសល់បានដឹងឮនៅពេលដែលថាគេយកឪពុកខ្ញុំទៅ គឺអ្នកដឹងឮ គឺលោក ស៊ឹម កា ហើយលោក ម៉ៅ ជាង និងលោក ឃាវ សារុន។ ខ្ញុំសូមបញ្ជាក់ថា លោក ឃាវ សារុន គឺជាក្មួយរបស់ឪពុកខ្ញុំផ្ទាល់ឯលោក ម៉ៅ -- ឯលោក ជាង ម៉ៅ គឺជាអ្នករួមបន្ទុកការងាររបស់គាត់។ ហើយលោក ស៊ឹម កា នេះគឺជាលោក -- លោកជានាទីរបស់គាត់ទទួលខុសត្រូវមួយផ្នែក។ ផ្នែកខាងនីរសារនៅក្នុងតំបន់២០។ ម្ល៉ោះហើយ គាត់នោះ ដែលខ្ញុំបញ្ជាក់ថា គាត់ជាអ្នកនៅរស់អាចដឹងឮថា ឪពុកខ្ញុំគេយកទៅ ឬមិនយកទៅ? ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យអ្នកដែលតាមដានរកៗធាតុពិតនោះ ថាពាក្យនេះ គឺជាពាក្យពិត ឬក៏ជាពាក្យ ខ្ញុំភូតកុហក។ ដើម្បីបញ្ជាក់ការពិត ខ្ញុំចង់ឲ្យអ្នកដែលតាមដានឯកសារ ជួបអ្នកទាំងប៉ុន្មាននាក់ ព្រោះអ្នកទាំងអស់នោះនៅរស់។

[១៥:២៨:៣៥]

លោក ស៊ឹម កា នៅការងារនៅឡើយនៅក្រុងភ្នំពេញ។ ឯលោក ម៉ៅ ជាង គឺស្ថិតនៅក្រុងកំពង់ចាម។ ហើយលោក ឃាវ សារុន ស្ថិតនៅស្រុកកំណើតរបស់ខ្ញុំ -- ភូមិកំណើតបាទ។ សូមជ្រាបបាទ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំពុំមានសំណួរទៀតទេ។ លោកដើមបណ្តឹងរដ្ឋប្បវេណីក្នុងនាមលោក អៀង សារី យើងខ្ញុំជាមួយនឹងលោក អាង ឧត្តម សូមអរគុណលោកច្រើនដែលលោកមកផ្តល់សក្ខីកម្ម ហើយសូមលោកមានសំណាងល្អ។

[១៥:២៩:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក អែម អឿន។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ឥឡូវនេះដល់វេនខ្ញុំចោទសំណួរទៅលោក។ មានប្រធានបទមួយចំនួនដែលបានលើកឡើងដោយសហភាតារបស់ខ្ញុំហើយ ក៏ប៉ុន្តែមានការបំភ្លឺមួយចំនួនដែលខ្ញុំចង់ធ្វើ ហើយដែលចង់ឱ្យលោកជួយបំភ្លឺ។ ខ្ញុំដឹងថាអង្គហេតុនេះ វាកើតឡើងអស់រយៈពេលជាយូរណាស់មកហើយ ហើយវាមិនជាការងាយស្រួលនោះទេក្នុងការដឹងឱ្យបានច្បាស់លាស់នោះ ក៏ប៉ុន្តែវាជា ងាយស្រួលជាងក្នុងការយោងទៅលើព្រឹត្តិការណ៍ណាមួយដើម្បីឱ្យដឹងច្បាស់។ ឥឡូវនេះ ខ្ញុំចង់ធ្វើពិភាក្សាជាមួយលោកដើម្បីឱ្យដឹងព័ត៌មានច្បាស់តាមរយៈព្រឹត្តិការណ៍មួយចំនួន។ ចំណុចចំណាំទី១ គឺថាលោកបានឆ្លើយនៅក្នុងសវនាការនេះថា "ប្រហែលជាអាយុ ១០ឆ្នាំលោកបានទៅនៅជាមួយអ៊ំរបស់លោកនៅទីក្រុងភ្នំពេញ ហើយនៅពេលដែលគាត់យល់ឃើញថាសង្គ្រាមនឹងចាប់ផ្តើមកើតមានឡើង ហើយស្ថានភាពសន្តិសុខមិនល្អនោះ គាត់ក៏បញ្ជូនលោកទៅឪពុកម្តាយរបស់លោកវិញនៅតំបន់២០"។ សំណួរខ្ញុំដូចតទៅនេះ នៅពេលដែលលោកចូលទៅដល់តំបន់២០ បន្ទាប់ពីបានស្នាក់នៅផ្ទះអ៊ំរបស់លោក ជាគ្រូពេទ្យនោះ តើនៅមុន ឬក៏នៅក្រោយពេលរដ្ឋប្រហាររបស់ លន់ នល់?

[១៥:៣២:០០]

**លោក អែម អឿន៖**

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមឆ្លើយបញ្ជាក់ថា ខ្ញុំនៅមុនរដ្ឋប្រហារបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកឆ្លើយតបជាមួយលោកមេធាវី កាណាវាស លោកបានលើកឡើងអំពីចំណុចចំណាំមួយទៀត ដែលជាកាលបរិច្ឆេទនៃការបាត់ខ្លួនរបស់ឪពុករបស់លោក ហើយយើងយល់ស្របថា បើតាមអ្វីដែលលោកបានឆ្លើយទៅតុលាការថ្ងៃនេះ គឺលោកបានបញ្ជាក់ថានៅឆ្នាំ១៩៧៤ តើអ៊ីចឹងមែនទេ? លោកបញ្ជាក់ឆ្នាំ៧៤ នេះមែនទេ?

**ឆ៖** ខ្ញុំទទួលស្គាល់គឺឆ្នាំ៧៤ បាទ។

**ស៖** សូមអរគុណ។ ឥឡូវបើខ្ញុំយកឆ្នាំ៧៤ នេះជាចំណុចចំណាំ ហើយខ្ញុំសូមដកស្រង់ចម្លើយរបស់លោកនៅសវនាការថ្ងៃទី២៣ សីហា កន្លងទៅនេះ គឺនៅម៉ោង មុនម៉ោង១២ថ្ងៃត្រង់ គឺថាម៉ោង

១២:០០:០៧ លោកបានឆ្លើយថា "នៅពេលដែលលោកនិយាយអំពីការស្នាក់នៅរៀនសូត្រនៅប្រទេសវៀតណាម លោកឆ្លើយថាបន្ទាប់ពីបានចេញពីប្រទេសវៀតណាមមក ឪពុករបស់ខ្ញុំ សោ ភឹម និង តា ខឹម បានសុំឲ្យខ្ញុំក្លាយជាពេទ្យនៅតំបន់នោះ។ បើតាមខ្ញុំចាំនោះ កាលនោះខ្ញុំមានអាយុប្រហែល ចន្លោះពី២០ ទៅ ២៣ឆ្នាំ"។ បើខ្ញុំយកចំណុចចំណាំនៃការបាត់ខ្លួនរបស់ឪពុករបស់លោក ប្រសិនបើជាឪពុករបស់លោកចូលរួមក្នុងការធ្វើសម្រេចឲ្យលោកធ្វើការជាគ្រូពេទ្យនៅក្នុងតំបន់នោះ ដូច្នេះយើងយល់ស្របថាលោកធ្វើការនៅតំបន់២០ គឺថាយ៉ាងហោចណាស់ក៏មុនឆ្នាំ១៩៧៤ ដែរ តើលោកយល់ស្របដែរឬទេ គឺថាមានការសម្រេចចិត្តឲ្យលោកធ្វើការជាគ្រូពេទ្យមុនឆ្នាំមួយពាន់ប្រាំ -- នៅក្នុងឆ្នាំ១៩៧៤?

[១៥:៣៣:៥៥]

**ឆ៖** ត្រង់ហ្នឹង ខ្ញុំបានបញ្ជាក់ហើយថា ខ្ញុំមិនបានចាំពេលវេលាឆ្នាំខែច្បាស់លាស់ទេ ប៉ុន្តែខ្ញុំគ្រាន់ដឹងថា ក្រោយពីពេលខ្ញុំត្រឡប់ពីភ្នំពេញមកវិញ បានខ្ញុំត្រឡប់ទៅ -- ឪពុកខ្ញុំបញ្ជូនទៅរៀននៅវៀតណាម។ អ៊ីចឹងការពិតដែលគាត់បញ្ជាក់ថា ថ្ងៃ -- ៧៤នោះ ក៏ខ្ញុំសម្គាល់យកត្រង់ហ្នឹងដែរបាទ។

**ស៖** សូមអរគុណ។ តម្រុយសម្គាល់មួយទៀត ទាក់ទងកាលបរិច្ឆេទនេះដែលខ្ញុំចង់បំភ្លឺជាមួយលោកគឺជាកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍របស់លោក។ នៅក្នុងសវនាការនេះ លោកបានឆ្លើយថា សវនាការថ្ងៃទី២៣ សីហា ឆ្នាំ២០១២ គឺក្រោយ ជាម៉ោង១៤ -- ជាម៉ោង ១៦:០៤:០៨ លោកបាននិយាយថា យ៉ាងហោចណាស់ គឺថាទាក់ទងនឹងថ្ងៃ ដែលលោកច្បាស់ដែរ គឺថានៅថ្ងៃទី១៧ មេសា លោកបានឆ្លើយថា "ខ្ញុំជ្រើសយកថ្ងៃទី១៧មេសា ជាថ្ងៃរៀបអាពាហ៍ពិពាហ៍របស់ខ្ញុំ ពីព្រោះថា ញាតិមិត្តជិតខាងរបស់ខ្ញុំបានចូលរួម មកការរៀបការរបស់ខ្ញុំ ហើយបើពុំមានវត្តគាត់ទាំងអស់គ្នា នោះទេខ្ញុំប្រហែលជាជំទាស់មិនរៀបការទេ"។ បើសិនជាខ្ញុំមានការភ័ន្តច្រឡំ សូមឲ្យកែប្រែខ្ញុំ ដោយលោកនិយាយថា "ថ្ងៃទី១៧ មេសា នេះ ជាថ្ងៃបុណ្យ។ ដូច្នេះ លោកជ្រើសរើសយកថ្ងៃនេះ ជាថ្ងៃរៀបការរបស់លោក ដើម្បីឲ្យញាតិមិត្តជិតខាងរបស់លោកអាចមកបាន"។ តើនេះជាការត្រឹមត្រូវដែរឬទេ?

[១៥:៣៥:៥១]

**ឆ៖** នេះគឺជាការកំណត់របស់ខ្ញុំនៅថ្ងៃ មិនកំណត់ទេ គឺចាំរបស់ខ្ញុំពីពេលនោះមក។ កំណត់យកថ្ងៃ១៧។ តែឆ្នាំៗ ខ្ញុំមិនទាន់ប៉ានកំណត់ឲ្យច្បាស់ថា ឆ្នាំណាទេ ប៉ុន្តែដឹងថា ថ្ងៃ១៧ ខែមេសា។

**ស៖** នៅទំព័រដដែលនេះ នៃពង្រាងប្រតិចារឹកនោះ គឺថានៅម៉ោង ១៦:០៤:០៨ ដដែលនេះក្រោយហ្នឹងបន្តិច លោកនិយាយថា "លោកបានពិតជាបានរៀបការមែន។ តើនៅថ្ងៃទី១៧ ឆ្នាំ១៩៧០ --

១៧ មេសា ៧៧ ឬ ៧៨ ខ្ញុំមិនច្បាស់ទេ ក៏ប៉ុន្តែខ្ញុំដឹងថា ខ្ញុំរៀបការនៅក្នុងខែ -- ឆ្នាំមួយ ឬក៏ឆ្នាំមួយទៀត"។ អានេះ គឺជាអ្វីដែលលោកបានលើកឡើងនៅក្នុងសវនាការ។ អ៊ីចឹង ខ្ញុំសូមយោងទៅចម្លើយរបស់លោកពីមុនៗមួយចំនួន។

[១៥:៣៧:០២]

បាទ ឥឡូវនេះ ខ្ញុំសូមចាប់ផ្តើមយោងទៅនិយាយអំពីសំណុំបែបបទរបស់លោក ជាជនរងគ្រោះរបស់លោក។ គឺឯកសារ D22/3963។ បើសិនជាខ្ញុំមិនច្រឡំទេ ចម្លើយរបស់លោកដែលបានផ្តល់ជូនទៅសហភាតារបស់ខ្ញុំ អម្បាញ់មិញនេះ គឺថាជាចម្លើយដែលលោកសរសេរដោយដៃ ដោយខ្លួនឯងផ្ទាល់នេះជាអ្វីដែលលោកបានសរសេរទាក់ទងទៅនឹងការរៀបការរបស់លោក។ បាទ ខ្ញុំសូមដកស្រង់ ERN ជាភាសាបារាំងគឺ 00786287, ERN ជាភាសាអង់គ្លេស 00751868, ជាភាសាខ្មែរ គឺ 00573980។ កថាខណ្ឌដែលខ្ញុំនឹងដកស្រង់នេះ គឺជាផ្នែកដែលលោកបានលើកឡើងទាក់ទងនឹងការរៀបការរបស់លោក។ នេះជាអ្វីដែលលោកនិយាយ ដូចតទៅនេះ ជាភាសាបារាំង គឺថានៅកថាខណ្ឌទី៤ នៅក្រោមគេ។ លោកពន្យល់ថា "ការបណ្តុះបណ្តាលរបស់លោកនៅទីក្រុងភ្នំពេញត្រូវបានបញ្ចប់"។ ខ្ញុំសូមដកស្រង់តែម្តង គឺថា "ក្នុងការបណ្តុះបណ្តាលខ្ញុំនេះ បានចប់ទៅ ហើយខ្ញុំសប្បាយចិត្ត ហើយពេលដែលខ្ញុំត្រឡប់មកវិញ អង្គការចង់ឲ្យខ្ញុំរៀបការជាមួយនារីម្នាក់ ដែលជាប្រពន្ធខ្ញុំសព្វថ្ងៃនេះ។ ដោយសារតែខ្ញុំប៉ានជំទាស់ ខ្ញុំក៏ត្រូវបានបញ្ជូនទៅធ្វើការនៅក្នុងកន្លែងដាំដំណាំ ក្នុងរយៈ -- អស់រយៈ២ខែ"។ ហើយបន្ទាប់មកទៀត -- បាទ ខ្ញុំសូមរំលងពីរបន្ទាត់ ហើយបន្ទាប់មកលោកពន្យល់ថា "ជាចុងបញ្ចប់នោះគេក៏នាំយកលោកមកវិញ ដោយសារតែមានអ្នករបួសច្រើន។ ហើយលោកក៏សុខចិត្ត ទទួលព្រមក្នុងការរៀបការ ដែលអង្គការឲ្យធ្វើ។ នៅថ្ងៃទី១៧ ឆ្នាំ -- ១៧ មេសា ១៩៧៧ នៅក្នុងឱកាសចូលឆ្នាំខ្មែរ។ កាលណោះ មានគេរៀបការបីក្រុម អ៊ំ!បីគូ"។ នេះជាអ្វីដែលលោកឆ្លើយនៅក្នុងឯកសារ D22/3963។ តើពាក្យពេចន៍ទាំងអស់នេះ ធ្វើឲ្យលោកនឹកឃើញដែរឬទេ?

[១៥:៤០:០៤]

**ឆះ** ពាក្យទាំងអស់នេះគឺ ពាក្យដែលខ្ញុំបានសរសេរ ពេលសរសេរទម្រាំតែនឹងនឹកឃើញ មកដល់ឥឡូវទើបឃើញ បាននឹកឃើញថា ថ្ងៃ -- គឺជាថ្ងៃនុ៎ងមែន។ បាទ សូមទទួលស្គាល់បាទ។

**សះ** សូមអរគុណៗ។ ឥឡូវនេះខ្ញុំសូមនិយាយអំពីឯកសារមួយទៀត គឺជាឯកសារ D230/2/4.2.277A។ បាទត្រង់ចំណុចនេះគឺលេខ ERN ជាភាសាបារាំងគឺ 00822271, ERN ជាភាសា

អង់គ្លេសគឺ 00777625, ERN ជាភាសាខ្មែរគឺ 00508426។ ជាភាសាបារាំងគឺនៅកថាខណ្ឌក្រោយគេបំផុត ហើយលោកបាននិយាយថា "នៅដើមឆ្នាំ១៩៧៧ ខ្ញុំជាកម្មាភិបាលនៅក្នុងមន្ទីរពេទ្យតំបន់២០ យើងទាំងបីគូត្រូវបានបង្ខំឱ្យរៀបការ យើងជាកម្មាភិបាលដូចគ្នា"។ លោក អែម អឿន នៅត្រង់ចំណុចនេះខ្ញុំចង់ដឹងថា តើអ្វីដែលខ្ញុំអាននេះធ្វើឱ្យលោកនឹកឃើញដែរទេ? ហើយតើនៅក្នុងចម្លើយទាំងពីររបស់លោកនេះ គឺថាលោកបានកំណត់ថា លោកបានរៀបការនៅឆ្នាំ១៩៧៧ អ៊ីចឹងមែនទេ?

[១៥:៤២:១៥]

**ឆ៖** បាទ ទទួលស្គាល់បាទ។

**ស៖** ឥឡូវនេះយើងមានតម្រុយសម្គាល់ច្បាស់ ហើយយើងក៏ឯកភាពដែរថា លោករៀបការបន្ទាប់ពីបានទទួលការបណ្តុះបណ្តាលនៅមន្ទីរមិត្តភាពខ្មែរ-សូវៀត។ អ៊ីចឹងបើយើងធៀបទៅនឹងព្រឹត្តិ-ការណ៍ទាំងអស់នេះទៅ យើងឃើញថា លោករៀបការនៅឆ្នាំ១៩៧៧ លោកឯកភាពទេ?

**ឆ៖** ទទួលបាទ។

**ស៖** សូមអរគុណ ដែលបានបំភ្លឺ ដូច្នេះយើងនឹងអាចទៅមុខរួចហើយ។ នៅថ្ងៃនេះនៅពេលដែលឆ្លើយតបទៅនឹងសហភាតារបស់ខ្ញុំលោក ហ្សាស្តេ ប៉ោ ដែលជាមេធាវីរបស់លោក នួន ជា លោកបានកំណត់ការមកដល់ទីក្រុងភ្នំពេញរបស់លោក ដើម្បីធ្វើការសិក្សានៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនៅខែ៧ ឆ្នាំ១៩៧៦។ តើការយល់របស់ខ្ញុំនេះត្រឹមត្រូវដែរឬទេ? ខ្ញុំយល់ច្រឡំ ឬក៏យល់ខុស?

[១៥:៤៣:៣៨]

**ឆ៖** មិនខុសទេ ត្រឹមត្រូវហើយ។

**ស៖** បើសិនជាខ្ញុំយល់មិនខុសទេ ក្នុងចម្លើយរបស់លោកប៉ុន្មានថ្ងៃមកនេះ គឺថាលោកបានឆ្លើយទៅខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយលោកបានបញ្ជាក់មកសហភាតាខាងខ្ញុំនេះថ្ងៃនេះផងដែរ គឺថាបណ្តុះបណ្តាលនៅទីក្រុងភ្នំពេញនេះ ដែលត្រូវស៊ីពេលអស់រយៈពេល១ឆ្នាំនោះ មកត្រឹមតែ៩ខែនោះទេ ដោយសារមានបញ្ហានៅក្នុងតំបន់របស់លោក ហើយគេត្រូវការលោកនៅក្នុងតំបន់២០ ត្រូវការលោកជាធ្វើជាគ្រូពេទ្យនៅទីនោះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ ទាំងអស់នេះគ្រាន់តែថាយើងកំណត់តម្រុយឱ្យបានច្បាស់លាស់នៅក្នុងពេលវេលាតែប៉ុណ្ណោះ ព្រោះថាយើងត្រូវការប្រៀបធៀបទៅនឹងព្រឹត្តិការណ៍ទាំងអស់នេះ ដែលខ្ញុំបាន

និយាយនេះ។ លោកមកទីក្រុងភ្នំពេញនៅខែកក្កដា ឆ្នាំ១៩៧៦ អស់រយៈពេល៩ខែ ហើយក្រោយមកទៀតលោកត្រឡប់ទៅតំបន់របស់លោកវិញ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទៗ។

[១៥:៤៥:០១]

**ប្រធានអង្គជំនុំ៖**

សាក្សីប្រយ័ត្នប្រយែងបន្តិច ហើយមេធាវីការពារក្តីដូចគ្នា។ ឃើញសំណួរចុងក្រោយនេះគឺសុទ្ធតែជាសំណួរនាំមុខ អាចឈានទៅដល់ការខុស។ សូមកែសម្រួលរបស់ខ្លួនឡើងវិញលោកមេធាវី ក្នុងការតាំងសំណួរចៀសវាងប្រើប្រាស់នូវសំណួរដឹកមុខ នាំឲ្យមានកំហុសទៅលើនីតិវិធីនៃការតាំងសំណួរដេញដោល។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមបញ្ជាក់។ សូម -- គឺថាសំណួរខ្ញុំមិនមែនជាសំណួរនាំមុខទេលោកប្រធាន។ ខ្ញុំគ្រាន់តែចង់ពិភាក្សាជាមួយសាក្សីនេះ ថាៗពីអ្វីដែលគាត់បានលើកឡើងនៅក្នុងចម្លើយមុនៗរបស់គាត់ ហើយយើងចង់បង្កើតកាលប្បវត្តិមួយឲ្យច្បាស់លាស់។ ព្រោះថាប៉ុន្មានថ្ងៃកន្លងមកនេះនោះ យើងបាននិយាយអំពីព្រឹត្តិការណ៍ច្រើនណាស់ ក៏ប៉ុន្តែមិនបានបង្កើតឲ្យមានការកាលប្បវត្តិច្បាស់លាស់នោះទេ។

[១៥:៤៦:០៧]

ដោយឧទាហរណ៍គឺថា ដើម្បីផ្តល់លទ្ធភាពឲ្យលោក អែម អឿន នេះគាត់មានតម្រុយច្បាស់លាស់។ អានេះគ្រាន់តែជាសំណួរបញ្ជាក់បំភ្លឺនោះទេ។ ខ្ញុំមិនចង់នាំមុខគាត់ទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែសំណួរបែបដឹកមុខ នាំមុខរបស់លោកស្រី នាំឲ្យសាក្សីភ័ន្តច្រឡំ។ ពីព្រោះឆ្នាំ -- ខែ៧ ឆ្នាំ៧៦ សាក្សីបានឆ្លើយថា ខ្លួនបានចូលរៀនវគ្គនយោបាយនៅសាលានយោបាយបុរីកីឡា។ មិនមែនគាត់មកធ្វើការនៅក្រុងភ្នំពេញទេ។ ធ្វើការក្រុងភ្នំពេញ គឺខែ៦ ឆ្នាំ១៩៧៥ លោកស្រីប្រើសំណួរនាំមុខនាំឲ្យសាក្សីនេះ ឆ្លើយបាទ គឺជាការភ័ន្តច្រឡំ។ ពិនិត្យសំណួររបស់លោកស្រីឡើង ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់! អ៊ីចឹងហើយបានជាចៀសវាងការសួរបែបនេះ នាំឲ្យមានកំហុសក្នុងការអនុវត្តនីតិវិធីនៃការសួរដេញដោលតាមផ្លូវតុលាការ គឺប្រភេទនៃការសួរដឹកមុខបែបនេះ។

[១៥:៤៧:៣០]

**កញ្ញា អង់តា ហ្គីសសេ៖**

ដូច្នេះ របៀបល្អជាងគេនោះ គឺថាចង់ -- ត្រូវតែឲ្យដើមបណ្តឹងរដ្ឋប្បវេណីបំភ្លឺបញ្ហាមួយចំនួន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក អែម អឿន នៅសវនាការ (សូមទោស) គឺសវនាការម្សិលមិញនេះ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ដែលគាត់សុំឲ្យសួរលោកទាក់ទងទៅនឹងវគ្គអប់រំនយោបាយនៅបុរីកីឡា សួរលោកថា "តើលោកដឹងពីតួនាទីរបស់លោក ខៀវ សំផន ហើយនិង នួន ជា ដែរឬក៏អត់?" ម្សិលមិញនេះគឺលោកឆ្លើយថា "លោកដឹងអំពីមុខងាររបស់គាត់ទាំងអស់គ្នា" ដោយឆ្លើយថា "លោក ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ហើយ នួន ជា ជាប្រធានសភាតំណាងប្រជាជនកម្ពុជា"។ លោក អែម អឿន ខ្ញុំចង់ដឹងថា តើសោ ភឹម ជាអ្នកប្រាប់ពីតួនាទី របស់គាត់ទាំងអស់គ្នានេះជាមុន មុនពេលដែលលោកមកទទួលការអប់រំនោះនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ឬក៏យ៉ាងម៉េច?

[១៥:៤៩:០៧]

**លោក អែម អឿន៖**

**ឆ៖** តួនាទីដែលខ្ញុំបានដឹង ព្រោះខ្ញុំបានដឹងទៅតាមដំណើរឪពុកខ្ញុំផង លោក ខឹម គណៈតំបន់ផង និងលោក សោ ភឹម ផង គឺខ្ញុំស្គាល់នាទីថា លោក ខៀវ សំផន ធ្វើអ្វី លោក នួន ជា គាត់ធ្វើអ្វី គឺស្គាល់ទៅតាម ដឹងទៅតាមដំណើរអ្នកធ្វើការកន្លងមក។ តែគ្រាន់តែឮសំឡេង ឮឈ្មោះនោះទេ ការស្គាល់មុខមាត់ គឺមិនដែលស្គាល់ទេ ទើបតែមកស្គាល់នៅពេលចូលមន្ទីរពេទ្យនេះឯង នៅបុរីកីឡានេះឯង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ E3 ទៅលោក អែម អឿន។ ខ្ញុំមិនច្បាស់ថាលោក អែម អឿន បានឃើញឯកសារនេះនោះទេ គឺឯកសារ E3 165 ចំណងជើងគឺថា ជាសមាជទី១នៃនីតិបញ្ញត្តិមធ្យមនៅថ្ងៃទី១១ មេសា ឆ្នាំ១៩៧៦។ បាទ ចង់បង្ហាញសម្រង់មួយនៃឯកសារនេះដែលលោក នួន ជា និងលោក ខៀវ សំផន ត្រូវបានតែងតាំងឲ្យកាន់តំណែងគាត់រៀងៗខ្លួន នៅក្នុងអង្គប្រជុំសន្និបាតលើកទី១នេះ ក្នុងសម័យកាលទី១។

លោកប្រធាន តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបញ្ចាំងឯកសារនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

[១៥:៥១:១៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ទំព័រទី១ ដែលខ្ញុំចង់បង្ហាញជូនលោក អែម អឿន នេះគឺជាឯកសារ គឺលេខ ERN ជាភាសាបារាំងគឺថា 00301353, ERN ជាភាសាខ្មែរគឺ 00053632 ហើយមានហួសទៅទំព័រមួយទៀតដែរ, បន្ទាប់ដែរគឺថា ERN ជាភាសាអង់គ្លេស 00184066។ លោក អែម អឿន លោកមើលឃើញឯកសារនេះ ទំព័រនេះហើយឬនៅ? ខ្ញុំសូមអានសម្រង់មួយនៃឯកសារនេះ ដូចដែលខ្ញុំបានជម្រាបជូនអម្បាញ់អ៊ីចឹងគឺថា ជាឯកសារទាក់ទងទៅនឹងមហាសន្និបាត នៃសម័យនីតិកាលទី១នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ លោកបាននិយាយថា "លោក សោ ភឹម និងឪពុករបស់លោកបានប្រាប់ពីមុខងាររបស់ ខៀវ សំផន និង នួន ជា ដល់លោក"។ ហើយនៅក្នុងឯកសារនេះ ប្រហែលជានៅក្នុងមហាសន្និបាតនេះ ថា នួន ជា និង ខៀវ សំផន នេះត្រូវបានតែងតាំង គឺថានៅកថាខណ្ឌទី៤ មានចែងដូចតទៅនេះ "ក្នុងពេលនេះ មហាសន្និបាតបានតែងតាំង ហើយនិងបង្កើតជាគណៈកម្មាធិការជាច្រើន--

**អ្នកបកប្រែ៖**

លោកប្រធាន ខ្ញុំតាមអត់ទាន់ លោកប្រធាន ដោយសារគាត់អានលឿនពេក។

[១៥:៥៣:១១]

**ប្រធានអង្គជំនុំ៖**

អានឡើងវិញម្តងទៀត ព្រោះអ្នកបកប្រែបកមិនទាន់ទេ។ សូមឲ្យយឺត ដើម្បីឲ្យអ្នកបកប្រែអាចបកបាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** បាទ ខ្ញុំសូមចាប់ផ្តើមជាភាសាខ្មែរគឺថា 0053632 (ស៊ីក) ហើយអាចបន្តទៅទំព័រខាងបន្ទាប់នោះផងដែរ ERN ជាភាសាបារាំងគឺ ជាទំព័រទី២០ នៅក្នុងឯកសារហ្នឹងគឺ ERN គឺ 00301353, ERN ជាភាសាអង់គ្លេសគឺ 00184066។ លោក អែម អឿន នៅក្នុងឯកសារនេះ មានសរសេរដូចតទៅនេះ៖ "ព្រមជាមួយគ្នានេះ សភាក៏បានជ្រើសតាំងសមាសភាព របស់គណៈកម្មាធិការអចិន្ត្រៃយ៍ នៃសភាតំណាងប្រជាជនកម្ពុជា និងសមាសភាពរបស់គណៈកម្មាធិការផ្សេងៗរបស់សភាផងដែរ។ គណៈ

កម្មាធិការអចិន្ត្រៃយ៍ នៃតំណាងសភាតំណាងប្រជាជនកម្ពុជា មានសមាសភាពដូចតទៅ៖ ចំណុចទី១ សមមិត្ត នួន ជា ជាប្រធាន"។ បានខ្ញុំសូមបញ្ចប់នៅលើទំព័រនេះ។

នៅទំព័របន្ទាប់ទៀតនោះ ERN ជាភាសាបារាំង គឺ 00301354 , ជាភាសាខ្មែរគឺ 00053634, ហើយជាភាសាអង់គ្លេសគឺ 00184068។ មានសរសេរដូចតទៅនេះ គឺថាមាននៅចំណុចប្រាំតូចនេះ "ការជ្រើសតាំងគណៈប្រធានរដ្ឋនៅកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីបានពិភាក្សាយ៉ាងហ្មត់ចត់ និងល្អិតល្អន់លើលក្ខណៈសម្បត្តិផ្សេងៗគ្រប់ទិដ្ឋភាពមក សភាបានអនុម័តជ្រើសរើសតាមគណៈប្រធានរដ្ឋកម្ពុជាប្រជាធិតេយ្យដែលមានសមាសភាពដូចតទៅ៖ ១) មិត្ត ខៀវ សំផន ប្រធាន ២) មិត្ត សោ ភឹម អនុប្រធានទី១"។

នៅពេលដែលលោក អែម អឿន បានដឹងហើយ ខ្ញុំសូមអនុញ្ញាតបញ្ចាំងទំព័រទី១ នៃឯកសារនេះ គឺថា E3/165 ដែលនិយាយអំពីកាលបរិច្ឆេទនៃឯកសារនេះ គឺថានៅថ្ងៃទី១១ ទៅ១៣ មេសា ឆ្នាំ១៩៧៦។ សំណួរខ្ញុំដូចតទៅនេះ លោក អែម អឿន បើការតែងតាំងរបស់លោក នួន ជា និងលោក ខៀវ សំផន ចុះនៅថ្ងៃទីដប់ -- ពី១១ ទៅ១៣ មេសា ឆ្នាំ១៩៧៦ ខ្ញុំមានការលំបាកក្នុងការយល់ឃើញថាឪពុករបស់លោកស្លាប់នៅឆ្នាំ១៩៧៤ ហើយនិងលោកនិយាយអំពីការតែងតាំងរបស់លោក ខៀវ សំផន និងលោក នួន ជា។ មានបញ្ហាចម្រូងចម្រាសត្រង់នេះ លោកដើមបណ្ដឹងរដ្ឋប្បវេណី?

[១៥:៥៧:២០]

**ឆ៖** ការចម្រូងចម្រាសពិតជាមាន ព្រោះថាខ្ញុំពេលនោះហាក់ដូច -- មិនមែនហាក់ទេ រឿងពិតរបស់ខ្ញុំ គឺរឿងពិតៗជាឪពុកខ្ញុំបាននិយាយ តែនិយាយនៅពេលដែលគេតែងតាំង ឬគាត់និយាយមុន គឺអត់ដឹង ព្រោះឪពុកខ្ញុំ គាត់ធ្វើការយូរហើយ។ ដូច្នេះក៏ប្រហែលជាខ្ញុំ ថាប្រហែលចុះថា ខ្ញុំបានដឹងនៅពេលគាត់ប្រាប់ខ្ញុំមុន មុនការតែងតាំង ព្រោះថាគាត់ឧស្សាហ៍មកភ្នំពេញណាស់។ ព្រោះខ្ញុំបានដឹងថាគាត់មកនោះ មកធ្វើអីទេ? អ៊ីចឹងធាតុពិតនោះ គាត់ឧស្សាហ៍បាននិយាយជាមួយខ្ញុំ ពីគោលការណ៍នៃការបង្កើតខ្មែរក្រហមកន្លងមកនោះ។ គាត់តែងតែដឹងថា អ្នកនេះធ្វើអីចេះ អ្នកនោះធ្វើអីចុះ។ សូម្បីតែមាខ្ញុំនៅភ្នំពេញយកខ្ញុំមកដេកឲ្យធ្វើពេទ្យនេះ ក៏ទៅតាមដំណើរការរៀបចំរបស់គាត់ដែរ ដល់ពេលថ្ងៃក្រោយទៅនោះ។ អ៊ីចឹងសូមលោកម្ចាស់សំណួរ សូមអភ័យទោស កាលបរិច្ឆេទរបស់ខ្ញុំប្រហែលជាមិនច្បាស់ ប៉ុន្តែរឿងពិតគឺអ៊ីចឹងមែនបាទ។

[១៥:៥៨:៣៨]

**ស៖** តើលោក -- ឪពុករបស់លោកប្រាប់លោកអ្វីខ្លះនៅមុនឆ្នាំ១៩៧៤ គឺមុនពេលស្លាប់នោះ ប្រាប់អ្វីខ្លះទាក់ទងនឹង ខៀវ សំផន ហើយនិង នួន ជា នេះ? តើគាត់បាននិយាយអំពីចំណងជើងទាំងអស់នេះ ដែលលោកបានប្រាប់ -- ពីតំណែងរបស់គាត់ទាំងអស់គ្នានេះ ជាគណៈប្រធានរដ្ឋ ហើយនិងលោក នួន ជា ជាប្រធានសភាតំណាងប្រជាជនកម្ពុជានេះ? តើមុនពេលគាត់ស្លាប់ហ្នឹងគាត់បាននិយាយជាមួយលោកអំពីព័ត៌មានទាំងអស់នេះដែរឬទេ?

**ឆ៖** ត្រង់នេះ គឺខ្ញុំសូមបញ្ជាក់ថា ការនិយាយគឺច្រើនណាស់ ប៉ុន្តែមិនមែនប៉ុណ្ណឹងទេ គឺច្រើន ប៉ុន្តែការចាំរបស់ខ្ញុំ អាចនឹងចាំកន្លែងណាដែលចាំ គឺចាំ។ កន្លែងណាដែលមិនចាំ មិនចាំ។ សូមជម្រាបម្ចាស់សំណួរបាទ។

[១៥:៥៩:៤៨]

**ស៖** បើខ្ញុំយល់មិនខុសទេ នៅពេលដែលលោកឆ្លើយទៅ នៅក្នុងសវនាការកាលពីម្សិលមិញនេះ ពេលលោកឆ្លើយទៅសហព្រះរាជអាជ្ញាថា ប្រាប់គាត់ថា “លោកស្គាល់មុខងាររបស់លោក ខៀវ សំផន ហើយនិងមុខងាររបស់លោក នួន ជា។ នៅពេលដែលលោកឃើញគាត់នៅបុរីកីឡា តើនេះបានន័យថា លោកច្រឡំ ឬលោកចាំមិនច្បាស់ ឬក៏ថាមិនមែនជាការពិតទេនៅពេលដែលឆ្លើយទៅលោកសហព្រះរាជអាជ្ញាម្សិលមិញ?

**ឆ៖** ខ្ញុំនិយាយពីម្សិលមិញអត់មានច្រឡំទេ គឺជារឿងច្បាស់ ប៉ុន្តែនិយាយថាពាក់ព័ន្ធច្រឡំ គឺច្រឡំតែថ្ងៃដែលខ្ញុំមកទៅតាមដំណើរឪពុកខ្ញុំដឹងនៅពេលណាគឺខុស ប៉ុន្តែការដឹង និងចាំបានថា ឃើញនៅបុរីកីឡាគឺខ្ញុំនិយាយពិតមែន ហើយខ្ញុំស្គាល់ពិតមែនបាទ។

**ស៖** ឥឡូវខ្ញុំទទួលយកសំណួរ -- ចម្លើយនេះទៅចុះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ឥឡូវខ្ញុំឃើញថាម៉ោងបួនហើយ តើខ្ញុំអាចបន្តសំណួរទៀតបានដែរឬទេ ឬក៏ថាលោកប្រធានចង់ឲ្យសម្រាកឥឡូវនេះ?

[១៦:០១:០៤]

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយណេះ។ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់

ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២៩ ខែសីហា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលនឹងបន្តតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ សូមភាគី និងសាធារណជនជ្រាប។

លោក អែម អឿន ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត ដូច្នេះអង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ព្រមទាំងសាក្សីបម្រុងថ្ងៃនេះដែលមានរហស្សនាម TCW-480 វិលត្រឡប់ទៅកាន់ទីកន្លែងដែលពួកគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។ ដោយឡែកសាក្សីបម្រុងដែលមានរហស្សនាម TCW-480 ឲ្យគាត់មកបម្រុងនៅបន្ទប់រង់ចាំក្នុងបរិវេណអគារ អ.វ.ត.ក នេះ។

[១៦:០២:២១]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*